# បច្ច័យ៤




រៀបរៀងដោយៈ ឧបាសក គីម-អួន

សម្រាប់ជាធម្មទាន

# ពាក្យគួរចងចាំ

ធម៌ទាំងឡាយកើតព្រោះ មានហេតុ មានបច្ច័យ ដូច្នេះតែវាយ៉ាងម៉េចគឺវាអ៊ីចឹងឯង កុំចាំបាច់ចង់កុំឱ្យវាអ៊ីចឹងអី នេះជាច្បាប់ធម្មជាតិពិត១ ហើយនឹងម្យ៉ាងទៀត ចិត្តយើងមិនដូចចិត្តគេទេ កុំចង់ឱ្យតែគេគិតដូចយើង ពីព្រោះអ្វី? ពីព្រោះបើយើងវិញក៏គិតមិនដូចគេដែរ នេះជាចិត្តនិយាម(ជាទំនៀមឬក៏ជាច្បាប់របស់ចិត្ត) ។

ធ្វើនៅសៀមរាប,ថ្ងៃ៤កើត ខែមិគសិរ

ឆ្នាំខាល ទោស័ក ព.ស ២៥៥៤

ត្រូវនឹងថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០

ដោយបំណងល្អពីខ្ញុំព្រះករុណាខ្ញុំបាទ **គីម អួន**

# អភិធម៌






បង្រៀនដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**

បង្រៀននៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ

រៀបរៀងដោយខ្ញុំព្រះករុណាខ្ញុំបាទ គឹម អូន

*សម្រាប់ជាធម្មទាន*

# សិក្សាសតិប្បដ្ឋាន

# និង

# ការពិចារណាបច្ច័យ៤




បង្រៀនដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**

បង្រៀននៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ

ធ្វើនៅសៀមរាប,ថ្ងៃ៤កើត ខែមិគសិរ ឆ្នាំខាល

ទោស័ក ព.ស ២៥៥៤, គ.ស ២០១០

រៀបរៀងដោយខ្ញុំព្រះករុណាខ្ញុំបាទ **គឹម_អួន**

# ពាក្យប្រារព្ធ

សៀវភៅនេះខ្ញុំបាទបានចម្លងចេញពីខ្សែអាត់សំឡេងព្រះធម៌របស់លោកគ្រូ**អគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស** ដែលលោកគ្រូបានបង្រៀនព្រះអភិធម្ម នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ ដូច្នេះព្រះករុណាគុណម្ចាស់ និងញាតិញោមអាចស្វែងរកខ្សែអាត់ព្រះធម៌ដ៏ថ្លាថ្លៃនេះមកស្ដាប់បាន ដើម្បីជាជំនួយដល់ **សតិ បញ្ញា ស្មារតី** ដែលជាឧបការៈយ៉ាងសំខាន់ចំពោះសតិប្បដ្ឋាន-វិបស្សនាបដិបត្តិ ។

ខ្ញុំបាទសូមសេចក្ដីអនុគ្រោះអំពីលោកគ្រូជាម្ចាស់ ដើម្បីបានឱកាសរៀបរៀងសៀវភៅនេះ និង សៀវភៅផ្សេងៗទៀត ដូចជាសៀវភៅ **សិក្សាព្រះអភិធម្មខ្លួនឯង** ចាប់ពីភាគ១តទៅ **សិក្សាសតិប្បដ្ឋាននិងការពិចារណាបច្ច័យ៤, សិក្សាសតិប្បដ្ឋាន និងទិដ្ឋិ៦២** ជាដើម ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់សព្វសត្វក្នុងត្រៃភព ។

ចំពោះការខិតខំប្រឹងប្រែងក្នុងព្រះពុទ្ធសាសនាដូចជាការងារធម្មទាន មានការរៀបរៀងសៀវភៅផ្សេងៗជាដើម ខ្ញុំបាទសូមបូជាចំពោះ :

-គុណព្រះរតនត្រ័យដែលមាន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សព្វៗកាល ។

-គុណមាតាបិតារបស់យើងខ្ញុំសព្វៗកាល

-គុណលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស សព្វៗកាល

**ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ**

ឧបាសិកា **ហេង ណារី** ព្រមទាំងបុត្រ បានឧបត្ថម្ភគ្រប់យ៉ាងក្នុងការងារធម្មទាននេះ ។

**សូមថ្លែងអំណរគុណសប្បុរសដែលបានឧបត្ថម្ភកុំព្យូទ័រ (Computer) សម្រាប់ការងារធម្មទាននេះគឺ:**

-លោក **ឡាយ គឹមឆេន** និងភរិយា ព្រមទាំងបុត្រ

-លោក **ទូន គង់** និងភរិយា ព្រមទាំងបុត្រ

-លោក **ហេង វិបុល** និងភរិយា ព្រមទាំងបុត្រ

-លោក **តាំង វីន** និងភរិយា ព្រមទាំងបុត្រ

# បត្តិទានកថា

ខ្ញុំព្រះករុណាខ្ញុំបាទ សូមបូជាការខិតខំប្រឹងប្រែងកសាងសៀវភៅនេះ ចំពោះព្រះរតនត្រ័យសព្វៗកាល ។

ដោយអំណាចនៃធម្មទាននេះ សូមឧទ្ទិសបុណ្យកុសលថ្វាយ ប្រគេន និង គោរពជូនៈ

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-ព្រះសង្ឃគ្រប់ៗព្រះអង្គ ទាំងក្នុងនិងក្រៅប្រទេស

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិងរាជវង្សានុវង្ស

-រាជរដ្ឋាភិបាល និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់

-មាតាបិតារបស់យើងខ្ញុំ

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**

-ឧបាសកឧបាសិកានិងពុទ្ធបរិស័ទទាំងក្នុងនិងក្រៅប្រទេស

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមត្រេកអរ អនុមោទនា នូវចំណែកបុណ្យកុសលនេះឱ្យបានស្មើៗគ្នា សូមអនុមោទនា!...

**ដោយអំណាចមហាកុសលនៃធម្មទាននេះ**

**សព្វេ សត្តា អវេរិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយ  កុំមានពៀរនឹងគ្នា

**សព្វេ សត្តា ខេមិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយ  បានដល់នូវសេចក្តីក្សេម

**សព្វេ សត្តា សុខិនោ ហោន្តុ**

សូមសត្វលោកទាំងឡាយបានប្រកបដោយសេចក្តីសុខ

ជានិច្ចនិរន្តរ៍!

ថ្ងៃ៤កើត  ខែមិគ្គសិរ  ឆ្នាំខាល  ទោស័ក  ព.ស ២៥៥៤

ត្រូវនឹងថ្ងៃទី  ១០  ខែ  ធ្នូ  ឆ្នាំ  ២០១០

ធ្វើនៅសៀមរាប

ខ្ញុំបាទ  **គីម អូន**

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**


*១-សេចក្តីផ្តើម* ........................................ ១

*២-ការពិចារណាបច្ច័យ៤* ........................... ១៩

*៣-ការពិចារណាចីវរប្បច្ច័យ* ......................... ២១

*៤-ការពិចារណាបិណ្ឌបាតប្បច្ច័យ* ............... ៤០

*៥-ភាសិតព្រះសារីបុត្ត* ................................ ៨៣

*៦-ការពិចារណាសេនាសនប្បច្ច័យ* ................ ៩៤

*៧-ការពិចារណាគិលានភេសជ្ជប្បច្ច័យ* ......... ៩៨

# ព្រះនាម និង នាមពុទ្ធបរិស័ទ
# ដែលមានឧបការៈក្នុងធម្មទាន

## សៀវភៅដែលបោះពុម្ពរួចហើយគឺ

១- បច្ច័យ៤

២-សិក្សាព្រះអភិធម្មខ្លួនឯង ភាគ១

៣-សិក្សាព្រះអភិធម្មខ្លួនឯង ភាគ២

៤-សិក្សាព្រះអភិធម្មខ្លួនឯង ភាគ៣

៥-សិក្សាព្រះអភិធម្មខ្លួនឯង ភាគ៤

## សៀវភៅដែលត្រូវបោះពុម្ពបន្តគឺ

១-សិក្សាព្រះអភិធម្មខ្លួនឯងភាគ៥,...

២-សិក្សាសតិប្បដ្ឋាន និងទិដ្ឋិ៦២

៤-សិក្សាសតិប្បដ្ឋាននឹងអកុសលធម៌ ១៨ពួក ដែលត្រូវ លះដោយមគ្គញ្ញាណ

៥-និងសៀវភៅផ្សេងៗទៀត

# ដំណឹង

ពុទ្ធបរិស័ទដែលមានបំណងចូលរួមបោះពុម្ពសៀវភៅសិក្សាព្រះអភិធម្មខ្លួនឯង (មានច្រើនភាគ) និងសៀវភៅផ្សេងៗទៀត ដែលជាការរួមចំណែកក្នុងការងារធម្មទាន សូមទំនាក់ទំនងជាមួយៈ

-ឧបាសក **សូ រេត** (ផ្សារដើមក្រឡាញ់.សៀមរាប)
០១២ ៦២ ០៧ ៣៩

-ឧបាសក **គឹម លី** (ព្រះដាក់.សៀមរាប)
០៩៧ ៩៥១ ០៤ ០៤

-ឧបាសិកា **សុវណ្ណារី** (ផ្សារញៀ.សៀមរាប)
០១៦ ៧៦ ៥០ ០៤

-ឧបាសិកា **វិញ ពូន** (ផ្សារសាមគ្គី.សៀមរាប)
០១២ ៤៩ ៦៣ ១១

-ឧបាសិកា **គឹម សួង** (ស្រុកបរិបូណ៌,កំពង់ឆ្នាំង)
០៩៧ ៩៥១ ០៥ ០៥

# សេចក្តីផ្តើម

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណាខ្ញុំបាទ សូមនមស្សការក្រាបថ្វាយបង្គំ ចំពោះសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដោយសេចក្តីគោរពកោតក្រែង និងដោយសេចក្តីជ្រះថ្លា ដែលព្រះអង្គគង់ជាសុខ និងជាអធិបតី ជាម្លប់ដ៏ត្រជាក់ដល់ពុទ្ធបរិស័ទអាចសិក្សាព្រះធម៌ ព្រះវិន័យ បដិបត្តិព្រះធម៌ព្រះវិន័យបានក្នុងកាលសម័យនេះ និងសូមនមស្សការក្រាបថ្វាយបង្គំ ព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ ដោយសេចក្តីគោរពជ្រះថ្លា និងកោតក្រែង ព្រមទាំងសូមធ្វើសេចក្តីគោរពចំពោះញាតិញោម លោកតាលោកយាយ អ៊ំពូមីង បងប្អូនស្រីប្រុស ជាពុទ្ធបរិស័ទទាំងអស់ដែលមានដៃដ៏ស្អាត គឺសទ្ធាជឿមាំលើគុណព្រះរតនត្រ័យ ដោយសេចក្តីគោរពជ្រះថ្លាអំពីខ្ញុំព្រះករុណាខ្ញុំបាទ និងសូមអនុមោទនាបុណ្យកុសលអំពីព្រះករុណាគុណម្ចាស់ និងញាតិញោមគ្រប់កាលទាំងពួង ។

នៅក្នុង **សុត្តន្តិកទុកមាតិកា** មានសម្តែងថា **ភោជនេ មត្តញ្ញុតា ច** គឺសភាវធម៌ដែលធ្វើបុគ្គលឱ្យជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

អង្គធម៌បានដល់មហាកុសល៨ដួង និងមហាកិរិយា ៨ដួង ព្រមដោយចេតសិក ៣៣ (វៀរវិរតិ៣ និងអប្បមញ្ញា២) ។

ហេតុអ្វីបានជាត្រូវវៀរវិរតិ៣? ព្រោះវិរតិមានតែបរមត្ថជាអារម្មណ៍ ហើយការដែលស្គាល់ប្រមាណក្នុងភោជននេះ គឺវាមានភោជនបញ្ញត្តិជាអារម្មណ៍ ។ ចំពោះអប្បមញ្ញា២គឺវាមានសត្វប្បញ្ញត្តិជាអារម្មណ៍ ដូច្នេះត្រូវវៀរវិរតិ៣ និងអប្បមញ្ញា២ អ៊ីចឹងចេតសិកនៅសល់៣៣ ។

នៅក្នុងការដែលស្គាល់ប្រមាណក្នុងភោជននេះ ព្រះករុណាគុណម្ចាស់បានជ្រាបស្រាប់ហើយ គឺនៅក្នុងការស្គាល់ប្រមាណក្នុងការស្វែងរក ការស្គាល់ប្រមាណក្នុងការទទួល ការស្គាល់ប្រមាណក្នុងការបរិភោគ ។ យើងជាឧបាសកឧបាសិកាក៏មានការស្គាល់ប្រមាណដែរ ទើបជាការ

បដិបត្តិទៅមិនខុស ហើយក៏ទើបមានឈ្មោះថា ជាអ្នកមាន **ចរណៈ** ដំណើរទៅតាមស្នាមព្រះយុគលបាទ ។ ញាតិញោម ចង់ដើរតាមស្នាមព្រះយុគលបាទទាំងគូរបស់ព្រះសម្មា-សម្ពុទ្ធទេ? ចង់ដង្ហែរព្រះសម្មាសម្ពុទ្ធទេ? គឺចង់ អ៊ីចឹង ទាល់តែមានការប្រព្រឹត្តនូវចរណៈ គឺធម៌ដែលជាគ្រឿង ត្រាច់ទៅ ដើម្បីឱ្យបានរួចផុតអំពីសេចក្តីទុក្ខ ។

នៅក្នុងការបរិភោគនូវអាហារភោជននេះ មានការ ប្រព្រឹត្តទៅដើម្បីកម្ចាត់បង់នូវអង្គ៤គឺ ទី១ **នេវ ទវាយ** គឺ ជាការកម្ចាត់បង់នូវការលេង បរិភោគហ្នឹងមិនមែនដើម្បី លេងដូចក្មេងអ្នកស្រុកជាដើមទេ ។ ដូចជាកូនក្មេងដែល បរិភោគដើម្បីមានកម្លាំងលេងអ៊ីចឹងទៅ ឬក៏ក្មេងៗដែល ប្រព្រឹត្តទៅដោយការវង្វេងនៅក្នុងវ័យរបស់ខ្លួន ហើយរត់ លេងសប្បាយទៅ បរិភោគដើម្បីតែប៉ុណ្ណឹងឯង ប៉ុន្តែនៅ ក្នុងការដែលស្គាល់ប្រមាណក្នុងភោជន គឺថាស្គាល់ប្រមាណ ក្នុងការបរិភោគ គឺមិនមែនបរិភោគដើម្បីលេងទេ ចំពោះ ទី២នោះគឺ **ន មទាយ** គឺបរិភោគមិនមែនដើម្បីស្រវឹងទេ ។

ស្រវឹងហ្នឹង គឺបានសេចក្ដីថា ប្រៀបបីដូចជាអ្នកប្រដាល់ អ៊ីចឹង មានការស្រវឹងនឹងកម្លាំងរបស់ខ្លួន ប្រព្រឹត្តទៅដើម្បីវាយតប់ ដើម្បីដាល់ ដើម្បីអី១អ៊ីចឹងទៅ គឺការដែលស្គាល់ប្រមាណក្នុងភោជននោះ បរិភោគមិនមែនដើម្បីការដែលទ្រទ្រង់ឱ្យមានកម្លាំងទៅវាយទៅទាត់ទៅឈ្លោះទៅប្រកែក ឬក៏ប្រព្រឹត្តធ្វើនូវអំពើណា១ ដោយអំណាចនៃកម្លាំងបាយនោះទេដែលជារឿងមិនល្អនោះ ដូច្នេះបរិភោគហ្នឹងដើម្បីកម្ចាត់បង់នូវការវង្វេង កម្ចាត់បង់នូវសេចក្ដីស្រវឹង រីឯទី៣នោះគឺ **ន មណ្ឌនាយ** មិនមែនប្រដាប់កាយទេ ដើម្បីបានអាហារបរិភោគទៅដើម្បីចម្រើនសាច់ ចម្រើនឈាមឱ្យមានការប្រដាប់កាយ តាក់តែងរាងកាយនោះទេ និងទី៤គឺ **ន វិភូសនាយ** មិនមែនឱ្យផូរផង់សម្បុរទេ ។ នេះជាការបរិភោគដើម្បីកម្ចាត់បង់នូវអង្គទាំង៤ ។

ចំពោះការកម្ចាត់បង់នេះ តាមពិតទៅនៅក្នុងគម្ពីរវិសុទ្ធិមគ្គបានសម្ដែងថា **ន ទវាយ** ដែលមិនដើម្បីលេងនោះ គឺជាការកម្ចាត់បង់នូវមោហៈ ។ **ន មទាយ** ការ

ដែលមានសេចក្ដីស្រវឹងនៅក្នុងកម្លាំងប្រព្រឹត្តទៅដើម្បីវាយតប់ឈ្លោះប្រកែកនោះ គឺដើម្បីកម្ចាត់បង់នូវទោសៈ ហើយមិនប្រព្រឹត្តដើម្បី **មណ្ឌន វិភូសន** គឺមិនប្រព្រឹត្តទៅប្រដាប់តាក់តែងស្អិតស្អាងរាងកាយនោះ គឺដើម្បីកម្ចាត់បង់នូវរាគៈ ដូច្នេះការបរិភោគហ្នឹងដើម្បីការពារនូវរាគៈទោសៈមោហៈ តែប្រព្រឹត្តទៅដើម្បីប្រយោជន៍មានច្រើនប្រការ មានរហូតដល់ទៅ៨ប្រការ ទី១គឺ **ឥមស្ស កាយស្ស ឋិតិយា** ដើម្បីការតាំងនៅនៃកាយនេះ ទី២គឺ **យាបនាយ** គឺប្រព្រឹត្តទៅដើម្បីជីវិតិន្ទ្រិយតគ្នាមិនដាច់ ហើយទី៣គឺ **វិហឹសុបរតិយា** គឺដើម្បីកម្ចាត់បង់នូវការបៀតបៀន ដោយសេចក្ដីស្រេកឃ្លាន ការស្រេកឃ្លាននេះគឺជាការបៀតបៀនផងដែរ ។ ចំពោះទី៤គឺ **ព្រហ្មចរិយានុគ្គហាយ** គឺដើម្បីអនុគ្រោះដល់សាសនព្រហ្មចរិយ និង មគ្គព្រហ្មចរិយ ។ ទី៥គឺ **ឥតិ បុរាណញ្ច វេទនំ បដិហំខាមិ** គឺដើម្បីកម្ចាត់បង់នូវវេទនាចាស់គឺការស្រេកឃ្លាន ឬក៏ទុក្ខវេទនាដែលកើតឡើងព្រោះការបរិភោគនូវអាហារមិនជាទីសប្បាយ ព្រោះការដែលមិន

ស្គាល់ប្រមាណវានាំឱ្យមានទុក្ខលំបាក ព្រោះអាស្រ័យកម្ម ចាស់គឺបាបកម្មឯណានីមួយមានឱកាសជាបច្ច័យ ដូច្នេះការ បរិភោគហ្នឹងគឺដើម្បីកម្ចាត់បង់នូវវេទនាចាស់ រីឯទី៦នោះ គឺ **នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** ដើម្បីមិនញ៉ាំងនូវវេទនាថ្មី គឺឆ្អែតហួសប្រមាណហ្នឹងឱ្យកើតឡើងផង ។

ចំពោះសេចក្ដីទាំងអស់នេះនឹងមានការពន្យល់ជាបន្ត បន្ទាប់តទៅ ហើយយើងនឹងបានរៀនសូត្រឱ្យបានជិតដល់ ល្អកុំឱ្យវារំលងនូវព្យញ្ជនៈព្រះពុទ្ធដីកាទាំងអស់ហ្នឹង នេះខ្ញុំ ព្រះករុណាខ្ញុំបាទគ្រាន់តែពន្យល់ត្រួសៗបន្តិចសិន អំពីរឿង ការស្គាល់ប្រមាណក្នុងភោជន ។ ចំពោះទី៧គឺ **យាត្រា ច មេ ភវិស្សតិ** កិរិយាប្រព្រឹត្តទៅក្នុងឥរិយាបថទាំង៤នឹង មានដល់អាត្មាអញ គឺនៅក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ហ្នឹងឯង គឺសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ និង ទី៨នោះគឺ **អនវជ្ជតា ច ផាសុវិហារោ ច** គឺដើម្បីការ មិនមានទោស តើមិនមានទោសនោះយ៉ាងណា? ហើយ ដើម្បីការដែលនៅជាសុខនោះយ៉ាងម៉េច? យើងនឹងបាន

សិក្សាឱ្យបានល្អដើម្បីពិចារណាដល់ព្រះធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងផងឱ្យបានស្របគ្នាទៅនឹងព្រះវិន័យ ដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ព្រះពុទ្ធបញ្ញត្តិ និងព្រះ-ពុទ្ធានុញ្ញាត ព្រោះការបរិភោគនូវអាហារនេះ ជាពិសេសគឺធ្ងន់ចំពោះបព្វជិតដែលត្រូវទទួលនូវអាហារបិណ្ឌបាត អំពីទាយកទាយិកា គឺទាយកទាយិកាដែលគេបានធ្វើនាះក្នុងមនោសញ្ចេតនាប្រព្រឹត្តទៅចំពោះអ្នកមានសីល ។ ឱ្យតែសម្គាល់ថាជាបព្វជិត គឺសំដៅទៅលើអ្នកមានសីលហើយ ហើយណាមួយទៀតនោះចំពោះសេចក្ដីនេះព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់អនុញ្ញាត ដើម្បីបព្វជិតបរិភោគប្រើប្រាស់នូវបច្ច័យ៤ក៏សមគួរសម្រាប់តែបព្វជិតដែលមានសីលហ្នឹងដែរ ដែលជាអ្នកបរិភោគ ។ បើសិនជាបព្វជិតហ្នឹងឯងជាអ្នកទ្រុស្តសីល ជាអ្នកជោគជាំខាងក្នុងទៅដោយកិលេសហៅថាស្អុយក្នុង ឬជាការសៅហ្មងខាងក្នុងដែលព្រះធម៌សម្ដែងថាដូចជាសំរាមនោះ គឺមិនសមគួរនៅក្នុងការបរិភោគនូវបច្ច័យ៤នេះឡើយ ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គ លោកសម្ដែងថា ដែលមិនសមគួរក្នុងការបរិភោគនោះ គឺមិនសមគួរសម្រាប់ភិក្ខុអ្នកមានសីល ។ មានសីលហើយតែបរិភោគមិនពិចារណា នេះគឺថាមិនសមគួរក្នុងការបរិភោគទេ ហ្នឹងគឺសម្រាប់បព្វជិតមានសីលផងដែលមិនសមគួរក្នុងការបរិភោគ ព្រោះមិនពិចារណានូវបច្ច័យ៤ ហើយក៏ចេះតែបរិភោគប្រើប្រាស់ទៅ ហើយលោកបានពន្យល់ថា ដល់ទៅភិក្ខុនោះឯងទ្រុស្តសីល គឺថាមិនចាំបាច់និយាយដល់ឡើយ ពីព្រោះតែភិក្ខុមានសីលផងក៏ឈ្មោះថាមិនសមគួរក្នុងការបរិភោគ ព្រោះមិនពិចារ-ណា ព្រោះតែបរិភោគទៅវានាំឱ្យជំពាក់បំណុល ពាក្យថាជំពាក់បំណុលហ្នឹងគឺបានសេចក្ដីថា ញ៉ាំងនូវទក្ខិណាវិសុទ្ធិនេះឱ្យបានសម្រេចតែម្ខាង គឺសម្រេចតែចំពោះទាយកទាយិកាដែលជាអ្នកបានធ្វើទាន ឯចំណែកបដិគ្គាហកនោះឯងមិនបានពិចារណា ក៏មិនបានញ៉ាំងទក្ខិណាវិសុទ្ធិហ្នឹងឱ្យសម្រេចទាំងពីរបានទេ មិនបានទៅជា **ឧបតោ** គឺមិនបានសម្រេចទៅទាំងសងខាង នេះគឺជំពាក់បំណុលនៅក្នុង

ទក្ខិណាវិសុទ្ធិមួយ គឺបានបរិសុទ្ធតែខាងអ្នកឱ្យ ឯអ្នកទទួលមិនបរិសុទ្ធព្រោះមិនពិចារណា គឺជំពាក់បំណុលត្រង់កន្លែងហ្នឹង ត្រង់ដែលមិនបានញ៉ាំងទក្ខិណាវិសុទ្ធិឱ្យប្រព្រឹត្តទៅទាំងសងខាង ។ ប៉ុន្តែបើចូលនៅក្នុងការបរិភោគដោយអំណាចការដែលទ្រុស្តសីលឈ្មោះថា **ថេយ្យបរិភោគ** គឺបរិភោគលួចនូវរបស់អ្នកមានសីល ពីព្រោះព្រះអង្គអនុញ្ញាតបច្ច័យ៤គឺសម្រាប់បព្វជិតអ្នកមានសីល ហើយដែលទាយកទាយិកាអ្នកធ្វើក៏សំដៅយកបព្វជិតអ្នកមានសីលផងដែរ ។ ដូច្នេះកាលណាបើទ្រុស្តសីលហើយនោះ មិនចាំបាច់និយាយ ថាមិនគួរនោះទេ គឺបានសេចក្ដីថាវាទៅជាអ្នកលួចអាហារ បរិភោគភោជនរបស់អ្នកមានសីលហើយ ។

ចំពោះសេចក្ដីនេះព្រះករុណាគុណម្ចាស់ ក៏អាចនឹងបានជ្រាបណាស់ហើយ គ្រាន់តែខ្ញុំព្រះករុណាខ្ញុំបាទចង់ពន្យល់ញាតិញោមបងប្អូន ឱ្យយល់អំពីធម៌ដែលប្រព្រឹត្តទៅបដិបត្តិទៅមិនខុស ត្រង់ដែលថា **ភោជនេ មត្តញ្ញុតា** ការ

ស្គាល់ប្រមាណក្នុងភោជននេះ ក៏សម្រាប់ឧបាសកឧបាសិកាយើងផងដែរ ដើម្បីឱ្យយើងបានពិចារណាទៅតាមព្រះពុទ្ធ-ដីកាដែលព្រះអង្គទ្រង់បញ្ញត្តិនូវព្រះវិន័យ ហើយព្រះអង្គទ្រង់ត្រាស់សម្តែងព្រះធម៌ហ្នឹង តើស្របគ្នាយ៉ាងណា?

នៅក្នុងសេចក្តីនេះគឺព្រះអង្គសម្តែងឱ្យស្គាល់ប្រមាណក្នុងការបរិភោគគឺយើងអាចជ្រាបហើយ តើប្រយោជន៍នៃការបរិភោគហ្នឹងកំណត់ដឹងថា ត្រឹមតែជាអាហារប្បច្ច័យយ៉ាងណា? យើងមិនមែនបរិភោគដើម្បីរស់ ហើយរស់ហ្នឹងមិនដើម្បីបានអ្វីៗក្នុងលោកនេះទេ ញាតិញោមបងប្អូនអាចដើម្បីថា បានមាសប្រាក់លុយកាក់ពិតប្រាកដទេ? តើអាចបានពិតប្រាកដទេ? មិនពិតប្រាកដទេ គឺគ្រាន់តែជាការលួងលោមចិត្តរបស់យើងមួយពេលមួយគ្រា ឱ្យជាប់ជំពាក់ក្នុងភព បើមិនប្រញ៉ាប់រួតរះរកផ្លូវរត់ចេញទេ តាមពិតតើបានឬមិនបាន? ឬក៏ត្រូវចោលក្នុងលោកនេះ? ត្រូវចោលមាសប្រាក់លុយកាក់បុត្រភរិយាស្វាមី គោក្របីដីរីសេះ ផ្ទះសម្បែង បុណ្យសក្តិ យានយន្ត ឫទ្ធិអំណាចអីទាំងអស់

តើត្រូវចោលពិតប្រាកដទេ? ពិតជាចោលហើយ ប៉ុន្តែធ្វើឱ្យយើងមានការវង្វេងភ្លេច ធ្វើឱ្យយើងស្រវឹងនៅក្នុងរបស់ទាំងអស់ហ្នឹងថា អឺ!របស់អញហើយ អឺ!របស់យើងហើយ យើងសប្បាយណាស់ យើងរីករាយណាស់ ហើយដល់តែ អឺ!របស់អញហើយ អឺ!របស់យើងហើយ សប្បាយរីករាយអ៊ីចឹង តើរកផ្លូវរត់ទេ? គឺអត់រត់ទេ នេះឈ្មោះថាយើងនៅជាមួយខ្មាំងសត្រូវហើយ បើយើងសប្បាយនឹងអាហារភោជនរបស់ខ្មាំងសត្រូវថា អឺ!ឆ្ងាញ់ណាស់ៗ សុខស្រួលណាស់ សប្បាយណាស់អ៊ីចឹង តើអាចរត់ចេញពីសត្រូវបានទេ? អត់ទេ ហើយបើយើងរស់នៅជាមួយសត្រូវអ៊ីចឹង តើអាចប្រព្រឹត្តទៅជាសុខឬជាទុក្ខ? ជាទុក្ខ ព្រោះសត្រូវនឹងបៀតបៀនយើង ។ ដូច្នេះអាហារភោជនផ្ទះសម្បែងទីកន្លែងរបស់សត្រូវហ្នឹង វាគ្រាន់តែលួងលោមយើងឱ្យនៅជាមួយដើម្បីថាកុំឱ្យយើងគិតរកផ្លូវរត់ចេញ តែសត្រូវនឹងចាប់យើងជាខ្មាំង នឹងព្យាបាទ នឹងបៀតបៀន នឹងធ្វើ

ទារុណកម្ម ឬប្រើយើងនោះយ៉ាងណាៗ ឱ្យយើងហ្នឹងឯង ជាទាសៈរបស់សត្រូវ ។

ខន្ធបញ្ចកៈ(ខន្ធ៥)នេះវាជាសត្រូវ ជាឃាតករ ជាអ្នកសម្លាប់ សូមកុំភ្លេចឱ្យសោះព្រោះការកើតឡើងនៃរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ គឺជាការកើតឡើងនៃឃាតករ សត្វទាំងឡាយរមែងស្លាប់ ឬសត្វណាដែលត្រូវស្លាប់ក៏មានដែរ ព្រោះអំណាចបញ្ចក្ខន្ធ(ខន្ធ៥)កើតឡើង ដូច្នេះព្រះករុណាគុណម្ចាស់ញាតិញោម ពិចារណាដោយសេចក្តីស្ងប់រំងាប់នៃចិត្តហើយមានសតិសម្បជញ្ញៈដោយល្អ តើការដែលយើងបរិភោគអាហារដើម្បីរស់សព្វថ្ងៃហ្នឹង តើ យើងរស់ដើម្បីបានអ្វី? ក្រៅតែអំពីរឿងការដែលយើងវង្វេង ការដែលយើងមិនមានយោនិសោមនសិការដោយល្អ ពិចារណាឱ្យឃើញបញ្ចក្ខន្ធតាមសេចក្តីពិត ។ តាមពិតអាស្រ័យអយោនិសោមនសិការហ្នឹងឯង ដែលធ្វើឱ្យយើងគិតថាយើងបាននេះយើងបាននោះ ។ យើងរស់នៅបានលាភបានយស បានសរសើរបានការរាប់អាន បានសេចក្តី

សុខ ឬអាចដើម្បីបាននូវអ្វីៗជាកាមគុណ ដែលជាទីពេញចិត្តដោយប្រការណាៗនោះ យើងតែងតែគិតថាយើងបាន តែឥឡូវយើងផ្ទង់ស្មារតីពិចារណាមើល តើយើងអាចបានអ្វីពិតប្រាកដទេ? ឬចាំបាច់ត្រូវតែលះបង់នូវរបស់ទាំងអស់នោះ? នៅក្នុងជីវិតយើងនេះ តើយើងអាចបានអ្វីទេ សព្វថ្ងៃដែលយើងកំពុងថាជារបស់យើងៗហ្នឹង? តើពិតប្រាកដជារបស់យើងមែនទេ? តើយើងត្រូវលះបង់ចោលទៅទាំងអស់មែនទេ? ទាំងដែលកំពុងព្រាត់ប្រាសទៅជានិច្ច រាល់ដង្ហើមចេញចូល រាល់ការបើកភ្នែកនិងបិទភ្នែកនេះក៏កំពុងតែព្រាត់ប្រាសទៅដែរ ។ យើងអាចបានទ្រព្យសម្បត្តិ ដែលមានសព្វថ្ងៃជារបស់យើងមែនទេ?មិនចាំបាច់និយាយរបស់ខាងក្រៅទេ រូបនេះយើងអាចបានជារបស់យើងទេ? ឬក៏ត្រូវបែកធ្លាយចោលទៅក្នុងលោកនេះ? វេទនាជាសុខជាទុក្ខដែលកំពុងមាននេះ តើជារបស់យើងឬក៏ត្រូវជារបស់ដែលត្រូវរលត់ក្នុងលោកនេះ? សញ្ញា សង្ខារ វិញ្ញាណ ត្រូវចោលក្នុងលោកនេះ តើមែនទេ? គឺពិតមែនហើយ

បើអ៊ីចឹងការដែលយើងបរិភោគអាហារដើម្បីរស់សព្វថ្ងៃនេះ តើយើងរស់ដើម្បីបានអ្វី? យើងរកនឹកបន្តិទៅមើល តើយើងខំប្រឹងបរិភោគដើម្បីរស់ ឬប្រើប្រាស់បច្ច័យ៤ទាំងអស់ដើម្បីរស់នេះ តើយើងរស់ដើម្បីបានអ្វី? ទាំងអស់នេះមិនមែនថាមិនឱ្យបរិភោគនោះទេ ប៉ុន្តែដែលព្រះអង្គទ្រង់ត្រាស់សម្តែងឱ្យពិចារណានូវបច្ច័យ៤នេះ គឺការបរិភោគហ្នឹងដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ គឺដើម្បីចម្រើននូវបញ្ញាទីបំផុតព្រះសម្មាសម្ពុទ្ធដែលព្រះអង្គទ្រង់ត្រាស់ថា **បញ្ញាជីវី មាហុសេដ្ឋំ** ជីវិតនៃបុគ្គលណាដែលរស់នៅប្រកបដោយបញ្ញាទើបជាជីវិតប្រសើរ ទើបជាការរស់នៅដ៏ប្រសើរ គឺប្រសើរត្រង់ដែលថា មានបញ្ញាពិចារណាឃើញរូបនេះមិនមែនជាខ្លួនយើង វេទនាមិនមែនជាខ្លួនយើង សញ្ញាមិនមែនជាខ្លួនយើង សង្ខារទាំងឡាយនេះមិនមែនជាខ្លួនយើង វិញ្ញាណមិនមែនជាខ្លួនយើង ហើយថែមទាំង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះជាសត្រូវ គឺជាអ្នកធ្វើទារុណកម្ម និងជាអ្នកសម្លាប់ទៀតផង ។

រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នេះកំពុងភ្លើងជរា ព្យាធិ *មរណៈ* ឆាបឆេះសន្ធោសន្ធៅ តើមែនទេ? ភ្លើងជរា ព្យាធិ *មរណៈ* កំពុងឆេះមែនទេ? គឺពិតមែនហើយ ដូច្នេះវាមានអានិសង្សរបស់បញ្ចក្ខន្ធនេះឯងដែលនាំឱ្យសត្វលោកសប្បាយរីករាយ គឺមានសុខសោមនស្សគ្រាន់តែជាគ្រឿងចាប់សត្វលោកទុកឱ្យឆេះនៅក្នុងភ្លើងជរាព្យាធិ មរណ ដោយមិនរូតរះរកផ្លូវដើម្បីរត់គេចចេញតែប៉ុណ្ណោះ ដូចនេះព្រះករុណាគុណម្ចាស់កាលណាបើស្គាល់ដោយល្អ ការបរិភោគប្រើប្រាស់នូវបច្ច័យ៤ ឬក៏ដូចជាការបរិភោគនូវអាហារបិណ្ឌបាតនេះ ដែលហៅថា **ភោជនេមត្តញ្ញុតា** ការស្គាល់ប្រមាណក្នុងការបរិភោគហ្នឹងគឺបរិភោគដើម្បីរស់ពិតមែនហើយ តែរស់នេះដើម្បីរកផ្លូវរត់ចេញអំពីបញ្ចក្ខន្ធដែលជាខ្មាំងសត្រូវ តើមែនទេ? យើងនៅជាមួយខ្មាំងសត្រូវដែលសត្រូវចាប់បាន យើងមិនមែនមិនបរិភោគទេ តែបរិភោគបាយទឹកនំចំណីរបស់ខ្មាំងដែលឱ្យមកនោះ ដែលសត្រូវឱ្យមកនោះ មិនមែនដើម្បីឆ្ងាញ់ទេ

តើមែនទេ? មិនមែនដើម្បីសប្បាយរីករាយនៅជាមួយខ្មាំងសត្រូវទេ ប៉ុន្តែបរិភោគធ្វើអ្វី? គឺដើម្បីរស់ហើយមានឱកាសរកផ្លូវរត់ តើមែនទេ? មិនមែនបរិភោគដោយត្រេកអររីករាយចំពោះអាហារបរិភោគរបស់ខ្មាំងសត្រូវទេ ។ ដូច្នេះអាហារបរិភោគដែលបរិភោគរាល់ថ្ងៃនេះ ដោយសារមានបញ្ចក្ខន្ធ មានការស្រេកឃ្លាន ទើបនាំឱ្យមានការបរិភោគអ៊ីចឹងការបរិភោគនេះឯង វាទាក់ទងតែជាមួយនឹងបញ្ចក្ខន្ធតែប៉ុណ្ណោះ ។ ការបរិភោគនេះគឺបរិភោគដើម្បីនឹងរត់ចេញអំពីបញ្ចក្ខន្ធ ដូចជាដើម្បីរស់ហើយរត់ចេញអំពីខ្មាំងសត្រូវអ៊ីចឹង ។

ចំពោះការបរិភោគដ៏ប្រសើរនៅក្នុងព្រះសាសនានេះ តើបរិភោគដើម្បីអ្វី? ដើម្បីចម្រើនបញ្ញារំលត់សក្កាយទិដ្ឋិនេះគឺជាចម្លើយយ៉ាងខ្លី ។ បរិភោគដើម្បីរស់ ហើយរស់ហ្នឹងដើម្បីចម្រើនបញ្ញារំលត់សក្កាយទិដ្ឋិ បើមិនរំលត់សក្កាយទិដ្ឋិទេឈ្មោះថានៅក្នុងអំណាចឃាតករ អំណាចខ្មាំងសត្រូវជាអ្នកសម្លាប់ដដែល ព្រោះតែការជាប់ជំពាក់ជា

មួយ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ប៉ុន្តែការបរិភោគ ដើម្បីរស់ ហើយរស់ដើម្បីចម្រើនបញ្ញាវំលត់សកាយទិដ្ឋិ ។ កាលដែលរំលត់សកាយទិដ្ឋិបានហើយ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណហ្នឹងឯងជាអ្នកប្រើប្រាស់ទៅ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាអ្នកបែកធ្លាយទៅ ។ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្តរមែងមិនបានកើតឡើងឡើយ ដោយមិនមានសេចក្តីត្រិះរិះថា រូបអញប្រើប្រាស់ហើយ រូបអញនឹងវិនាសហើយ រូបអញសាបសូន្យហើយ វេទនា សញ្ញា សង្ខារ វិញ្ញាណ អញហ្នឹងប្រែប្រួលហើយ វិនាសហើយដូច្នេះឡើយ ព្រោះហេតុតែរំលត់នូវសេចក្តីប្រកាន់ក្នុងបញ្ចក្ខន្ធ ។ ចំពោះការបរិភោគដែលព្រះអង្គទ្រង់ពុទ្ធា-នុញ្ញាតឱ្យបព្វជិតជាដើម បរិភោគប្រើប្រាស់នូវបច្ច័យ៤ គឺ ដើម្បីរត់ចេញពីបញ្ចក្ខន្ធតែប៉ុណ្ណោះ នេះឈ្មោះថាអនុគ្រោះ ដល់ព្រហ្មចរិយធម៌ ។

យើងនឹងបានសិក្សាដោយល្អនៅក្នុងធម៌ ដែលយើងបានកត់សរសេរមកហើយនេះ ខ្ញុំព្រះករុណាខ្ញុំបាទនឹងបែរវិលត្រឡប់ពន្យល់ន័យសេចក្ដីយ៉ាងណា។ ព្រះករុណាគុណម្ចាស់ញាតិញោមនឹងបានសិក្សាដោយល្អ ចំពោះព្រះធម៌ដែលយើងបានសិក្សាហើយនេះ ។

សូមអនុមោទនាព្រះធម៌!...

សម្ដែងដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**

# ការពិចារណាបច្ច័យ៤
# ក្នុងការបរិភោគប្រើប្រាស់ប្រចាំថ្ងៃ

នៅក្នុងបច្ច័យ៤នេះ ចំពោះបព្វជិតសមគួរនឹងពិចារណាណាស់ហើយ មានចីវរប្បច្ច័យជាដើម ក៏ប៉ុន្តែចំណែកឧបាសកឧបាសិកា ក៏គួរដល់ការពិចារណាផងដែរ ព្រោះអ្វីបានជាគួរដល់ការពិចារណា? ពីព្រោះសុទ្ធតែជាពុទ្ធបរិស័ទបានសិក្សាបដិបត្តិតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ហើយអាស្រ័យឧបនិស្ស័យនៃការសិក្សាបដិបត្តិនោះ ក៏មានចិត្តបង្អោនទៅដើម្បីនឿយណាយនឹងជាតិកំណើត នឿយណាយនឹងវដ្តសង្សារ ដែលនាំមកនូវសេចក្តីទុក្ខរឿយៗ មានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ។ កាលណាបើមានចិត្តបង្អោនទៅកាន់ព្រះនិព្វានដូចដែលឧបនិស្ស័យរុញច្រានមកសម្រាប់ពុទ្ធបរិស័ទអីចឹង

គឺពុទ្ធបរិស័ទហ្នឹងសមគួរនឹង កំណត់ដឹងចំពោះបច្ច័យ៤

មានសំពត់ខោអាវដែលស្លៀក
ពាក់ឬក៏អាហារបរិភោគប្រចាំថ្ងៃនេះ ដើម្បីនឹងពិចារណា
ក្នុងការបរិភោគប្រើប្រាស់ កុំឱ្យវាមានការវង្វេងជាប់ជំពាក់
ភ្លេចស្មារតី ។ ការពិចារណាហ្នឹងជាឧបការនាំឱ្យមាន
ព្រហ្មចរិយធម៌នឹងធឹងល្អ និងជាឧបការដល់សតិប្បដ្ឋាន
បដិបត្តិទៀតផង ពីព្រោះតែកាលណាមានចិត្តបង្អោនទៅ
ដើម្បីព្រះនិព្វាន ហើយពិចារណាបច្ច័យ៤ក្នុងការបរិភោគ
ប្រើប្រាស់ ជាឧបនិស្សយប្បច្ច័យមួយឱ្យមានសតិរលឹក
ព្រោះសតិថ្នាក់សតិប្បដ្ឋាននេះ ប្រៀបបីដូចជាដំណើរដែល
ដើរទៅកាន់ព្រះនិព្វាន ។ កាលណាបើនឹករលឹកឃើញ
ទិសដៅដែលត្រូវទៅ ក៏ញ៉ាំងការកម្រើកជើងហ្នឹងឱ្យដើរ
ទៅគឺឱ្យដើរទៅកាន់ទិសដៅ ។ ដូច្នេះការពិចារណា
បច្ច័យ៤នេះ គឺជាការនឹករលឹកឃើញដល់ទិសដៅដែលត្រូវ
ទៅ មិនមែនត្រូវជំអក់នៅក្នុងភពជាតិកំណើត ឬថាជាការ
ជំអក់នៅជាមួយឧបាទានក្ខន្ធ ដែលតែងតែប្រើប្រាស់បច្ច័យ
៤ជានិច្ចកាលរាល់ថ្ងៃនោះទេ មិនមែនជំអក់នៅជាមួយនឹង

ឧបាទានក្ខន្ធដែលជាខ្មាំងសត្រូវនោះទេ គឺត្រូវតែបង្អោនចិត្ត ទៅកាន់ទិសដៅ ។ ទិសដៅដែលត្រូវទៅគឺការរួចផុតអំពី បញ្ចក្ខន្ធ កាលណាបើបង្អោនចិត្តទៅអ៊ីចឹង ពិចារណាបច្ច័យ ៤ក្នុងការបរិភោគប្រើប្រាស់ ក៏ជាឧបការឱ្យមានសតិរលឹក រូបធម៌និងនាមធម៌ ដែលជាដំណើរជើងដែលត្រូវដើរចេញ អំពីបញ្ចក្ខន្ធ គឺការរំលត់សេចក្តីប្រកាន់ ។

## ការពិចារណាចីវរបច្ច័យឬសំលៀកបំពាក់

បើជាឧបាសកឧបាសិកាក៏ជាសំលៀកបំពាក់ សំពត់ ខោអាវដែលប្រើប្រាស់ប្រចាំថ្ងៃនេះ ហើយសមគួរដល់ការ ពិចារណាដើម្បីកម្ចាត់បង់នូវសេចក្តីស្រវឹង ក្នុងការស្លៀក ពាក់ ព្រោះកាលណាបើមិនបានពិចារណាទេនោះ ហ្នឹងជា ធម្មតាក៏មាន ការប្រព្រឹត្តទៅនៅក្នុងវដ្ត ជាប់ជំពាក់ជាមួយ នឹងឧបាទានក្ខន្ធដោយមានសេចក្តីប្រកាន់ថា ខ្លួនអញហ្នឹង ឯងចាំបាច់ត្រូវតែស្លៀកពាក់ឱ្យស្អាតឱ្យល្អ ឱ្យឆើតឆាយឱ្យ

សង្ខារ ហើយក៏អាចដើម្បីមានទោស កាលណាបើមានចិត្ត បង្អោនទៅដើម្បីឱ្យអ្នកដទៃហ្នឹងឯង មានការវង្វេងភ្លេចស្មារតីនោះ ។ បុរសស្ត្រីដែលស្លៀកពាក់ហ៊ុំហាដោយសេចក្ដីជាប់ជំពាក់នឹងខ្លួនឯងនេះវាជាសញ្ញោជន គឺជាសញ្ញោជនរបស់ខ្លួន នេះប្រការមួយ ហើយបើមានចិត្តប្រព្រឹត្តទៅដើម្បីឱ្យអ្នកដទៃហ្នឹងឯង វង្វេងភ្លេចស្មារតីស្រវឹងនឹងរូបខ្លួនដែលប្រដាប់ទៅដោយអាភរណសព្វគ្រប់ សំលៀកបំពាក់គ្រឿងអលង្ការ
ឈ្មោះថាមានចេតនាញ៉ាំងសញ្ញោជនរបស់
អ្នកដទៃយ៉ាងច្រើននោះឯងឱ្យចម្រើនឡើង គឺថាមានទោសហើយ មានបាបហើយ ។

កាលណាបើមានចេតនាធ្វើឱ្យអ្នកដទៃវង្វេង ដោយសារការតាក់តែងរូបរាងកាយរបស់ខ្លួនគឺជាបាប មានកម្មពៀរវេរាហើយមានបាបទៀត ។ ការមានបាបនេះមិនមែនមានតែបាបល្មមធម្មតាទេ គឺអាចញ៉ាំងអកុសលវិបាកឱ្យ

បដិសន្ធិក្នុងនរកបាន ។ ដូច្នេះយើងត្រូវតែពិចារណានូវចីវរបច្ច័យឬសំលៀកបំពាក់ដើម្បីឱ្យបានសមរម្យផងដែរ ។

**ចំពោះចីវរបច្ច័យឬសំលៀកបំពាក់នេះមាន៤ចំណុចគឺៈ**

✍ **យាវទេវ** មានប្រមាណត្រឹមតែ (នេះជាពាក្យកំណត់ព្រំដែននៃប្រយោជន៍ក្នុងការបរិភោគប្រើប្រាស់) ។

**១-សីតស្ស បដិឃាតាយ** ដើម្បីការពារនូវត្រជាក់ ។

នេះជាប្រយោជន៍ ហើយក៏យើងផ្ទៀងផ្ទាត់មើលដែរ នៅពេលដែលញាតិញោមពាក់ខោអាវក្រាស់ៗ ឬអាវរងារ តើមានគំនិតគិតថាដើម្បីការពារនូវអាកាសធាតុត្រជាក់ដែរទេ? ដូចជារដូវរងារ ឬក៏ដូចជានៅស្រុកដទៃទៀតដែលត្រជាក់ជាងស្រុកខ្មែរយើង គឺអាវក្រាស់អាវរងារសម្រាប់ពាក់ការពាររងារ តើនៅក្នុងបំណងដើម្បីថាការពារនូវសម្ផស្សត្រជាក់ ឬអាកាសធាតុត្រជាក់តែប៉ុណ្ណឹងឬក៏គិតថាដើម្បីឱ្យវាស្អាតក្នុងការពាក់អាវរងារហ្នឹងដែរ? នេះក៏ជាការដែលយើងសិក្សាឃើញដល់លោភមូលចិត្ត ដែលវាកើត

ឡើងហួសការកំណត់ព្រំដែននៃប្រយោជន៍ នៅក្នុងការប្រើប្រាស់ ។ ជួនកាលក៏ឱ្យវាសង្ហារបត្តិចទៅ ឬក៏ថាវាមានតម្លៃយ៉ាងណាក៏ដើម្បីបញ្ជាក់ប្រាប់អ្នកដទៃថា ខ្លួនហ្នឹងក៏ជាអ្នកមាន នេះសុទ្ធតែកំណត់ព្រំដែនហួស មិនបានត្រឹមតែថាការពារនូវសម្ពស្សត្រជាក់ ទាំងនេះសម្រាប់ឃរាវាសអ្នកគ្រប់គ្រងផ្ទះ មិនងាយអីនឹងមានស្មារតីទប់ទល់ជាមួយនឹងកិលេសរបៀបទាំងអស់ហ្នឹងបានទេ ថែមទាំងមិនបានដឹងថាវាជាបាប វាជាអកុសលទៀតផង ព្រោះដឹងរឿងរ៉ាវរបស់បាបអកុសលហ្នឹងវាទាល់តែទៅបៀតបៀនគេ ឬទៅកេង-ប្រវ័ញ្ចគេ ទៅឆបោកគេ ទៅជេរប្រទេចគេជាដើមអីចឹងទៅទើបបានស្គាល់ថាជាបាបជាអកុសល តែត្រង់កិលេសដែលវាកើតឡើងដូចជាចង់ស្អាត ចង់ឱ្យវាឆើតឆាយខ្លួនឯង ឬក៏មានស្មារតីដើម្បីចង់ឱ្យអ្នកដទៃហ្នឹងឯងស្រវឹងវង្វេងភ្លេចសតិអីហ្នឹងយ៉ាងណា មិនដឹងថាទាំងហ្នឹងគឺជាបាប ជាអកុសលនោះទេ ប៉ុន្តែសេចក្តីនេះសម្រាប់បព្វជិតដែលមានការសិក្សាថ្នាក់ខ្ពស់ ពិចារណាបានច្រើនសព្វគ្រប់ទាំងអស់

ព្រោះកិច្ចការដែលប្រើប្រាស់នូវបច្ច័យ៤នេះ បព្វជិតមិនអាចប្រមាទធ្វេសប្រហែសបានទេ មកអំពីអ្វី? មកអំពីអ្វីៗទាំងអស់គឺត្រូវបានទទួលអំពីព្រះសម្មាសម្ពុទ្ធជាអម្ចាស់ដែលព្រះអង្គទ្រង់ព្រះពុទ្ធានុញ្ញាតនូវបច្ច័៤នេះឯងដើម្បីឱ្យបព្វជិតជាអ្នកបរិភោគប្រើប្រាស់ ។ បព្វជិតជាអ្នកមានសីលបរិភោគប្រើប្រាស់នូវបច្ច័យ៤ ដោយមានការពិចារណាឈ្មោះថា **ទាយជ្ជបរិភោគ** ។ ចំពោះបុថុជ្ជនអ្នកមានសីលដែលបានបរិភោគប្រើប្រាស់ដោយការពិចារណាយ៉ាងត្រឹមត្រូវ រួមជាមួយនឹងព្រះសេក្ខបុគ្គលឈ្មោះថា **ទាយជ្ជបរិភោគ** គឺបរិភោគនូវបច្ច័យ៤ដែលជាមរតករបស់ព្រះសម្មាសម្ពុទ្ធ ។ ពិតមែនតែឧបាសកឧបាសិកាញាតិញោមជាអ្នកប្រគេនដល់បព្វជិតភិក្ខុសាមណេរ ក៏ប៉ុន្តែរាល់ពេលដែលបព្វជិតបរិ-ភោគប្រើប្រាស់តែងសម្គាល់ថា នេះគឺជាមរតករបស់ព្រះពុទ្ធដោយសារព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ព្រះពុទ្ធានុញ្ញាតឱ្យបរិភោគប្រើប្រាស់នូវរបស់ដែលជា **កប្បិយៈ** របស់គួរទៅតាមព្រះធម៌ព្រះវិន័យ ។ ដូច្នេះគឺថាជាមរតករបស់ព្រះពុទ្ធ

ក្នុងការបរិភោគយ៉ាងនេះ មិនអាចធ្វេសប្រហែសបានទេ ត្រូវកំណត់ព្រំដែននៃប្រយោជន៍ ។ តាមពិតនោះក៏សម្រាប់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ ញាញោមបងប្អូនពុទ្ធបរិស័ទយើងម្នាក់ៗគ្រប់ៗគ្នាក្នុងសេចក្ដីដែលថា ជាអ្នកមិនត្រេកអរជាមួយនឹងឧបាទានក្ខន្ធទុក្ខ ។ ឧបាទានក្ខន្ធទុក្ខនេះដូចជាចោរ ដូចជាខ្មាំងសត្រូវ បានដល់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះឯងដែលបានសន្មត់ថាជាខ្លួនយើងម្នាក់ៗគ្រប់ៗគ្នាហ្នឹងឯង ។ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះ តើជាកន្លែងសុខឬជាកន្លែងទុក្ខ? ហ្នឹងគឺយើងអាចឆ្លើយបានហើយ គ្រាន់តែថាញ៉ាំងស្មារតីសម្បជញ្ញៈឱ្យមានការប្រព្រឹត្តទៅកំណត់ដឹងជាក់លាក់ប្រាកដថាវាជាទុក្ខមែន វាជាកន្លែងបៀតបៀន កន្លែងធ្វើទារុណកម្ម ព្រោះជរាក្ដី ព្យាធិក្ដី មរណក្ដី សេចក្ដីសោកក្ដី សេចក្ដីខ្សឹកខ្សួលក្ដី សេចក្ដីទុក្ខទោមនស្សក្ដីសព្វគ្រប់ទាំងអស់ គឺរមែងមាននៅក្នុងឧបា-ទានក្ខន្ធនេះហើយ ។ ឧបាទានក្ខន្ធនេះត្រូវភ្លើងកំពុងឆេះទេ? យើងទាំងអស់គ្នាពិចារណាមើល ដែលសន្មត់ថាជា

យើងម្នាក់ៗហ្នឹង តើមានសត្វបុគ្គលអ្វីជទៃអំពីបញ្ចក្ខន្ធទេ? អត់ទេ ហើយបញ្ចក្ខន្ធនេះភ្លើងកំពុងឆេះទេ? តើភ្លើងអ្វី? គឺភ្លើងជរា ភ្លើងព្យាធិ ភ្លើងមរណៈ ហើយថែមភ្លើងកិលេសផងទៀតទេ? ថែមទៀត ។ ឥឡូវយើងគិតថា ដោយទូទៅទោះជាថាបុគ្គលហ្នឹងមានកិលេសក្តី អស់កិលេសក្តី តែចំពោះរូបដែលភ្លើងកំពុងឆេះ គឺភ្លើងជរា ព្យាធិ មរណៈ និងវេទនា សញ្ញា សង្ខារ វិញ្ញាណ ត្រូវភ្លើងជរា ព្យាធិ មរណៈកំពុងឆេះសន្ធោសន្ធៅ ។ ឥឡូវឧបមាថាយើងមានផ្ទះស្បូវ ឬក៏ផ្ទះឈើមួយខ្នង ហើយដែលភ្លើងកំពុងឆេះ មិនមានសមត្ថភាពអាចនឹងពន្លត់ភ្លើងនោះទេ ប៉ុន្តែយើងគ្រាន់តែរត់ចេញអំពីផ្ទះដែលត្រូវភ្លើងឆេះហ្នឹងមក ហើយយើងឈរសម្លឹងមើលភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ យើងមានគិតថានៅជាផ្ទះរបស់យើងទៀតទេ? បន្តិចទៀតដែលភ្លើងឆេះអស់ទៅមាននៅជាផ្ទះរបស់យើងដើម្បីនឹងរស់នៅជ្រកកោនបានដូចមុនទៀតទេ? អត់ទេ គឺកន្លះម៉ោង ឬមួយម៉ោងទៀតហ្នឹងគឺត្រូវឆេះអស់ នៅសល់តែផេះ នៅ

សល់តែធ្យូង តើអ៊ីចឹងមែនទេ? ប៉ុន្តែពេលហ្នឹងមិនទាន់ឆេះអស់ទេគឺកំពុងតែឆេះរាលដល់ដំបូលហើយ តើយើងមានគិតថានៅសល់ជាផ្ទះយើងទេ? អត់ទេ វានឹងអស់ទៅដែលហៅថាជាចំណីភ្លើង តើអ៊ីចឹងមែនទេ? ដូចនេះបញ្ចក្ខន្ធដែលភ្លើងកំពុងឆេះហ្នឹង យើងមានគិតថានៅជារបស់យើងទៀតទេ? នឹងបានជារបស់យើងទៀតទេ? នេះដែលយើងត្រូវពិចារណាអ៊ីចឹង ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពិចារណា ហើយព្រះអង្គទ្រង់បានជ្រាបច្បាស់ហើយ ទ្រង់ត្រាស់សម្តែងឱ្យយើងហ្នឹងឯងពិចារណានូវភ្លើងពាកងនេះឱ្យបានរឿយៗ គឺជរា ព្យាធិ មរណ ប្រសិនបើអត់មានភ្លើងហ្នឹងទេ ក៏ព្រះសម្មាសម្ពុទ្ធអត់បានត្រាស់ដែរ ។ យើងអាចឃើញព្រះសម្មាសម្ពុទ្ធដោយបញ្ញាចក្ខុបាន ដោយសារពិចារណានៅក្នុងជរា ព្យាធិ មរណនេះឯង ពីព្រោះតែដោយសារមានជរាព្យាធិមរណហ្នឹងហើយដែលបៀតបៀននូវសត្វលោក ដែលសត្វលោកហ្នឹងនៅជាប់ជាមួយនឹងបញ្ចក្ខន្ធ ទើបបានមានព្រះសម្មា

សម្ពុទ្ធព្រះអង្គបានត្រាស់ដឹងឡើងនៅក្នុងលោក គឺដោយអាស្រ័យបារមី ដែលព្រះអង្គកសាងបានគ្រប់គ្រាន់មក ។ ដូច្នេះនៅក្នុងសេចក្តីនេះ ព្រះករុណាគុណម្ចាស់ក៏គួរនឹងបានសង្វេគផងដែរ ដូចជាកាលដែលយើងបានចូលកាន់ពិធីបូជាសពមាតាបិតា ឬក៏បូជាសពញាតិកាណា។ នៅពេលដែលយើងបានពិចារណាឱ្យបានច្បាស់លាស់ ក៏យើងបានឃើញថា ភ្លើងដែលកំពុងឆេះនូវសរីរសាកសពនោះគឺមាតាក្តីបិតាក្តី តើយើងមានគិតថាភ្លើងកំពុងឆេះយើងទេ? អត់ទេ គឺដុតអ្នកណាគឺឆេះអ្នកនោះឯង តើអ៊ីចឹងមែនទេ? នេះបើយើងមានឧបនិស្ស័យនៃសតិប្បដ្ឋាន-វិបស្សនា ក៏គង់រួចខ្លួនបាននៅពេលដែលយើងឃើញថា ភ្លើងជរា ភ្លើងព្យាធិ ភ្លើងមរណនេះ មិនមែនភ្លើងហ្នឹងឯងមកអំពីទីដទៃណាទេ គឺភ្លើងហ្នឹងវាកើតចេញអំពីការមាន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណហ្នឹងឯង បើអត់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ តើមានភ្លើងពាកងហ្នឹងទេ? អត់ទេ វាមានភ្លើងហ្នឹងមកពីណា ។ ដូច្នេះដើមភ្លើងដែលជាជរា ព្យាធិ

មរណាហ្នឹងឯង ដែលកំពុងតែឆេះរាលមកដល់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណរហូតបច្ចុប្បន្ននេះ ដោយសារតែវាមាន រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ នេះជាដើមហេតុ ។ បើអត់មានបញ្ចក្ខន្ធទេ ភ្លើងពាកងហ្នឹងក៏អត់រាលមកដែរ ទាំងអស់នេះយើងបានរៀនហើយព្រះគាថារបស់ព្រះ**មនត្តេរ** នោះគឺ **ភ្លើងទាំងពាកងគឺ ជរា ព្យាធិ មរណានេះឯងគឺថាដូច ជាគំនរភ្លើងដែលកំពុងតែឆេះរាលមកកម្លាំងដើម្បីទប់ទល់នឹង ភ្លើងហ្នឹងអត់មានទេ សន្ទុះដើម្បីរត់គេចចេញក៏អត់ដែរ** នេះគឺជាការសម្តែងឱ្យឃើញថាបញ្ចក្ខន្ធត្រូវភ្លើងឆេះ ក៏ប៉ុន្តែការអប់រំចម្រើនសតិប្បដ្ឋាន-វិបស្សនាក៏បានឃើញថាភ្លើងដែលឆេះបញ្ចក្ខន្ធនេះឯង តើឆេះរូបឬក៏ឆេះខ្លួនយើង? គឺឆេះរូប បើសេចក្តីប្រកាន់ក្នុងរូបហ្នឹងឯងមិនមានហើយនោះ ក៏សេចក្តីត្រិះរិះថាភ្លើងហ្នឹងឆេះខ្លួនឯងក៏មិនមានដែរ ប៉ុន្តែតើឆេះអ្វី? គឺឆេះរូប ចុះបើយើងប្រកាន់ថារូបហ្នឹងជាខ្លួនយើង នៅពេលដែលរូបត្រូវភ្លើងជរា ព្យាធិ មរណាឆេះ សេចក្តីត្រិះ

រិះថាអញចាស់ អញឈឺ អញស្លាប់ដែរទេ? គឺប្រកាន់ហើយ ហ្នឹងគឺអ៊ីចឹងឯង កាលណាបើយើងប្រកាន់ថារូបជាខ្លួនយើង នោះ ដល់រូបហ្នឹងឯងប្រែប្រួលទៅ រូបហ្នឹងឯងត្រូវភ្លើង ជរា ព្យាធិ មរណឆាបឆេះក៏រមែងត្រិះរិះថា ខ្លួនអញ ហ្នឹងឯងចាស់ហើយ ខ្លួនអញហ្នឹងឈឺ ខ្លួនអញហ្នឹងស្លាប់ យ៉ាងនេះជាដើម ដូច្នេះសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីទុក្ខទោមនស្សរមែងកើតឡើង នេះជាការកើតឡើង នៃទុក្ខព្រោះសេចក្ដីប្រកាន់ តើអ៊ីចឹងមែនទេ? ទាំងនេះជា ធម៌ដែលយើងត្រូវពិចារណា ។ កាលណាបើយើងអាច ដើម្បីនឹងមានបញ្ញាកំណត់ដឹងនូវរូប វេទនា សញ្ញា សង្ខារ វិញ្ញាណហ្នឹងច្បាស់ ដែលវាមិនមែនជាខ្លួនយើងហើយនោះ ជរា ព្យាធិ មរណនេះក៏ឆេះចំពោះតែបញ្ចក្ខន្ធតែប៉ុណ្ណោះ មិនបានឆេះយើងទេ ដូចនេះយើងអាចរួចអំពីភ្លើងទាំងពា កងហ្នឹងបាន តើដោយអ្វី? ដោយការមិនប្រកាន់បញ្ចក្ខន្ធ តើមែនទេ? គឺមែន ដូចជាអ្វី? ដូចជាយើងបានឃើញភ្លើង ដែលកំពុងឆេះអុស យើងមិនបានគិតថាឆេះយើង ឬដែល

គេបូជាសពអ្នកដទៃ

ភ្លើងដែលកំពុងឆេះក៏យើងមិនបានត្រិះ

រិះថាភ្លើងកំពុងឆេះយើងដែរ ។ យើងមានគិតថាតើភ្លើង កំពុងឆេះរូបអញទេ? អត់ទេ ដូច្នេះយើងអាចរួចផុតអំពី ភ្លើងទាំងពាកងគឺភ្លើងជរា ព្យាធិ មរណហ្នឹងបាន លុះត្រា តែរំលត់សេចក្ដីប្រកាន់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ពីព្រោះភ្លើងទាំងពាកងនេះ មិនអាចឆេះអ្វីដទៃក្រៅតែអំពី បញ្ចក្ខន្ធទេ ព្រោះបញ្ចក្ខន្ធនេះប្រៀបបីដូចជារបស់ដែល សម្រាប់ភ្លើងឆេះមានអុសជាដើម ឬក៏ស្មៅឬក៏ចម្លើង ឬក៏ ប្រេង ឬក៏អ្វីៗដែលសមគួរជាបច្ច័យឱ្យភ្លើងឆេះបាន ប៉ុន្តែ ភ្លើងជរា ព្យាធិ មរណហ្នឹងតើឆេះនិព្វានបានទេ? អត់ទេ មកអំពីអ្វី? មកអំពីនិព្វានប្រាសចាកសង្ខារ ។ ដូច្នេះបើអត់ មានសង្ខារទេ ភ្លើងក៏មិនដឹងជាមានអ្វីឆេះដែរ តើអ៊ីចឹង មែនទេ? អ៊ីចឹងនិព្វានដែលព្រះករុណាគុណម្ចាស់ត្រូវតែ ប្រព្រឹត្តបដិបត្តិឱ្យបានដល់ហ្នឹង តើនៅត្រង់កន្លែងណា? នៅត្រង់រំលត់សេចក្ដីប្រកាន់ថារូបជាខ្លួន គ្រាន់តែជាមហា-

ភូតរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលអាស្រ័យនឹងវត្ថុរូបក្នុងមហាភូតរូបនេះកើតឡើងហើយក៏រលត់ទៅ ជានាមធម៌ ពុំមែនជាសត្វបុគ្គលតួខ្លួនយើងទេ ។ រំលត់នូវសេចក្តីប្រកាន់ ក៏គឺជាការរំលត់នូវសេចក្តីសេចក្តីត្រិះរិះថាខ្លួនយើងហ្នឹងត្រូវភ្លើងឆេះ ។ ការរំលត់នូវសេចក្តីរិះរិះថាខ្លួនយើងត្រូវភ្លើងឆេះ រំលត់នូវសេចក្តីត្រិះរិះថាអាត្មាអញហ្នឹងឯងត្រូវសាបសូន្យហើយ ត្រូវវិនាសហើយ សេចក្តីសោក សេចក្តីខ្សឹកខ្សួលជាដើមតាមផ្លូវចិត្តក៏មិនមានដែរ ។ ទាំងនេះគឺជាការដែលយើងត្រូវពិចារណា ចំពោះបញ្ចក្ខន្ធដើម្បីជាប្រយោជន៍កុំឱ្យមានការដំអក់នៅ ជាប់ជំពាក់នៅប្រកាន់មាំនៅក្នុងបញ្ចក្ខន្ធ មានរូបក្ខន្ធជាដើម ។

ចំពោះការដែលត្រូវប្រើប្រាស់នូវចីវរ ឬក៏សំពត់ខោអាវ បើសិនជាអត់មានរូបតើចាំបាច់ត្រូវប្រើប្រាស់ទេ? អត់ទេ ប៉ុន្តែដល់ទៅមានរូបទៅមិនបានប្រើប្រាស់ គឺនាំឱ្យមានសេចក្តីលំបាក ហើយលំបាកហ្នឹងឥតប្រយោជន៍ទៅទៀត មិនមែនលំបាកហ្នឹងកើតបុណ្យកើតកុសលឯណា គឺលំបាក

ឥតប្រយោជន៍ ពីព្រោះដូចជាក្តៅពេកអ៊ីចឹងទៅយើងក៏ទ្រាំក្តៅក៏វាមិនបានជាចម្រើនប្រយោជន៍ដែរ ពីព្រោះវាមិនមែនជារឿងដែលយើងត្រូវទៅអង្គុយហាលថ្ងៃ ឱ្យកើតបុណ្យងណា បើសិនជាត្រូវកើតបុណ្យនោះ ឧទាហរណ៍ថាយើងត្រូវធ្វើដំណើរទៅបំរើមាតាបិតា ទោះជាហាលថ្ងៃក៏ទៅដែរ ហ្នឹងគឺមកអំពីចេតនាជាបុណ្យកុសល ក្នុងការប្រារព្ធយកមាតាបិតាជាអារម្មណ៍ ឬក៏យើងទៅស្តាប់ព្រះធម៌ទោះជាក្តៅខ្លាំងក៏យើងទៅដែរ ព្រោះការដែលយើងទ្រាំនឹងក្តៅហ្នឹងដោយសារមានការគោរពព្រះធម៌ ប៉ុន្តែបើយើងអត់ប្រារព្ធយកអ្វីជាគុណជាអារម្មណ៍នាំឱ្យកើតកុសលទេ គ្រាន់តែថាឱ្យវាក្តៅចុះឱ្យវាអស់កិលេសដោយសារហាលក្តៅ ឬក៏ឆ្អើរភ្លើងបន្ថែមទៀតទៅ នេះវាមិនអាចប្រព្រឹត្តទៅបានឡើយ វាមិនអាចនាំមកនូវបុណ្យកុសលឬសេចក្តីបរិសុទ្ធទេ ឬក៏ដេកឆ្អើរភ្លើង ឬក៏ខែវរងារហើយចុះត្រាំទឹក ឬក៏សុខចិត្ត ឱ្យរងារទៅ ទ្រាំទៅ ហើយស្រាប់តែវាបាននូវសេចក្តីបរិសុទ្ធ

ឯងៗដោយគ្រាន់តែទ្រាំនឹងរងារនោះ គឺមិនអាចប្រព្រឹត្តទៅបានទេ បើថាយើងហ្នឹងវាចាំបាច់ត្រូវចុះទឹកទៅស្រង់មនុស្សលង់ទឹក នេះចេតនារបស់យើងជាកុសលដើម្បីជួយអ្នកដទៃ សុខចិត្តលំបាក សុខចិត្តរងារដោយប្រការផ្សេងៗ នេះគឺជាបុណ្យជាកុសលក្នុងកិច្ចការងារដែលត្រូវធ្វើ តែបើឱ្យទ្រាំរងារឯងៗដើម្បីសេចក្តីបរិសុទ្ធនោះវាមិនអាចប្រព្រឹត្តទៅបានទេ ដូច្នេះបានជាត្រូវប្រើប្រាស់នូវត្រៃចីវរឬសំលៀកបំពាក់ ប៉ុន្តែវាមានព្រំដែននៃការប្រើប្រាស់ ប្រៀបបីដូចជាថាយើងមានដំបៅនឹងសាច់ ក្នុងការដែលលាបថ្នាំដំបៅឬយកសំពត់រុំដំបៅនោះ គឺមិនមែនដើម្បីបង្អួតសំពត់រុំដំបៅដល់អ្នកដទៃ ឬខ្លួនឯងហ្នឹងត្រេកអរសប្បាយថា បើកុំតែអញមានដំបៅ អញអត់បានមានសំពត់ប៉ុនបាតដៃមកគ្របដំបៅនេះទេ អ៊ីចឹងអញត្រេកអរណាស់ អញអត់ចង់ឱ្យដំបៅជាទេ ព្រោះដំបៅជាទៅអញអត់បានសំពត់ហ្នឹងមករុំដំបៅទៀត តើមានគិតអ៊ីចឹងដែរទេ? អត់ទេ ដែលមានដំបៅហើយបើអត់យកសំពត់មករុំ វានាំឱ្យធូលីចូលទៅវា

ក្រជាសះស្បើយ នាំឱ្យអ្វី១ដូចជាកំទេចថ្ម កំទេចគ្រួស ឬ ក៏មែកឈើវាវែតប៉ះមកត្រូវទៅវានាំឱ្យចេញឈាម វានាំឱ្យ លំបាក អ៊ីចឹងត្រូវយកសំពត់មករុំការពារធូលី និងការពារ នូវសម្ផស្សផ្សេង១ ដូចនេះវាចាំបាច់ត្រូវតែរុំដំបៅ ហ្នឹងគឺ អ៊ីចឹងហើយ ប៉ុន្តែសួរថាតើយើងរុំដំបៅហ្នឹង រុំដើម្បីយើង ត្រេកអរនឹងសំពត់ ត្រេកអរនឹងដំបៅបានជាយើងរុំ ឬក៏រុំ ដើម្បីអ្វី? គឺដើម្បីឱ្យដំបៅជា ។ ចំពោះការស្លៀកពាក់ ហ្នឹងក៏អ៊ីចឹងដែរ ព្រះសម្មាសម្ពុទ្ធបានឱ្យយើងកំណត់ដឹង សំលៀកបំពាក់ដែលយើងស្លៀកពាក់ហ្នឹង គឺដូចជាសំពត់រុំ ដំបៅអ៊ីចឹង មកអំពីអ្វី? មកអំពីបើយើងមិនស្លៀកពាក់ទេ វាក្តៅពេកមិនបាន វាត្រជាក់ពេកមិនបាន សម្ផស្សរបោម មូសខ្យល់សព្វគ្រប់ទាំងអស់ វាមានកាយប្បសាទរូបនេះប៉ះ ខ្ទប់នឹងផោដ្ឋព្វៈ ដូច្នេះត្រូវតែស្លៀកពាក់ ប៉ុន្តែត្រូវកំណត់ ដឹងថាសំលៀកបំពាក់ដែលស្លៀកពាក់នេះ តើដើម្បីអ្វី? គឺ ដើម្បីគ្រាន់តែការពារនូវត្រជាក់ក្តៅជាដើម តែប៉ុណ្ណឹងទេ ។ ដូចយើងកំពុងសិក្សាអំពី **យាវទេវ** ក្នុងការប្រើប្រាស់នូវ

សំលៀកបំពាក់នេះ តើយើងអាចកំណត់ព្រំដែនអ្វីចឹងបាន ទេ? គឺអាចបាន ។

យើងត្រូវពិចារណាថា សំពត់រុំដំបៅនេះគឺមិនមែន ត្រេកអរនឹងដំបៅ ហើយនឹងដើម្បីឱ្យបានសំពត់រុំរហូតតទៅ ទេ យ៉ាងណាមិញមិនមែនត្រេកអរថា អី!អញបានកើតមក អញមានរូបកាយ អញបានស្លៀកពាក់នឹងគេ អញបានល្អ ស្អាត មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរអ៊ីចឹងទេ ។ រូបកាយនេះប្រៀបបីដូចជារោគមួយដុំដែលបានកើតមក វា បីដូចជាដំបៅអ៊ីចឹង ដូចនេះតើយើងពិចារណាយកមួយ ណា? ការដែលនៅមានដំបៅដើម្បីបានរុំដំបៅ ហើយនឹង ជាដំបៅមិនចាំបាច់រុំ តើយើងយកមួយណា? គឺយកជាដំបៅ ការដែលរួចផុតអំពី រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ មិនមានរបស់ដែលនាំឱ្យកង្វល់ មិនមានទុក្ខ មិនមានការ បៀតបៀន រួចផុតអំពីការកាប់សម្លាប់ រួចផុតពីជរា ព្យាធិ មរណ រួចផុតពីខ្មាំងសត្រូវនោះ វាជាបរមសុខដ៏ក្រៃលែង

ដូច្នេះមិនមែនថាយើងមិនស្លៀកពាក់ទេ ប៉ុន្តែការស្លៀកពាក់នេះមានការកំណត់ព្រំដែននៃប្រយោជន៍ ។

**២-ឧណ្ហស្ស បដិឃាតាយ** ដើម្បីការពារនូវកម្ដៅ ។
**៣-ឌំសមកសវាតាតបសិរិសប្ប សម្ផស្សានំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្ស របោមមូសខ្យល់ កម្ដៅថ្ងៃ និងសត្វលូនវារ មានពស់ជាដើម ។
**៤-ហិរិកោបិនប្បដិច្ឆាទនត្ថំ** ជាប្រយោជន៍ដើម្បីបិទបាំងរាងកាយកុំឱ្យមានការអៀនខ្មាស់កើតឡើង ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គក៏មានការប្រើប្រាស់នូវចីវរព្រះបច្ចេកពុទ្ធ ព្រះភិក្ខុសង្ឃក៏មានការប្រើប្រាស់ដែរ មិនមែនដូចពួកអាចេល ពួកមិច្ឆាទិដ្ឋិដែលគេមិនស្លៀកពាក់ដោយគេយល់ឃើញថា កុំឱ្យវាមានការជាប់ជំពាក់ទាក់ទិននឹងគ្រឿងប្រើប្រាស់ទាំងអស់ហ្នឹង ត្រូវមានការលះបង់ឱ្យអស់ទៅ ដោយគេយល់ថាជាការលះបង់នូវកិលេស មិនជាប់ជំពាក់នឹងការប្រើប្រាស់សំលៀកបំពាក់ នេះជាការ

យល់ខុសទេ ពីព្រោះព្រំដែននៃប្រយោជន៍ក្នុងការប្រើប្រាស់នេះគឺប្រព្រឹត្តទៅដើម្បីមិនមានទោស អត់មានទោសអ្វីក្នុងការស្លៀកពាក់ហ្នឹងទេ បើយើងស្លៀកពាក់គ្រាន់តែការពារទី១ត្រជាក់ ទី២កម្ដៅ ទី៣ការពារនូវសម្ផស្សទាំងឡាយ មានរបោមមូសខ្យល់ កម្ដៅថ្ងៃ សត្វពស់តូចពស់ធំ សត្វលូនវារ ហើយនឹងទី៤គឺដើម្បីបិទបាំងរាងកាយតែប៉ុណ្ណឹងឯង ទាំងអស់នេះគឺអត់មានទោសទេ ប្រើប្រាស់ជាវត្ថុបដិបត្តិ គឺគ្រាន់តែជាបរិមណ្ឌល ការស្លៀកពាក់ហ្នឹងឯងឱ្យមានការសមរម្យ កុំឱ្យរយីករយាក កុំឱ្យមានការឆ្គាំឆ្គង នេះជាសុជីវធម៌នៅក្នុងសង្គម និងជាសណ្ដាប់ធ្នាប់ប្រព្រឹត្តទៅឱ្យវាមានការសមរម្យ ចូលជំនុំចំណោមអីហ្នឹងយ៉ាងណា១ ក៏ជាការបង្ហាញដល់មារយាទ សណ្ដាប់ធ្នាប់ល្អ ក៏ជាការគោរពផងដែរដល់អ្នកតូចអ្នកធំអីហ្នឹងយ៉ាងណា១វាអាស្រ័យសំលៀកបំពាក់ ការតុបតែងរាងកាយ ដូច្នេះគឺមិនមានទោសពៃអ្វីទេ ហើយម្យ៉ាងទៀតក៏ដើម្បីជីវិតរស់នៅប្រព្រឹត្តព្រហ្មចរិយធម៌ ។ រឿងដែល

សំខាន់គឺការដែលលះបង់នូវកិលេស នៅត្រង់ការប្រព្រឹត្ត ព្រហ្មចរិយធម៌ទេ មិនមែនដើម្បីលះបង់កិលេសដោយមិន ស្លៀកពាក់នោះគឺអត់មែនទេ អត់មានវិធីឧបាយអ្វីដែលនឹង កម្ចាត់បង់នូវកិលេសដោយការមិនស្លៀកពាក់ឡើយ ។

✍ត្រូវធ្វើទុកក្នុងចិត្តដោយឧបាយយ៉ាងល្អថាអាត្មា អញស្លៀកពាក់នេះ គ្រាន់តែដូចជាសំពត់ឬក្រណាត់រុំដំបៅ តែប៉ុណ្ណោះ ។

## ការពិចារណាបិណ្ឌបាតបច្ច័យ

✍📖✍

មានអង្គ៤ដែលត្រូវរារាំងក្នុងការបរិភោគអាហារគឺ:

**១-នេវ ទវាយ** មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុកជាដើម នេះជាអង្គដើម្បីរារាំងនូវមោហៈ ។

នៅក្នុងលោកនេះតើមានអ្នកបរិភោគដើម្បីលេងទេ ? គឺមាន ។ មិនចំពោះតែកូនក្មេងទេ នេះគ្រាន់តែលើក ឧទាហរណ៍ដែលកូនក្មេងវាបរិភោគដើម្បីលេងនេះ លេង នោះ មានកម្លាំងទៅរត់លេងទៅ ប៉ុន្តែមនុស្សធំៗហើយ

ហ្នឹងក៏មានការបរិភោគដើម្បីលេងដែរ ប៉ុន្តែលេងរបៀបមនុស្សធំ គឺលេងនៅក្នុងកាមគុណទាំងឡាយផ្សេងៗ លេងដោយប្រការណាៗព្រះករុណាគុណម្ចាស់ក៏ពិចារណាជ្រាបហើយ ប៉ុន្តែចំពោះបព្វជិត ឬក៏ពុទ្ធបរិស័ទដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាននោះ គឺមិនមែនបរិភោគដើម្បីលេងទេ ។ ឧទាហរណ៍ដូចជាយើងត្រូវខ្មាំងចាប់បានអ៊ីចឹងក្នុងការដែលបរិភោគចំណីរអាហារបស់ខ្មាំងនេះ គឺបរិភោគអត់មានសប្បាយអត់មានដើម្បីលេងទេ

ប៉ុន្តែថាមិនបរិភោគ វាមិនបាន វាត្រូវស្លាប់ ហើយយើងត្រូវការរត់ចេញពីកន្លែង ខ្មាំង រត់ឱ្យរួចពីកន្លែងសត្រូវ ដូចនេះបរិភោគហ្នឹងតើគ្រាន់តែដើម្បីអ្វី? គឺដើម្បីរស់ ហើយមានកម្លាំងរត់ចេញពីខ្មាំងសត្រូវ សូមមេត្តាកុំភ្លេចចំណុចហ្នឹងផង ។ បញ្ចក្ខន្ធនេះជាខ្មាំងសត្រូវ កន្លែងធ្វើទារុណកម្មសព្វគ្រប់គឺនៅលើបញ្ចក្ខន្ធហ្នឹងហើយ ។ ដូច្នេះដើម្បីរត់ចេញពីបញ្ចក្ខន្ធគឺត្រូវតែមានការបរិភោគនូវអាហារ តែការបរិភោគមិនមែនដើម្បីលេង

ទេ ហើយការរត់ចេញពីខ្នាំងសត្រូវហ្នឹង តើរត់នៅកន្លែងណា? តើនៅកន្លែងណាដែលឈ្មោះថារត់ពីខ្នាំងសត្រូវ? គឺនៅត្រង់រំលត់សកាយទិដ្ឋិ រំលត់សេចក្តីប្រកាន់ថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាខ្លួនយើង នេះឈ្មោះថារត់ ។ បើមិនដើម្បីរំលត់សកាយទិដ្ឋិទេ មិនរំលត់ឆន្ទរាគ គឺសេចក្តីត្រេកអរពេញចិត្តឧបាទានគឺសេចក្តីប្រកាន់ហ្នឹងទេ ផ្លូវដទៃក្រៅអំពីហ្នឹងទៅដល់ណាក៏រត់មិនរួចដែរ តើជ្រាបអ៊ីចឹងទេ? ដូច្នេះដែលអាចរួចអំពីបញ្ចក្ខន្ធបាននោះគឺរំលត់សកាយទិដ្ឋិ ហើយដើម្បីរំលត់សកាយទិដ្ឋិត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ គឺសីល សមាធិ បញ្ញា ការចម្រើនអរិយមគ្គប្រកបដោយអង្គ៨ប្រការ ដូច្នេះដើម្បីនឹងប្រព្រឹត្តនូវព្រហ្មចរិយធម៌បានទាល់តែបរិភោគអាហារ តើមែនទេ? ប៉ុន្តែបរិភោគអាហារហ្នឹងត្រូវកំណត់អង្គ៤ដែលត្រូវរារាំង ដូចដែលយើងបានសរសេរទី១រួចហើយ ដែលជាការរារាំងនូវមោហៈអវិជ្ជា ។ មោហចេតសិកវាវង្វេងដើម្បីលេង ដើម្បីសប្បាយនៅក្នុងជំរុំរបស់ខ្នាំងសត្រូវ បរិភោគដើម្បីជាទាសៈ

នៃសត្រូវគឺបញ្ចក្ខន្ធ បរិភោគដើម្បីជាទាសៈនៃការសោយអារម្មណ៍ តណ្ហារមែងប្រព្រឹត្តទៅជាមួយគ្នានឹងមោហៈហ្នឹងឯង ។

**២-ន មទាយ** មិនមែនដោយសេចក្តីស្រវឹង ។ មានការស្រវឹងនឹងកម្លាំងកាយដើម្បីវាយតប់អ្នកដទៃជាដើម នេះជាអង្គដើម្បីការពារទោសៈ ។

មានការស្រវឹងច្រើនណាស់ក្នុងការបរិភោគហ្នឹង គឺស្រវឹងនឹងម្ហូបអាហារ គឺត្រូវការម្ហូបអាហារហ្នឹងឯងប្រណីត ម្ហូបអាហារហ្នឹងឯងល្អ
ឱ្យសមនឹងបុណ្យសក្តិឋានៈរបស់ខ្លួន
នេះគឺប្រព្រឹត្តទៅដើម្បីស្រវឹងហើយ (ចំពោះសេចក្តីនេះមានពន្យល់នៅក្នុងគម្ពីរវិសុទ្ធិមគ្គ)។
ដើម្បីឱ្យសមនឹងបុណ្យ សក្តិឋានៈរបស់ខ្លួនហ្នឹងឯង ត្រូវឱ្យចានហ្នឹងក៏ត្រូវតែល្អ ភាជន ស្លាបព្រា សមចង្កឹះត្រូវតែល្អត្រូវតែប្រណីត ទាំងនេះបើកាលណានឹកឃើញថា អាត្មាអញហ្នឹងឯងមានឋានៈ

យ៉ាងនេះ មានបុណ្យសក្តិយ៉ាងនោះ ម្ហូបអាហារត្រូវតែល្អ ត្រូវតែប្រណីត ទាំងចានទាំងភាជនទាំងឡាយផ្សេងៗ ទីកន្លែងសម្រាប់បរិភោគនោះត្រូវតែល្អត្រូវតែប្រណីត ទាំងហ្នឹងគឺជាការបរិភោគដោយ **មទ** គឺដោយសេចក្តីស្រវឹង តើយល់ទេដែលថាបរិភោគដោយសេចក្តីស្រវឹងនោះ? ហើយណាមួយសូម្បីរសជាតិនៃអាហារនោះ ក៏វាត្រូវតែប្រណីត នេះក៏ព្រោះអាស្រ័យសេចក្តីស្រវឹងនឹងរសនោះដែរ តែចំពោះបព្វជិតមិនមែនបរិភោគដោយសេចក្តីស្រវឹងទេ អត់មានដើម្បីថា អាត្មាអញចាំបាច់ត្រូវតែមានបាត្រមាស ត្រូវតែបាត្រប្រាក់ ត្រូវតែអាហារនោះប្រណីត ត្រូវតែមានរសនោះអស្ចារ្យ គឺដើម្បីសក្តិសមនឹងអាត្មាអញជាបព្វជិតជាអ្នកបួសអីគឺអត់ទេ អត់មានទាក់ទងនៅក្នុងរឿងទាំងឡាយផ្សេងៗដែលជាការស្រវឹងរីករាយនឹងឋានៈ នឹងមុខនឹងមាត់អី ដើម្បីឱ្យសក្តិសមនឹងខ្លួនឯង នៅក្នុងសម្ភារៈសម្រាប់បរិភោគ ឬក៏ចំពោះអាហារដែលជាគ្រឿងបរិភោគ ចំណីចំណុកផ្លែឈើ ខាទនិយអីហ្នឹងយ៉ាងណាៗ ត្រូវតែ

ប្រណីត ត្រូវតែផ្ចិតផ្ចង់ ត្រូវតែល្អ ត្រូវតែមកពីនាយមកពីបរទេសអីទៅ បានសក្តិសមនឹងអាត្មាអញអីហ្នឹងយ៉ាងណាៗគឺសម្រាប់បព្វជិតអត់មានស្រវឹងនៅក្នុងរឿងទាំងអស់នេះទេ ។

ចំពោះយើងជាឧបាសកឧបាសិកាក៏អ៊ីចឹងដែរ បើមានចិត្តបង្អោនទៅដើម្បីព្រះនិព្វាន ដើម្បីរួចផុតចាកភពនោះគឺមិនមែនបរិភោគដោយសេចក្តីស្រវឹង គ្រប់យ៉ាងទាំងអស់នៅក្នុងរឿងបរិភោគ នេះគឺជាអង្គដែលត្រូវកម្ចាត់បង់នូវទោសៈ ។

ចំពោះការពិចារណាបច្ច័យ៤ ក្នុងការបរិភោគប្រើប្រាស់ប្រចាំថ្ងៃនេះ យើងនឹងរៀនឱ្យបានល្អិតល្អន់បន្តិចដើម្បីឱ្យបានឃើញធម៌វិន័យនេះ នាំមកនូវសេចក្តីបរិសុទ្ធហើយនាំមកនូវការចេះដឹង សូម្បីនៅក្នុងបច្ច័យ៤ដែលបរិភោគប្រើប្រាស់ ក៏ត្រូវតែមានការចម្រើនប្រាជ្ញាស្មារតីពិចារណានូវអ្វីៗដែលស្ថិតនៅជុំវិញជីវិតរបស់ខ្លួន ទាំងការ

បរិភោគប្រើប្រាស់សព្វគ្រប់ទាំងអស់ សំលៀកបំពាក់ ចីវរ បិណ្ឌបាតអីហ្នឹងយ៉ាងណាៗនោះ ។

នៅក្នុងបិណ្ឌបាតប្បច្ច័យ មានអង្គ៤ដែលត្រូវហាមឃាត់ ទី១គឺ **នេវ ទវាយ** នេះជាការហាមឃាត់នូវមោហៈ គឺបរិភោគមិនមែនដើម្បីលេងដូចក្មេងអ្នកស្រុកជាដើមទេ ឯទី២គឺ **ន មទាយ** មិនមែនដើម្បី ឬមិនមែនដោយសេចក្តីស្រវឹងឡើយ ។

**៣-ន មណ្ឌនាយ** មិនមែនដើម្បីប្រដាប់តាក់តែងរាងកាយ ។

សេចក្តីនេះក៏យើងអាចស្តាប់បានហើយ បើយើងនឹកឃើញថា តើដូចអ្វីអ្នកដែលប្រដាប់តុបតែងរាងកាយ? តើអ្នកណាខ្លះនៅក្នុងលោកហ្នឹង? ទាំងនេះយើងនឹងគិតទៅឃើញហើយ គឺជីវិតគេរស់ដើម្បីតែការតុបតែងរាងកាយមុខរបររបស់គេ ការរកទទួលទានរបស់គេ ការចិញ្ចឹមជីវិតរបស់គេ ឬជីវភាពដែលគេរស់នៅហ្នឹង គឺត្រូវតែជាប់ទាក់ទងនឹងការតាក់តែងរាងកាយ ។

នៅក្នុងសេចក្តីនេះ មិនចំពោះតែការបរិភោគឱ្យច្រើនៗទេនៅក្នុងការប្រដាប់តាក់តែងរាងកាយនោះ នៅក្នុងគម្ពីរដែលបានសិក្សានេះ គឺក្នុង **អភិធម្មសង្គណី** និង **អដ្ឋសាលនី** ក៏បានពន្យល់ដែរនៅក្នុងរឿង **ភោជនេ មត្តញ្ញុតា** នេះជាខ្លឹមសារដែលយើងកំពុងតែរៀនហ្នឹងហើយ ។

នៅក្នុង **គម្ពីរវិសុទ្ធិមគ្គ** ផ្នែកខាងសីលក៏បានសម្តែងពន្យល់ប្រាប់ផងដែរថា សូម្បីបរិភោគហ្នឹងឯងបន្តិចបន្តួចដើម្បីរក្សានូវរូបរាងកុំឱ្យវាធាត់ពេក សព្វថ្ងៃហ្នឹងក៏មានអ្នកគិតគូរច្រើនដែរគឺមិនទទួលទានឱ្យច្រើនទេ ព្រោះខ្លាចធាត់កាលណាធាត់ទៅវាអត់ស្អាត តើអ៊ីចឹងមែនទេ? ដូច្នេះការបរិភោគហ្នឹងអត់មានគិតថាបរិភោគដើម្បីរស់ ហើយរស់ហ្នឹងដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ រំលត់នូវសេចក្តីប្រកាន់បញ្ញត្តិថាជាសត្វបុគ្គល ថាជាតួខ្លួននោះគឺអត់មានបរិភោគគិតគូរដល់រឿងហ្នឹងទេ ។ ដូចជាអ្នកដែលនៅក្នុងជំរុំខ្មាំងអ៊ីចឹង បរិភោគហ្នឹងអត់មានគិតថាគ្រាន់តែដើម្បីឱ្យមានកម្លាំងនឹងរត់ចេញពីខ្មាំងសត្រូវនោះ គឺអត់មានទេ ព្រោះ

ស្ត្រីគ្រស្នោះនៅជាមួយខ្លាំងសត្រូវហ្នឹងទៅហើយ អ៊ីចឹងការបរិភោគដោយគំនិតគិតពីរឿងតុបតែងរាងកាយនេះ ឱ្យវាល្អមកុំឱ្យវាធាត់ពេក ហើយកុំឱ្យវាស្គមពេកដែរ បើអត់បរិភោគទៅវាស្គមពេកក៏អត់ស្អាតដែរ តើអ៊ីចឹងមែនទេ? ហើយដល់ធាត់ពេកម៉ាប់ៗទៅក៏អត់ស្អាតដែរ អ៊ីចឹងនៅក្នុងការប្រដាប់តាក់តែងរាងកាយនេះ គឺមិននិយាយពីរឿងសំលៀកបំពាក់ មិននិយាយពីគ្រឿងអលង្ការទេ គឺនិយាយពីរឿងយកសាច់ហ្នឹងជាគ្រឿងប្រដាប់តាក់តែង ពីព្រោះអាហារបរិភោគហ្នឹងវានាំឱ្យកើតសាច់ឈាម ដូច្នេះយកសាច់ឈាមនេះមកជាគ្រឿងប្រដាប់តុបតែងរាងកាយ ប៉ុន្តែចំពោះបព្វជិត និងពុទ្ធបរិស័ទដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន គឺក្នុងការបរិភោគនេះមិនមែនប្រព្រឹត្តទៅដើម្បី **មណ្ឌន** មិនមែនប្រដាប់តុបតែងរាងកាយទេ ។ យើងមើលនៅក្នុងសិក្ខាបទឧបោសថសីល យើងមានព្យពាក្យហ្នឹងហើយ តើមែនទេ? **មាលាគន្ធវិលេបន ធារណមណ្ឌន វិភូសនដ្ឋានា វេរមណី** វៀរចាកនៃការប្រដាប់តុបតែងរាង

កាយដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ នេះគឺវៀរចាកប្រដាប់តុបតែងរាងកាយខាងក្រៅៗ ដូចជា **មាលាគន្ធវិលេបន** គឺផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ក៏ប៉ុន្តែបើយើងទទួលអាហារដើម្បីថា ឱ្យវាមានសាច់ល្អ កុំឱ្យធាត់ពេក កុំឱ្យស្គមពេក អ៊ីចឹងតើដាច់សីលទេ? អត់ដាច់ទេ ព្រោះយើងអត់បានប្រដាប់តាក់តែងរាងកាយខាងក្រៅដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបទេ ក៏ប៉ុន្តែយើងត្រូវសង្រួមទៅទៀតហៅថា **ភោជនេមត្តញ្ញុតា** ស្គាល់ប្រមាណក្នុងការបរិភោគ កុំឱ្យវាមានទោសពីព្រោះកាលណាបើយើងមានកិលេសក្នុងការបរិភោគ នេះក៏វាជាទោសហើយ ។ យើងបរិភោគដើម្បីកម្ចាត់បង់នូវការស្រេកឃ្លានក៏ពិតមែន ប៉ុន្តែក៏វាជាការចម្រើននូវកិលេសរាល់ថ្ងៃ ។ ការបរិភោគនោះយើងតែងតែគិតថា បរិភោគនេះដើម្បីប្រដាប់តាក់តែងរាងកាយ អត់មានគិតថារស់ដើម្បីនឹងរត់ចេញពីខ្មាំងសត្រូវគឺបញ្ចក្ខន្ធ ដែលជាឃាតករនោះទេ ដែលយើងតែងតែស្និទ្ធស្នាលនៅជាមួយឃាតករ

ដែលឃាតករនេះគឺបញ្ចក្ខន្ធជាអ្នកសម្លាប់ តើមែនទេ? យើងមុខតែស្លាប់មែនទេ? មែន ក៏ប៉ុន្តែបើយើងមិនប្រកាន់ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណហើយ តើឃាតករសម្លាប់ យើងបានទេ? អត់ទេ ។ ចំពោះការដែលយើងបរិភោគ ដើម្បីរស់នេះ គឺរស់ដើម្បីចម្រើនបញ្ញា កុំឱ្យវានៅជាមួយ កុំឱ្យវាស្និទ្ធស្នាលជាមួយនឹងឃាតករ ។

**៤-ន វិភូសនាយ** មិនមែនដើម្បីស្អិតស្អាងរាងកាយឱ្យផូរផង់ ពណ៌សម្បុរ ។

✍ អង្គទី៣ និងទី៤នេះ គឺដើម្បីរារាំងនូវរាគៈ ម្យ៉ាងទៀតអង្គទី១ និងអង្គទី២ ជាការរារាំងនូវសញ្ញោជន របស់ខ្លួន អង្គទី៣ និងទី៤ ជាការរារាំងនូវសញ្ញោជន របស់អ្នកដទៃ ម្យ៉ាងទៀតអង្គទី៤នេះ ជាការរារាំងនូវ **អយោនិសោមនសិការ** និង **កាមសុខល្លិកានុយោគ** (ការ ប្រកបខ្លួនរឿយៗនៅក្នុងកាមសុខ) ។

សញ្ញោជនរបស់អ្នកដទៃយ៉ាងម៉េច? គឺបានសេចក្តី ថាក្នុងការប្រដាប់តុបតែងរាងកាយ ស្អិតស្អាងឱ្យផូរផង់

ពណ៌សម្បុរនេះ គឺជាកិច្ចការងារមួយដែលធ្វើឱ្យសញ្ញោជន របស់អ្នកដទៃដែលបានឃើញហើយ ដែលបានឮហើយជា ដើមនោះនូវ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះវានាំឱ្យ ចម្រើននូវសញ្ញោជន ។ ដូច្នេះការដែលបរិភោគនូវអាហារ នេះ គឺគ្មានបំណងចេតនាដើម្បីឱ្យផូរផង់ពណ៌សម្បុរ ឬ ដើម្បីប្រដាប់តាក់តែងរាងកាយយ៉ាងណាៗដើម្បីឱ្យអ្នកដទៃ ហ្នឹងឯងវង្វេងរីករាយនឹងរូបរបស់ខ្លួន នឹងពណ៌សម្បុររបស់ ខ្លួនទេ គឺដើម្បីរារាំងសញ្ញោជនរបស់អ្នកដទៃបាន ដោយ អំណាចកុសលចេតនារបស់យើងកើតឡើង ពោលគឺមិន មែនបរិភោគហ្នឹងដើម្បីឱ្យអ្នកណាម្នាក់មកស្រឡាញ់ត្រេកអរ រីករាយពេញចិត្តនឹងរូបរបស់យើងទេ ព្រោះការបរិភោគ របស់អាត្មាអញនេះមិនមែនប្រដាប់តាក់តែងរាងកាយ មិន មែនស្អិតស្អាងរាងកាយឱ្យផូរផង់ពណ៌សម្បុរ ឱ្យមានរូបរាង ល្អដើម្បីឱ្យអ្នកដទៃវង្វេងភ្លេចស្មារតីនោះទេ គឺអត់មាន ចេតនាដើម្បីអ៊ីចឹងទេ នេះជាការបរិភោគដើម្បីរារាំងនូវ សញ្ញោជនរបស់អ្នកដទៃ អ៊ីចឹងតើយើងយល់ដែរឬទេ?

ចំពោះទី១ និងទី២ ដើម្បីរារាំងនូវសញ្ញោជនរបស់ខ្លួន រីឯទី៣ទី៤នេះ ក៏វាជាការរារាំងសញ្ញោជនរបស់ខ្លួនហើយ តែសំខាន់ក៏ដើម្បីរារាំងសញ្ញោជនរបស់អ្នកដទៃ ។ ទាំងអស់ហ្នឹងគឺជាកុសលល្អណាស់ ដើម្បីមានចេតនាមួយដើម្បីជួយឱ្យអ្នកដទៃហ្នឹងឯងមានស្មារតី ទោះជាអ្នកដទៃហ្នឹងយ៉ាងម៉េច១ក៏ដោយ ចំពោះរឿងហ្នឹងវាជារឿងរបស់អ្នកដទៃទេ ប៉ុន្តែដែលយើងមានចេតនាមានបំណងដើម្បីឱ្យអ្នកដទៃបានសេចក្តីសុខស្ងប់ កុំឱ្យវាមានការញាប់ញ័រ កុំឱ្យវាមានការប្រព្រឹត្តទៅក្នុងសេចក្តីលំបាក ព្រោះតែការចម្រើនឡើងនូវសញ្ញោជនមានរាគៈសញ្ញោជនជាដើមនោះ នេះយើងមានបំណងជួយឱ្យអ្នកដទៃបានសេចក្តីសុខ មិនមែនដើម្បីដឹកនាំឱ្យអ្នកដទៃ បបួលអ្នកដទៃដោយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈរបស់ខ្លួន ឱ្យអ្នកដទៃមានទុក្ខលំបាក ឱ្យអ្នកដទៃដល់នូវសេចក្តីក្រវល់ក្រវាយ ព្រោះហេតុតែ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈនោះទេ តើក្នុងលោកនេះសម្បូរអ្នកដែលបរិភោគអាហារហើយប្រដាប់តុប

តែងរាងកាយដើម្បីឱ្យអ្នកដទៃស្រវឹងនឹងរូបខ្លួនឯងទេ? គឺសម្បូរច្រើនណាស់ ហើយក៏អាចមានទោសមានបាបកម្មទៀតផង ។

ចំពោះរឿងនេះវានៅលើឱបនិស្ស័យទេ បើយើងមានស្មារតីកាត់បន្ថយនូវកិច្ចការងាររបស់យើង ដែលប្រ-ព្រឹត្តទៅដើម្បីបាបកម្មពៀរវេរា ដែលធ្វើឱ្យអ្នកដទៃហ្នឹងឯងវង្វេងភ្លេច ។ ចំពោះគេស្រឡាញ់ គេរីករាយ គេត្រេកអរនឹងរូបយើង ទាំងអស់ហ្នឹងវាជាចិត្តរបស់គេទេ ប៉ុន្តែបំណងរបស់យើងដែលមានបំណងប៉ងប្រាថ្នាដើម្បីឱ្យអ្នកដទៃហ្នឹងឯងចម្រើនទៅដោយសញ្ញោជន ចម្រើនទៅដោយកិលេសចម្រើនទៅដោយសេចក្តីត្រេកត្រអាលរីករាយនោះ ចេតនាហ្នឹងវាជាអកុសល តើយល់ទេកន្លែងហ្នឹង?

## យាវ ទេវ

**ការបរិភោគប្រកបដោយអង្គ៨ប្រការមានប្រយោជន៍ត្រឹមតែៈ**

**១-ឥមស្ស កាយស្ស ឋិតិយា** ដើម្បីការតាំងនៅនៃកាយនេះ ។

នៅក្នុង **ភោជនេ មត្តញ្ញុតា** នេះមានសេចក្តីពីរោះណាស់ នៅក្នុងប្រយោជន៍៨យ៉ាងនេះ គឺអង្គ៨ប្រការនេះ អង្គនីមួយៗហ្នឹង ព្រះសារីបុត្តក៏បានសម្តែងនូវព្រះគាថាសម្រាប់ការបរិភោគនូវភោជនដែលជិតនឹងឆ្អែតហើយ គឺនៅបួនឬប្រាំពំនូតទៀតគឺថាត្រូវឈប់បរិភោគ ត្រូវបរិភោគទឹកបំពេញទៅ នេះសម្រាប់អ្នកដែលមានវិហារធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ហើយនឹងសម្រាប់អ្នកដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ។

នេះជាធម៌ដែលយើងគួរដល់ការសិក្សា ពីព្រោះថាការដែលទាក់ទងនឹងបច្ច័យ៤បរិភោគប្រើប្រាស់ហ្នឹង គឺជាគ្រឿងចម្រើននូវប្រាជ្ញាស្មារតី ជាគ្រឿងចម្រើននូវសតិសម្បជញ្ញៈ បញ្ជាក់ឱ្យឃើញថា បើសិនជាការបរិភោគប្រើប្រាស់មិនល្អទេនោះ គឺជាអ្នកនៅជាមួយនឹងឃាតករ ឯលទ្ធផលដែលនៅជាមួយនឹងឃាតករ គឺយើងជ្រាបហើយ តើព្រះគុណម្ចាស់ញាតិញោមបងប្អូនស្រីប្រុសជ្រាបច្បាស់ថានៅជាមួយឃាតករដូចម្តេចទេ? នេះបើសរុបសេចក្តីមកគឺ

**សក្កាយទិដ្ឋិ២០** ឈ្មោះថាជាការស្និទ្ធស្នាលជាមួយនឹងឃាត-
ករ លទ្ធផលគឺត្រូវស្លាប់ តើមែនទេ? ព្រោះ រូប វេទនា
សញ្ញា សង្ខារ វិញ្ញាណ ដែលប្រើប្រាស់ទៅក៏មានសេចក្ដីត្រិះ
រិះថា អញហ្នឹងសាបសូន្យហើយ អញហ្នឹងឯងបាត់បង់
ហើយ អញហ្នឹងវិនាសហើយ ប៉ុន្តែកាលណាបើការ
បរិភោគប្រើប្រាស់នូវបច្ច័យ៤នេះឯង ប្រកបដោយសតិ
សម្បជញ្ញៈ គឺជាការបរិភោគប្រើប្រាស់របស់អ្នកភ្ញាក់រឮក
មានដំណើរដើម្បីរត់ចេញអំពីឃាតករនោះ ក៏ពិចារណា
ឃើញ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណហ្នឹងឯងពុំមែនជា
តួខ្លួន មានការរំលត់នូវសក្កាយទិដ្ឋិ ។ នៅពេលដែល រូប
វេទនា សញ្ញា សង្ខារ វិញ្ញាណដល់នូវការប្រែប្រួលសព្វគ្រប់
ប្រការ ដោយជរា ដោយព្យាធិ ដោយមរណយ៉ាងណាៗ
ដោយឧបទ្ទវហេតុយ៉ាងម៉េចៗក៏ដោយ សេចក្ដីត្រិះរិះថា
អញប្រែប្រួលហើយ អញវិនាសហើយនោះរមែងមិនមាន
អ្វីចឹងក៏ជាការរំលត់ទុក្ខទៅហោង ។

ដោយអាស្រ័យពាក្យ **យាវ ទេវ** គ្រាន់តែឬត្រឹមតែការតាំងនៅនៃកាយនេះ ។ ដូច្នេះការបរិភោគហ្នឹងមិនមែនដើម្បីលេង ឬដោយការស្រវឹង ឬដោយប្រដាប់តាក់តែងស្អិតស្អាងរាងកាយនោះទេគឺ **យាវ ទេវ ឥមស្ស កាយស្ស ឋិតិយា** គ្រាន់តែដើម្បីការតាំងនៅនៃកាយនេះ ។

**២-យាបនាយ** ដើម្បីជាការប្រព្រឹត្តទៅនៃជីវិតិន្ទ្រិយ ។

យើងពិចារណាបិណ្ឌបាតបច្ច័យអាហារបរិភោគនេះមានន័យល្អណាស់នៅក្នុងជីវិតរបស់យើង មិនថាតែបព្វជិតទេ យរាវាសឧបាសកឧបាសិកាដែលជាអ្នកទទួលការណែនាំអំពីឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ក៏ពិចារណាក្នុងបច្ច័យ៤ដែលបរិភោគប្រើប្រាស់នេះ គឺបរិភោគដោយមានស្មារតីកុំឱ្យវាជាប់នៅក្នុងចំណងរបស់សត្រូវ ដូចជាអាហារបរិភោគរបស់ខ្មាំងសត្រូវអ៊ីចឹង ព្រោះរឿងនេះវាអាស្រ័យបញ្ចក្ខន្ធតែប៉ុណ្ណោះ ប្រៀបបីដូចជាជំងឺ ប្រៀបបីដូចជារោគ ។

នៅក្នុងការបរិភោគហ្នឹងគ្រាន់តែដូចជាថ្នាំដើម្បីព្យាបាលរោគតែប៉ុណ្ណឹងឯង មិនមែនជារឿងដែលរីករាយនឹង

ថ្នាំ ហើយចង់រក្សារោគហ្នឹងឱ្យវានៅរហូតតទៅ កុំឱ្យវាជា ឱ្យវានៅតែឈឺដើម្បីយើងបានថ្នាំបរិភោគនោះទេ យើង បរិភោគថ្នាំដើម្បីឱ្យជារោគ ក៏ដូចជាបរិភោគអាហារដើម្បី លះបង់នូវបញ្ចក្ខន្ធអីចឹងដែរ ។

បញ្ចក្ខន្ធនេះដូចជារោគ តើជារោគអ្វី? ដូចជារោគ គ្រុន ព្រះគុណម្ចាស់ឆាន់ថ្នាំ ញាតិញោមពិសាថ្នាំទៅ គឺមិនឆ្ងាញ់ទេចំពោះថ្នាំនោះ ដូចជាល្វីងអីចឹងទៅ ប៉ុន្តែ ចាំបាច់ត្រូវតែឆាន់ ត្រូវតែបរិភោគដើម្បីឱ្យជារោគ មិន មែនសប្បាយរីករាយនឹងបានថ្នាំឆាន់ ហើយចង់ឱ្យវានៅតែ គ្រុនទៅទៀតទៅដើម្បីបានឆាន់ថ្នាំទៀតនោះ គឺមិនមែន អីចឹងទេ ។ ចំពោះបញ្ចក្ខន្ធនេះដូចជារោគដែរ ជាតួរោគ ហ្នឹងតែម្តងក៏បាន ព្រោះមានការកើតឡើងនាំមកនូវសេចក្តី ទុក្ខគ្រប់យ៉ាងទាំងអស់ ។ ដូចនេះនៅក្នុងព្រះធម៌សម្តែងថា ការបរិភោគអាហារក៏ដូចជាការបរិភោគថ្នាំអីចឹង គឺដើម្បីឱ្យ ជារោគ យ៉ាងណាមិញគឺដើម្បីរស់ ហើយរស់គឺដើម្បី អនុគ្រោះដល់ព្រហ្មចរិយធម៌ មានការបដិបត្តិដោយសីល

សមាធិ បញ្ញា ដើម្បីនឹងរលាស់ចោលនូវបញ្ចក្ខន្ធនេះ ដូច្នេះ ការបរិភោគហ្នឹង គឺមានន័យណាស់នៅក្នុងព្រះសាសនានេះ សមគួរនឹងការពិចារណាជាចាំបាច់ ដើម្បីឱ្យមានការយល់ដឹងយ៉ាងច្រើននៅក្នុងព្រះពុទ្ធសាសនា ដែលជាសាសនាដឹកនាំឱ្យមានសតិសម្បជញ្ញៈ ឱ្យមានការចម្រើនបញ្ញាដើម្បីរំលត់នូវការវង្វេង រំលត់នូវការល្ងង់ខ្លៅរបស់ខ្លួនឯង ដើម្បីឱ្យបានឃើញច្បាស់នូវអ្វីៗទៅតាមសេចក្ដីពិត ។

**៣-វិហឹសុបរតិយា** ដើម្បីកម្ចាត់បង់នូវការបៀតបៀនដោយសេចក្ដីស្រេកឃ្លាន ។

ការស្រេកឃ្លាននេះជាតួបៀតបៀនគឺជាតួ **វិហឹសា** ។ បើសិនជារាល់ថ្ងៃនេះ មានអ្នកដទៃណាម្នាក់មកធ្វើឱ្យយើងស្រេកឃ្លានរាល់តែថ្ងៃអ៊ីចឹង លំបាកស្វែងរកអាហារសម្រាប់បរិភោគ តើព្រះគុណម្ចាស់ញាតិញោមពេញចិត្តនឹងអ្នកនោះដែរទេ? អត់ពេញចិត្តទេ ប៉ុន្តែនេះវាជាធម្មជាតិកើតឡើងខាងក្នុងហ្នឹងតែម្ដង គឺការស្រេកឃ្លាននេះឯង ដូចនេះមិនមានបុគ្គលណាសម្រាប់ឱ្យទាស់ចិត្ត ឱ្យខឹង ឱ្យក្រោធថា

យើស!មកធ្វើឱ្យអញស្រេកឃ្លានរាល់តែថ្ងៃ លំបាកក្នុងការស្វែងរកអាហារបរិភោគនោះគឺអត់អីចឹងទេ ដល់អីចឹងក៏ចេះតែខំប្រឹងប្រែងស្វែងរកអាហារដើម្បីបរិភោគទៅ ដើម្បីកម្ចាត់បង់នូវការស្រេកឃ្លាន ដែលមានការបៀតបៀនជានិច្ចប្រចាំរាល់ថ្ងៃ ទាំងនេះបានសេចក្ដីថាជាការកម្ចាត់បង់ **ឧបរតិយា** ប្រែថាកម្ចាត់បង់ តើកម្ចាត់បង់នូវអ្វី? គឺកម្ចាត់បង់នូវ **វិហឹសា** គឺតួស្រេកតួឃ្លានហ្នឹងវាមានការបៀតបៀនចំពោះការបរិភោគហ្នឹងគ្រាន់តែប៉ុណ្ណឹងឯង ។ បើមិនកម្ចាត់បង់នូវការស្រេកឃ្លានទេ នេះក៏មិនជាប្រយោជន៍អ្វីដែរ ។ យើងទ្រាំឱ្យវាស្រេកឃ្លានទៅ ក៏វាមិនបានជាប្រយោជន៍អ្វីដែរ ព្រោះដែលជាប្រយោជន៍វាទាល់តែមានបញ្ញា ។

បញ្ញាចម្រើនឡើងទើបបានជាប្រយោជន៍ ហើយដល់អត់បញ្ញាទេ យើងចេះតែទ្រាំស្រេកទ្រាំឃ្លានទៅនោះ ឧទាហរណ៍ថា សត្វតិរច្ឆានពពួកខ្លះដែលវាស្រេកឃ្លានណាស់នោះ ក៏មិនឃើញមានប្រយោជន៍ដោយការស្រេកឃ្លានហ្នឹងទេ ឬក៏ដូចជាពពួកប្រេតអីចឹងដែលវាស្រេកឃ្លាន

ណាស់នោះក៏មិនឃើញជាប្រយោជន៍ដែរ ។ រីឯចំណែក ប្រយោជន៍នេះវាទាល់តែមានបញ្ញា ដូច្នេះដើម្បីឱ្យមាន បញ្ញាត្រាស់ដឹងនូវសច្ចធម៌ រំលត់អវិជ្ជា រំលត់កិលេស រំលត់ហេតុដែលនាំឱ្យមានសេចក្ដីទុក្ខ វាទាល់តែរស់ គឺនៅ ក្នុងកំណើតដែលយើងជាមនុស្សនេះ ព្រោះជីវិតហ្នឹងវានៅ ដោយអាហារ អ៊ីចឹងការបរិភោគនេះមិនមានទិសដៅដើម្បី ឆ្ងាញ់ដើម្បីសុខស្រួលនឹងបរិភោគទេ បរិភោគអាហារមែន មានរសប៉ះនឹងអណ្ដាតមែន មានផោដ្ឋព្វៈប៉ះនឹងកាយមែន សុខវេទនាហ្នឹងកើតមែន ប៉ុន្តែទិសដៅមិនមែនរបស់ទាំង អស់ហ្នឹងទេ ។ មានជីវិតរស់នៅមែន តែក៏មិនមែនជាទិស ដៅដែរ ជីវិតដែលរស់នៅហ្នឹងគឺរស់ហើយ **យាបនាយ** ដើម្បី ការប្រព្រឹត្តទៅនៃជីវិតិន្ទ្រិយហើយ ប៉ុន្តែទិសដៅដើម្បីបាន នូវបញ្ញា ហើយបញ្ញានេះក៏មិនមែនជាទីបំផុតដែរ គ្រាន់តែ ថាជាដំណើរ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌គឺព្រះនិព្វាន ដែលជាអសង្ខតធាតុ នេះជាទិសដៅទីបំផុត ក៏ប៉ុន្តែដើម្បី

សម្រេចបាននូវអសង្ខតធាតុ គឺត្រូវប្រព្រឹត្តនូវព្រហ្មចរិយធម៌ ចម្រើនបញ្ញា ដែលជាប្រយោជន៍នាំឱ្យបានសម្រេចនូវព្រះនិព្វានដែលជាទីបំផុតទុក្ខនោះ ។

ចំពោះការបរិភោគនេះ សមគួរដល់ការពិចារណា បើខ្វះការពិចារណា វានៅត្រឹមតែថាឃ្លានហើយក៏បរិភោគទៅ បរិភោគហ្នឹងក៏ដោយអំណាចមានះឱ្យសក្តិសមនឹងអញអ៊ីចឹងទៅ ។ ចានហ្នឹងវាត្រូវតែស្អាត សម ស្លាបព្រាវាត្រូវតែស្អាត វាត្រូវតែមានកណ្តាប់មាសអីអ៊ីចឹងទៅ ផ្តិលទឹកហ្នឹងវាត្រូវតែមាសវាត្រូវតែប្រាក់ កន្លែងបរិភោគហ្នឹងវាត្រូវតែស្អាត ទាំងនេះគឺជាការបរិភោគដោយមានះ រហូតដល់ទៅបរិភោគដើម្បីហៅគេហៅឯងឱ្យមកមើល អ៊ីចឹងក៏តែមាន ដូចជានៅក្នុងរឿងរ៉ាវអីនោះគឺដោយសេចក្តីស្រវឹងដោយមានះ តែភិក្ខុមានការបរិភោគនូវអាហារបិណ្ឌបាតទៅតាមធម៌ទៅតាមវិន័យ និង ពិចារណាត្រឹមត្រូវហើយមិនប្រព្រឹត្តទៅដើម្បីលេង ដើម្បីស្រវឹង ដោយមានះ ឬក៏ប្រដាប់តាក់តែងស្អិតស្អាងរាងកាយទេ បរិភោគនេះមាន

ទិសដៅដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ ឱ្យបានដល់នូវទីរំលត់ទុក្ខ រលាស់ចោលនូវបញ្ចក្ខន្ធ មិនខុសអំពីយើងរក្សានូវដំបៅទេ ទោះជាយើងយកថ្នាំបិទដំបៅ ថែរក្សាថ្នាក់ថ្នម មិនឱ្យមានអ្វីមកប៉ះទង្គិច មិនឱ្យធូលីប៉ះត្រូវ បិទទៅរុំទៅ តែនឹងថាជាអ្នកស្រឡាញ់ដំបៅក៏ទេ ។ ដែលលាងដំបៅ ដែលយកថ្នាំទៅបិទដំបៅ យកសំពត់រុំដំបៅ សុទ្ធតែសំពត់មានអនាម័យល្អៗទាំងអស់ហ្នឹង មិនមែនដោយការត្រេកអររីករាយនឹងដំបៅទេ គឺដើម្បីឱ្យដំបៅជា តើអ៊ីចឹងមែនទេ? ថែរក្សារោគ ថែរក្សាដំបៅដើម្បីឱ្យរោគជា ដើម្បីឱ្យដំបៅហ្នឹងជា យ៉ាងណាមិញបញ្ចក្ខន្ធគឺជារោគគឺជាដំបៅ។ ការស្លៀកពាក់ក៏ដោយ ការបរិភោគហ្នឹងក៏ដែរ សូម្បីនៅក្នុងសេនាសនៈជាដើម ក៏មិនមែនជារឿងត្រេកអរនឹងខន្ធបញ្ចកៈនេះទេ តែក៏ដើម្បីរលាស់ចោលនូវបញ្ចក្ខន្ធ ។ ចុះបើរលាស់ចោលអ៊ីចឹង កុំបរិភោគតែម្តងទៅ កុំឱ្យរវីរវល់នឹងស្លៀកពាក់ទៅ កុំរវីរវល់នឹងនៅផ្ទះសម្បែងទៅ តើវាយ៉ាងម៉េចដែរ? ថានេះវាមិនមែនជាឧបាយក្នុងការរលាស់

ចោលនូវបញ្ចក្ខន្ធទេ គំនិតទាំងអស់នេះវាធ្លាប់កើតមានជាមួយបុគ្គលល្ងង់ៗ ឬថាបុគ្គលដែលមិនទាន់មានបញ្ញាក្នុងការត្រាស់ដឹង ឬថាមិនបានស្តាប់ព្រះធម៌របស់ព្រះដ៏មានព្រះ-ភាគនោះគឺតែងតែមានហើយ ដូចជាដេកផ្ទើភ្លើងអ៊ីចឹងទៅ ឬក៏អត់បាយអត់អាហារទៅ សូម្បីព្រះបរមពោធិសត្វក៏ធ្លាប់ទទួលកម្មពៀរវេរា មានការប្រព្រឹត្តនូវទុក្ករកិរិយាដោយបំណងថាឱ្យបានរួចផុតអំពីបញ្ចក្ខន្ធដើម្បីរំលត់កិលេសដើម្បីឱ្យវាអស់នូវរាគៈតណ្ហាជាដើម ប៉ុន្តែជាការយល់ខុសជាការយល់ច្រឡំទេ ។ សូម្បីព្រះបរមពោធិសត្វប្រព្រឹត្តអ៊ីចឹងក៏ដោយក៏ជាការប្រព្រឹត្តខុស ទៅតាមទម្លាប់ដែលគេធ្លាប់ប្រព្រឹត្តពីដើមៗមក ។ នៅពេលដែលព្រះអង្គបានត្រាស់ដឹងព្រះអង្គទ្រង់ត្រាស់សម្តែងថានេះមិនមែនជាផ្លូវកណ្តាល មិនមែនជាផ្លូវប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង ដើម្បីរួចផុតចាកទុក្ខទេ ហៅថា **អត្តកិលមថានុយោគ** ប្រកបខ្លួនរឿយៗនាំឱ្យមានសេចក្តីទុក្ខលំបាកឥតប្រយោជន៍ ។

ដូច្នេះយើងមិនអាចដើម្បីនឹងថា ឱ្យជារោគដោយសារយើងមិនប្រើថ្នាំ ឬដើម្បីឱ្យជាដំបៅយើងយកដុំដីដុំថ្មទៅគប់ដំបៅថាអញស្អប់ឯងណាស់ អញមិនចង់ឱ្យឯងមានទេ ទៅគប់ទៅគ្រវែងអ្វីចឹងទៅ តើដំបៅហ្នឹងជាទេ? តើអាចរួចអំពីដំបៅហ្នឹងទេ? អត់ទេ ដំបៅហ្នឹងរិទ្ធតែរីកធំឡើងៗ យ៉ាងណាមិញបញ្ចក្ខន្ធហ្នឹងដូចជារោគដូចជាដំបៅអ្វីចឹងដែរ ដើម្បីឱ្យបានរួចផុតអំពីបញ្ចក្ខន្ធនេះ គឺត្រូវតែអាស្រ័យបញ្ញា ហើយដើម្បីបញ្ញាត្រូវតែប្រព្រឹត្តនូវព្រហ្ម-ចរិយធម៌គឺ **សាសនព្រហ្មចរិយផង មគ្គព្រហ្មចរិយផង** ក្នុងការរលាស់ចោលនូវបញ្ចក្ខន្ធ ។ ដូច្នេះក្នុងការរលាស់ចោលនូវបញ្ចក្ខន្ធនេះ មិនមែនជាការប្រព្រឹត្តខ្លួនឱ្យលំបាកដោយសារអត់អាហារទេ គឺរំលត់ឆន្ទរាគគឺរំលត់សេចក្តីត្រេកអរពេញចិត្តក្នុង រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ កាលបើរូបវាមិនមែនជាខ្លួនយើង វេទនាវាមិនមែនជាខ្លួនយើង សញ្ញាវាមិនមែនជាខ្លួនយើង សង្ខារវាមិនមែនជាខ្លួនយើង និងវិញ្ញាណវាមិនមែនជាខ្លួនយើង សេចក្តីប្រកាន់ហ្នឹងមិន

មានហើយ វាជារបស់ដទៃ វាជារបស់ទន់ទាប ដូច្នេះក៏វាបានរួចផុតអំពីបញ្ចក្ខន្ធហ្នឹងទៅ ។ ដូចដែលយើងមិនបានប្រកាន់ស្លឹកឈើមែកឈើ សំរាម ថាជាខ្លួនយើងអ៊ីចឹងយ៉ាងណាឧបាទានក្ខន្ធក៏អ៊ីចឹងដែរ ។ កាលណាបើរំលត់សេចក្ដីប្រកាន់ហើយនោះក៏វាបញ្ចប់បញ្ហាហើយ អត់មានដើម្បីនឹងកង្វល់ដោយប្រការណាៗតាមផ្លូវចិត្តទៀតឡើយ នេះជាឧបាយក្នុងការរលាស់ចោលបញ្ចក្ខន្ធ កន្លែងហ្នឹងឯងដែលជាកន្លែងជារោគជាដំបៅ គឺនៅត្រង់កន្លែងហ្នឹងហើយជាមួយនឹងបញ្ចក្ខន្ធគឺរំលត់សេចក្ដីប្រកាន់ ។ ដូច្នេះការរលាស់ចោលនូវបញ្ចក្ខន្ធនេះ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សម្ដែងហើយគឺការរំលត់នូវសេចក្ដីប្រកាន់ អ៊ីចឹងទាល់តែមានបញ្ញាឃើញបញ្ចក្ខន្ធហ្នឹងតាមសេចក្ដីពិត ទើបការបរិភោគនេះមានទិសដៅដើម្បីចម្រើនបញ្ញា ។

**៤-ព្រហ្មចរិយានុគ្គហាយ** ដើម្បីអនុគ្រោះដល់សាសនព្រហ្មចរិយទាំងអស់ផង និងមគ្គព្រហ្មចរិយផង ។

ទាំងនេះក៏បានពន្យល់ពីខាងដើមៗមកហើយ គឺនៅក្នុងន័យកន្លែងហ្នឹងឯង គឺដើម្បីអនុគ្រោះព្រហ្មចរិយនេះក្នុងព្រះធម៌លោកសម្ដែងដល់ **សាសនព្រហ្មចរិយ** ។

សាសនព្រហ្មចរិយនេះគឺជាព្រះពុទ្ធដីកាទាំងអស់ ឬថាជាព្រះបរិយត្តិទាំងអស់ នេះហៅថា **សាសនព្រហ្មចរិយ** ដែលថ្លាស្អាតបរិសុទ្ធ គួរដល់ការក្រេបផឹក គឺសិក្សារៀនសូត្រនិងប្រព្រឹត្តបដិបត្តិ នេះហៅថា **សាសនព្រហ្មចរិយ** ។

ព្រះអង្គទ្រង់ត្រាស់សម្ដែងមានលម្អរបទដើម ដោយសីល លម្អរបទកណ្ដាលដោយសមាធិ លម្អរបទខាងចុងដោយបញ្ញា ឬថាលម្អរបទដើមដោយសីល និងសមាធិ លម្អរបទកណ្ដាលដោយបញ្ញា លម្អរបទចុងដោយមគ្គផលព្រះនិព្វានយ៉ាងនេះក៏បាន ។ ព្រះអង្គទ្រង់ប្រកាសសម្ដែងបរិបូណ៌ដោយអត្ថនិងព្យញ្ជនៈ បរិសុទ្ធគ្រប់គ្រាន់ទាំងអស់ ឈ្មោះថាជាសាសនព្រហ្មចរិយស្អាតបរិសុទ្ធ គួរដល់ការក្រេបផឹក ។ ពាក្យថាគួរដល់ការក្រេបផឹកនេះ គឺសត្វលោកដែលមានកិលេសជាគ្រឿងក្ដៅ តណ្ហាជាគ្រឿងស្រេក

ឃ្លានហ្នឹងឯង ដូច្នេះកាលណាបើមកជួបសាសនព្រហ្មចរិយ នេះក៏គប្បីគោរពដល់ការសិក្សារៀនសូត្រដោយការទ្រទ្រង់ ដោយការស្វាធ្យាយ ដោយការពិចារណា និងការប្រព្រឹត្ត បដិបត្តិដោយសេចក្ដីគោរព ប្រព្រឹត្តទៅដើម្បីកម្ចាត់បង់នូវ តណ្ហាដែលជាការស្រេកឃ្លាន ។ សាសនព្រហ្មចរិយនេះ គឺជាគ្រឿងដែលត្រូវផឹកដើម្បីបំបាត់នូវតណ្ហា ដើម្បីបំបាត់ នូវការស្រេកឃ្លាន តើស្ដាប់យល់ខ្លះៗទេ? សាសនព្រហ្ម ចរិយនេះ គឺជាការបរិភោគដើម្បីសិក្សារៀនសូត្រ ដើម្បី **គន្ធធុរៈ**ហៅថាអនុគ្រោះដល់ព្រហ្មចរិយគឺសាសនព្រហ្មចរិយ នេះឯង ហើយនឹងមគ្គព្រហ្មចរិយដែលប្រព្រឹត្តទៅនៅក្នុង **វិបស្សនាធុរៈ** ដែលមានការចម្រើនឱ្យបានសម្រេចនូវអរិយ មគ្គប្រកបដោយអង្គ៨ប្រការ ។

ដូច្នេះចំពោះការបរិភោគនេះ គឺមានទិសដៅដើម្បី ប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដោយការពិចារណាឃើញថា កាលដែលបានតាំងនៅនៃកាយនេះ ជីវិតិន្ទ្រិយប្រព្រឹត្តទៅ អ៊ីចឹងហើយក៏បដិបត្តិដោយត្រៃសិក្ខាគឺសីល សមាធិ បញ្ញា

ជាការប្រព្រឹត្តបដិបត្តិអនុគ្រោះដល់សាសនព្រហ្មចរិយ និងមគ្គព្រហ្មចរិយ ។ ធម៌បដិបត្តិដោយសីលសមាធិបញ្ញានេះ គឺអនុគ្រោះដល់ព្រហ្មចរិយទាំងពីរ ព្រោះបើយើងគ្រាន់តែសិក្សា តែមិនប្រព្រឹត្តបដិបត្តិ ក៏ឈ្មោះថាមិនអនុគ្រោះដែរ ។ ពាក្យថាអនុគ្រោះ គឺមានការប្រព្រឹត្តបដិបត្តិតាម ហើយការប្រព្រឹត្តបដិបត្តិតាមនេះឯង ក៏ជាការអនុគ្រោះដល់មគ្គព្រហ្មចរិយផងដែរ ។

**៥-ឥតិ បុរាណញ្ច វេទនំ បដិហំខាមិ** ដោយឧបាយនេះគឺដើម្បីបំបាត់បង់នូវវេទនាចាស់ បានដល់សេចក្តីស្រេកឃ្លានផង ។

សេចក្តីស្រេកឃ្លាននេះ លោកហៅថាវេទនាចាស់ **បុរាណញ្ច វេទនំ** ។ នៅក្នុងន័យម្យ៉ាងទៀតនោះ គឺកាលណាបើមិនមានការបរិភោគទេ វាមានការប្រព្រឹត្តទៅនៅក្នុង **អត្តកិលមថានុយោគ** គឺជាការប្រកបខ្លួនឱ្យលំបាកឥតប្រយោជន៍ ព្រោះវាមិនមែនកើតបញ្ញាដោយសារការស្រេកឃ្លានហ្នឹងទេ ។ ការដែលមានបញ្ញាវាត្រូវអាស្រ័យការ

អប់រំនូវបញ្ញា ដោយសតិរលឹករឿយៗចំពោះរូបធម៌ និងនាមធម៌ ដូច្នេះបើបណ្ដោយទៅតាមការស្រេកឃ្លានដោយមិនមានការបរិភោគ ទុក្ខវេទនាជាអកុសលវិបាកអាស្រ័យកម្មចាស់ ។ កម្មចាស់គឺកម្មដែលបានធ្វើហើយ ជាអកុសលកម្មហ្នឹងឯង វាមានឱកាសវាញ៉ាំងទុក្ខវេទនាឱ្យកើតឡើង ឬក៏សូម្បីការបរិភោគហើយ បរិភោគដោយអាហារមិនជាទីសប្បាយ អាហារដែលវាជាទំនាស់នឹងសុខភាព ឬក៏បរិភោគមិនស្គាល់ប្រមាណ នេះក៏ជាប្រយោគវិបត្តិមួយដើម្បីញ៉ាំងនូវបាបចាស់ អកុសលកម្មឯណានិមួយនោះដែលបានធ្វើហើយហ្នឹងញ៉ាំងទុក្ខវេទនាឱ្យកើតឡើង ។ ដូច្នេះក្នុងការបរិភោគនេះគឺដើម្បីបំបាត់នូវការស្រេកឃ្លានផង និងដើម្បីថាកុំឱ្យវេទនាថ្មីគឺឆ្អែតហួសប្រមាណនោះកើតឡើងផង ។
**៦-នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** ដើម្បីមិនឱ្យវេទនាថ្មីគឺការឆ្អែតហួសប្រមាណកើតឡើងបានផង ។

ចំពោះការបរិភោគនេះ គឺបំបាត់នូវវេទនាចាស់គឺការស្រេកឃ្លាន ហើយមិនញ៉ាំងនូវវេទនាថ្មីគឺការឆ្អែតហួស

ប្រមាណឱ្យកើតឡើងផង ។ ដូច្នេះក្នុងការបរិភោគនេះតើប្រព្រឹត្តទៅយ៉ាងណា? យើងពិចារណាទៅឃើញហើយមិនជាប្រយោជន៍ក្នុងការស្រេកឃ្លាននោះទេ ហើយក៏មិនមែនជាប្រយោជន៍ក្នុងការដែលឆ្អែតហួសប្រមាណដែរ ទាំងនេះសុទ្ធតែប្រព្រឹត្តទៅជាទោស ។ ចំពោះទោសទៅតាមផ្លូវកាយនេះវាទាក់ទងនឹងកិលេសដោយអំណាច **រសតណ្ហា** ដោយអំណាចពេញចិត្តនឹងរស ពេញចិត្តនឹងសេចក្ដីសុខស្រួលក្នុងការឆ្អែត ស្រួលនឹងដេក ស្រួលនឹងផ្អែក ស្រួលនឹងលក់ នេះដោយអំណាចកិលេសដែលជាបង្គោលចងចិត្តចងសត្វលោកឱ្យជាប់នៅក្នុងវដ្ដសង្សារ វាធ្វើឱ្យមិនស្គាល់ប្រមាណក្នុងការបរិភោគ អ៊ីចឹងការបរិភោគនេះដើម្បីកម្ចាត់នូវការស្រេកឃ្លាន និងបំបាត់នូវការស្រេកឃ្លានដែលឈ្មោះថាវេទនាចាស់ ។

**៧-យាត្រា ច មេ ភវិស្សតិ** ការសម្រេចឥរិយាបថបួននឹងប្រព្រឹត្តទៅដល់អាត្មាអញផង ។

កាលណាបើយើងទុកឱ្យវាឃ្លានពេកអ៊ីចឹងទៅ តើឥរិយាបថ៤ប្រព្រឹត្តទៅបានទេ? រហ័សរហួនទេក្នុងការក្រោកឡើង ដេកដើរឈរអង្គុយ តើបានទេ? អត់ទេ ដល់ទៅមែនទែនទៅគឺស្ដូកនៅនឹងកន្ទេលហ្នឹងឯង ងើបអង្គុយទាល់តែគេគ្រា តើមែនទេ? គឺមែន ។ វាមិនអាចដេកដើរឈរអង្គុយបានស្រួលទេ ហើយចុះបើបរិភោគឆ្អែតពេកទៅរហូតដល់ហាល់ផ្ទែះៗនោះ តើអាចបានស្រួលក្នុងឥរិ-យាបថទេ? អត់ទេ ។ ចំពោះការបរិភោគគឺបំបាត់នូវការស្រេកឃ្លាន ហើយក៏មិនញ៉ាំងការឆ្អែតហួសប្រមាណឱ្យហាល់ឱ្យលំបាកគួរដល់សប្បុរសតិះដៀលនោះទេ គ្រាន់តែឱ្យមានការប្រព្រឹត្តទៅក្នុងឥរិយាបថបួន **យាត្រា ច មេ ភវិស្សតិ** គឺការប្រព្រឹត្តទៅនៅក្នុងឥរិយាបថបួននេះមិនមានដល់អាត្មាអញ មិនទៅជាប់ចិត្តនឹងឥរិយាបថហ្នឹងទេ តែថាកិច្ចការដែលប្រព្រឹត្តទៅនៅក្នុងសាសនានេះ ក៏វាទាក់ទងនឹងឥរិយាបថហ្នឹងហើយ ដើម្បីនឹងប្រព្រឹត្តទៅយ៉ាងណាៗតាមព្រះធម៌តាមព្រះវិន័យកិច្ចការក្នុងសាសនា ដោយការ

សិក្សារៀនសូត្រក្តី ដោយការប្រព្រឹត្តបដិបត្តិដោយសេចក្តីគោរពក្តី ។

**៨-អនវជ្ជតា ច ផាសុវិហារោ ច** ដើម្បីការមិនមានទោសផង ការនៅជាសុខផង ។

ការមិនមានទោសដោយការស្វែងរក ការមិនមានទោសដោយការទទួល និងការមិនមានទោសដោយការបរិភោគទៅតាមធម៌តាមវិន័យ ដើម្បីនៅជាសុខ ព្រោះស្គាល់ប្រមាណក្នុងការបរិភោគ ម្យ៉ាងទៀតការមិនមានទោសព្រោះបរិភោគច្រើនហួសនាំឱ្យហល់ គួរដល់ការតិះដៀល នៅជាសុខព្រោះបរិភោគតែអាហារជាទីសប្បាយដល់រាងកាយ វៀរចាកអាហារដែលមានទោស និងម្យ៉ាងទៀតមិនមានទោសព្រោះជំពាក់ចិត្តក្នុងសុខគឺសុខនឹងដេកសុខនឹងផ្អែក សុខនឹងលក់ជាដើមប៉ុណ្ណោះ ។

សុខភាពរាងកាយមនុស្សយើងវាផ្សេងៗគ្នា ត្រូវតមចំណីទាស់ ដូច្នេះក៏ត្រូវតែមានសេចក្តីអត់ធ្មត់ដើម្បីវៀរចាក

នូវចំណីទាស់ដែលនាំឱ្យរោគវារើឡើង ឬបណ្ដាលឡើង ដូចនេះបរិភោគតែអាហារជាទីសប្បាយដល់កាយ ។ ពាក្យថាអាហារជាទីសប្បាយ គឺអាហារដែលនាំឱ្យសប្បាយកាយ មិនមែនសប្បាយត្រេកអររីករាយដោយលោភៈនោះទេ ។ បរិភោគទៅនាំឱ្យសុខស្ងប់ផ្លូវកាយ មិនបណ្ដាលឱ្យរោគផ្សេងៗវារើឡើងទេ ហើយការដែលមិនមានទោសនោះគឺការដែលបរិភោគល្មមប្រមាណហ្នឹងហើយ មិនឱ្យច្រើនហួសទាល់តែហល់ទេ ដែលនាំឱ្យមានការតិះដៀល ។

មានព្រាហ្មណ៍ម្នាក់គាត់បរិភោគរហូតដល់ក្រោកអត់រួច ទាល់តែគេជួយលើកជួយទាញដៃបានងើបរួច ព្រោះគាត់បរិភោគច្រើនហួស ឈ្មោះថា **អាហរហត្ថិកព្រាហ្មណ៍** ឯព្រាហ្មណ៍ម្នាក់ទៀតគាត់ក្រោករួច ប៉ុន្តែគាត់ស្លៀកសំពត់អត់ចូល ព្រោះពោះគាត់ធំពេក ឈ្មោះថា **អាលំសារិក-ព្រាហ្មណ៍** គឺហៅឈ្មោះទៅតាមការដែលគាត់បរិភោគច្រើនហួសប្រមាណ ។ ឯព្រាហ្មណ៍ម្នាក់ទៀតបរិភោគរួចទៅហល់ពេកក៏ននាលនៅនឹងដី ឈ្មោះថា **តត្ថវត្តិកព្រាហ្មណ៍**

ហើយព្រាហ្មណ៍មួយនោះ បរិភោគពេញពោះរហូតដល់លេបលែងចូលនៅនឹងមាត់ ពេលក្អែកចុះមកក៏ចឹកបាយនៅក្នុងមាត់គាត់ហ្នឹងឯង ឈ្មោះថា **កាកមាសិកព្រាហ្មណ៍** ឯព្រាហ្មណ៍ម្នាក់ទៀតបរិភោគរួចទៅក្អួត បរិភោគច្រើនពេកទាល់តែក្អួត ឈ្មោះថា **ភុត្តវនិកតកព្រាហ្មណ៍** មានលើកឧទាហរណ៍នៅក្នុងព្រះធម៌នេះ អំពីរឿងការបរិភោគច្រើនវានាំឱ្យមានទោស ដូច្នេះភិក្ខុលោកបរិភោគនូវចង្ហាន់បិណ្ឌបាតគឺ **អនវជ្ជតា** គឺដើម្បីការមិនមានទោសដូចជាព្រាហ្មណ៍ទាំងអស់នេះទេ ហើយក៏ដើម្បីការនៅជាសុខ ។ ចំពោះការនៅជាសុខនេះ ក៏ជាអានិសង្សនៃការបរិភោគអាហារដែលជាទីសប្បាយ ហើយនឹងការបរិភោគអាហារដោយការស្គាល់ប្រមាណ ។

ចំពោះសេចក្តីត្រេកអរក្នុងការបរិភោគពេញពោះទៅដើម្បីដេកជាសុខស្រួល ឬផ្អែកស្រួល ទាំងអស់នេះវាជាសត្រូវ វាជាចំណងដែលចាត់ជាទោសផងដែរ ដូច្នេះការបរិភោគមិនមែនដើម្បីឱ្យមានទោស នៅក្នុងរឿងត្រេកអរ

នឹងសុខដោយសារដេកផ្ទែកលក់ទេ ។ យើងក៏គួរតែគិតគូផងដែរចំពោះរឿងទាំងអស់ហ្នឹង ដូចជាថាបរិភោគឱ្យច្រើនទៅសម្រាន្តលក់ស្រួល ដែលយើងតែងតែហៅថាពុលបាយនោះ នេះសុទ្ធតែជារឿងជាប់ជំពាក់ ហើយជាសត្រូវចំពោះជីវិតរបស់យើង ។ វាបានសុខស្រួលប៉ុណ្ណឹងទៅប៉ុន្តែរឿងដែលជំអក់នៅ រឿងដែលជាប់ជំពាក់នៅនោះបានសេចក្តីថាជាការនៅក្នុងអំណាចនៃខ្មាំងសត្រូវហាក់ដូចជាយើងនៅក្នុងជំរុំខ្មាំងអ៊ីចឹង ។ ខ្មាំងដែលចាប់យើងបានយើងសប្បាយជ្រប់ងប់ទៅ ឬក៏សំងំនៅជាមួយនឹងខ្មាំងសត្រូវទៅ ធ្វើជាអ្នកបំរើខ្មាំងសត្រូវហ្នឹងទៅ ប៉ុន្តែភិក្ខុលោកមិនមែនដើម្បីសប្បាយពេញចិត្តនឹងដេក នឹងផ្ទែក នឹងលក់ទាំងអស់នេះទេ លោកធ្វើទុកក្នុងចិត្តថាដូចជានៅជាមួយខ្មាំងសត្រូវ ដែលខ្មាំងសត្រូវចាប់បានអ៊ីចឹង បរិភោគនោះគឺអត់មានត្រេកអរនឹងចំណី ដែលដាក់ចូលមាត់ទៅឆ្ងាញ់ដើម្បីឆ្អែតសុខស្រួលទេ លោកមានសតិសម្បជញ្ញៈដើម្បីរត់ចេញអំពីខ្មាំងសត្រូវ ។

ចំពោះការអត់មានសតិសម្បជញ្ញៈ តើអង្គធម៌បាន ដល់អ្វី? គឺបានដល់លោភៈ ទោសៈ មោហៈហ្នឹងឯង ។

ការងារណាដែលយើងវិនិច្ឆ័យដោយការមិនមាន សតិសម្បជញ្ញៈ វាប្រព្រឹត្តទៅដោយលោភៈ ឬទោសៈ ឬក៏ មោហៈ ។ ចំពោះអារម្មណ៍នៃកិច្ចការងារដែលយើងប្រុង នឹងធ្វើនោះ ឬថារឿងអ្វីៗដែលយើងប្រុងនឹងធ្វើនោះ គឺវា អត់ពិតទៅតាមការវិនិច្ឆ័យទេ ពីព្រោះការវិនិច្ឆ័យហ្នឹងវា ប្រាសចាកនូវសតិសម្បជញ្ញៈ **មុដ្ឋសច្ច** វាអត់មានសតិ វា វង្វេងភ្លេចសតិ ដូច្នេះយើងវិនិច្ឆ័យក្នុងរឿងអ្វីមួយ គឺរឿង អ្វីនោះអត់ពិតទៅតាមការវិនិច្ឆ័យទេ ។ ក្នុងជីវិតសព្វថ្ងៃ នេះមនុស្សយើងបែងចែករឿងមួយទៅជាច្រើនយ៉ាង តាម អំណាចនៃការគិតយល់ ដោយការខ្វះសតិសម្បជញ្ញៈក៏ វិនិច្ឆ័យរឿងហ្នឹងផ្សេងទៅ គួរឱ្យស្រឡាញ់ គួរឱ្យស្អប់ អីចឹងទៅ ប៉ុន្តែបើប្រកបដោយសតិសម្បជញ្ញៈក៏វិនិច្ឆ័យ រឿងមួយហ្នឹងឯងដែលគួរឱ្យមានសេចក្តីជ្រះថ្លា គួរឱ្យមាន មេត្តា គួរឱ្យមានករុណា គួរឱ្យមានការដឹងគុណអីចឹងទៅ

ដូចនេះបានថានៅពេលដែលយើងគិតចង់ធ្វើនូវអំពើអ្វីមួយ ដោយលោភៈ ទោសៈ មោហៈ សុទ្ធតែប្រាសចាកសតិសម្ប-ជញ្ញៈទាំងអស់ ព្រោះអង្គធម៌កាលដែលវង្វេងភ្លេចសតិ និង មិនមានសម្បជញ្ញៈវានៅក្នុងអកុសលចិត្តទាំង ១២ដួងហ្នឹង ឯង ។ អ៊ីចឹងការវិនិច្ឆ័យក្នុងរឿងអ្វីមួយដើម្បីនឹងធ្វើ បើ ការវិនិច្ឆ័យរបស់យើងហ្នឹងឯងវាអត់មានសតិសម្បជញ្ញៈទេ យើងកុំជឿថារឿងដែលយើងបានវិនិច្ឆ័យនោះ វាត្រឹមត្រូវ ឬវាពិតហើយ ពីព្រោះការវិនិច្ឆ័យដោយអត់សតិសម្ប-ជញ្ញៈវាមិនអាចពិតទៅតាមការគិត ទៅតាមការសម្រេច ទៅតាមការវិនិច្ឆ័យទេ ។ ដូចជាយើងវិនិច្ឆ័យថាស្អាតហើយ ល្អហើយ គួរឱ្យយើងចង់បានណាស់ អ៊ីចឹងទៅលួចទៅប្លន់ ឬក៏ប្រព្រឹត្តខុសក្នុងកាមេទៅ ។ ការដែលវិនិច្ឆ័យរបស់យើង ថាត្រូវតែធ្វើនូវអំពើរទាំងអស់ហ្នឹងនោះគឺដោយមិនមានសតិ សម្បជញ្ញៈ ដូច្នេះគឺថារឿងដែលថាល្អ ដែលថាស្អាត គួរតែ យើងទៅលួចទៅប្លន់ទៅយកមកនោះ វាជារឿងអត់ពិតទេ ដែលពិតនោះគឺមិនគួរកាន់យក មិនគួរប្រព្រឹត្តខុសក្នុង

កាមទាំងឡាយ មិនគួរនិយាយកុហក និយាយញុះញង់ជាដើម ។ តាមពិតសាច់រឿងនោះវាត្រូវតែមិនគួរប្រព្រឹត្តធ្វើនូវអំពើអាក្រក់ឯណានិមួយទេ ប៉ុន្តែដែលវាទៅជាគួរនោះតាមពិតវានៅលើការវិនិច្ឆ័យហ្នឹងឯង ខ្វះនូវសតិសម្បជញ្ញៈសូម្បីពេលខ្លះដែលយើងវិនិច្ឆ័យរឿងដែលគួរឱ្យយើងទាស់ចិត្ត ឬបុគ្គលដែលគួរឱ្យស្អប់នោះ ក៏ការវិនិច្ឆ័យនៅពេលហ្នឹងខ្វះសតិសម្បជញ្ញៈ ព្រោះវាកើតជាមួយនឹងទោសៈម្ល៉ោះហើយរឿងដែលយើងវិនិច្ឆ័យហ្នឹងវាអត់ពិត វាអត់ត្រឹមត្រូវទៅតាមសេចក្តីពិតនៃសាច់រឿងទេ ។ យើងកុំឱ្យជឿលើការវិនិច្ឆ័យរបស់យើង ដែលវាអត់សតិសម្បជញ្ញៈនោះប្រៀបដូចជាយើងខ្វាក់ភ្នែកអ៊ីចឹង ហើយកុំជឿថាខ្លួនឯងអាចដើរត្រូវផ្លូវនោះ នេះជាឧទាហរណ៍យ៉ាងណារឿងអ្វីក៏ដោយដែលយើងវិនិច្ឆ័យដោយលោភៈ ទោសៈ មោហៈថារឿងហ្នឹងត្រូវឱ្យយើងស្រឡាញ់ ត្រូវឱ្យយើងស្អប់ ត្រូវឱ្យយើងវង្វេងអីហ្នឹងយ៉ាងណា គឺថាវាមិនពិតទៅតាមសាច់រឿងទេ តើស្តាប់យល់ចូលចិត្តទេ? យ៉ាងណានៅក្នុងរឿង

បរិភោគហ្នឹងក៏អ៊ីចឹងដែរ បើយើងគិតថាគួរដើម្បីបរិភោគឱ្យបាននូវសេចក្ដីសុខក្នុងការដេក ការផ្ដេក និងសេចក្ដីស្រណុកសុខស្រួលក្នុងការលង់លក់ហ្នឹងយ៉ាងណា វាជាការវិនិច្ឆ័យដោយលោកៈគឺ **ភោជនេ អមត្តញ្ញុតា** ដូច្នេះវាអត់មានសតិសម្បជញ្ញៈនៅក្នុងលោកៈនេះទេ អ៊ីចឹងសាច់រឿងដែលយើងវិនិច្ឆ័យថា គួរតែបរិភោគដើម្បីសេចក្ដីស្រណុកសុខស្រួលហ្នឹងនោះ តាមពិតវាអត់គួរអ៊ីចឹងទេ សាច់រឿងហ្នឹងវាគួរតែថា **បរិភោគឱ្យស្គាល់ប្រមាណ** គ្រាន់តែការប្រព្រឹត្តទៅនៃឥរិយាបថបួនហ្នឹងបាន គឺដេកដើរឈរអង្គុយហើយក៏ប្រព្រឹត្តបដិបត្តិព្រះធម៌ ដើម្បីរលាស់ខ្លួនចេញចាកភព បើវិនិច្ឆ័យយ៉ាងហ្នឹងទើបវាត្រឹមត្រូវ សាច់រឿងហ្នឹងវាត្រូវតែអ៊ីចឹង ហើយតាមពិតចំពោះសាច់រឿងគឺទាល់តែមានសតិសម្បជញ្ញៈទើបសម្រេចត្រូវ ទើបវិនិច្ឆ័យទៅត្រូវ ។

យើងត្រូវពិចារណាធម៌ខាងក្នុងឱ្យបានរឿយៗ កុំចេះតែសម្គាល់ថាអ្វីៗទាំងអស់ក្នុងលោកនេះស្អាតមែន ល្អមែនគួរឱ្យយើងចង់បានមែន ទាំងហ្នឹងគឺជាការយល់ខុសទេ ។

ចំពោះការអត់បញ្ញា តែងតែសម្គាល់ថាស្អាត ថាល្អ ហើយចង់បាន យើងកុំឱ្យជ្រប់ងប់ថារបស់ហ្នឹងស្អាតមែន ល្អមែនគួរឱ្យយើងចង់បានមែននោះគឺអត់អ៊ីចឹងទេ ។ យើងត្រូវដឹងថាការសម្រេចក្នុងគំនិតរបស់យើងនេះ ព្រោះអត់មានសតិសម្បជញ្ញៈ ដែលនាំទៅជាការវង្វេងធ្វើឱ្យសម្គាល់របស់ទាំងអស់ដែលមិនស្អាតថាស្អាត ដែលមិនល្អថាល្អ មិនគួរប្រព្រឹត្តខុសឆ្គាំឆ្គងថាគួរតែប្រព្រឹត្តអ៊ីចឹងទៅ ។ ដូចជាការដែលទៅលួចទៅប្លន់ ប្រព្រឹត្តខុសក្នុងកាមេអីហ្នឹងគឺសុទ្ធតែសម្រេចថាគួរតែធ្វើ ហើយនៅពេលដែលសម្រេចហ្នឹងព្រោះអត់មានសតិសម្បជញ្ញៈ ទាំងជឿខ្លួនឯងថាត្រូវតែទៅធ្វើព្រោះរបស់ហ្នឹងវាអ៊ីចឹងមែន ។ ការដែលអត់មានសតិសម្បជញ្ញៈវាធ្វើឱ្យគិតថា រឿងហ្នឹងវាគួរតែយើងទៅដណ្តើមយកមកដោយការលួចប្លន់ ឬទៅប្រព្រឹត្តឆ្គាំឆ្គងយ៉ាងណាៗ គឺឃើញថារឿងហ្នឹងវាគួរតែអ៊ីចឹងមែន តាមពិតអត់គួរនោះទេ កាលណាបើមានសតិសម្បជញ្ញៈរឿយៗក៏បានដឹងថាអ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើតាមការពិត ។

ឃើញថាអំពើឆ្គាំឆ្គងហ្នឹងមិនគួរ ហើយអំពើត្រឹមត្រូវល្អសុចរិតហ្នឹងគួរ គឺការវិនិច្ឆ័យដោយសតិសម្បជញ្ញៈត្រឹមត្រូវទៅតាមសេចក្តីពិតនៃសាច់រឿង តើដើម្បីអ្វី? គឺដើម្បីសមតាមបំណងមនុស្សយើងគ្រប់គ្នាម្នាក់ៗ ចង់បានសេចក្តីសុខទាំងហ្នឹងទើបវាត្រឹមត្រូវ ដូច្នេះសតិសម្បជញ្ញៈនេះជាធម៌ដែលមានឧបការគុណដល់សត្វលោកដ៏ក្រៃលែង ។

យើងកំព្រាអត់មាតាបិតា

អត់អ្នកចិញ្ចឹមបីបាច់ថែរក្សា យ៉ាងណាតែសូមទំនុកបម្រុងសតិសម្បជញ្ញៈ ដែលមានឧបការគុណជាងមាតាបិតាយើងទៅទៀតជាងបុគ្គលណាៗទាំងអស់ ។ យើងត្រូវតបស្នងសងគុណដល់សតិសម្បជញ្ញៈ តើការតបស្នងសងគុណនោះយ៉ាងណា? ក៏គឺចម្រើនសតិសម្បជញ្ញៈហ្នឹងឯង ព្រោះសតិសម្បជញ្ញៈនេះ មានឧបការគុណដ៏ក្រៃលែងណាស់ដល់មនុស្ស និងទេវតា ដូច្នេះដើម្បីសតិនិងសម្បជញ្ញៈចម្រើន គឺត្រូវតែឧស្សាហ៍ស្តាប់ ឧស្សាហ៍ពិចារណារកហេតុរកផល ព្រោះធម៌មានអានិសង្ស... 

ដូចកាលដែលយើងអត់ទាន់មានសទ្ធា យើងមានដឹងថា យើងរស់ដោយសារបុណ្យឯណា យើងកើតមកជាមនុស្ស ដោយសារបុណ្យឯណាយើងមានយើងបានដោយសារបុណ្យ សំពត់ខោអាវស្លៀកពាក់ មានផ្ទះនៅជួបជុំញាតិមិត្តដោយ សារបុណ្យនោះយើងអត់ជឿទេ យើងថាមកពីយើងទាំង អស់ ព្រោះសកាយទិដ្ឋិវាមានកម្រាស់ក្រាស់ក្រៃពេក វាខ្លាំង ពេកអ៊ីចឹងទៅ សកាយទិដ្ឋិនេះវាបិទបាំងនូវហេតុផល វា ធ្វើឱ្យឃើញថាអ្វីៗគឺជារបស់ខ្លួន ហើយខ្លួនជាអ្នកបង្កើត ទាំងអស់ ។ យើងស្តាប់ព្រះធម៌យល់ចូលចិត្តទៅយើងអប់រំ ចម្រើនសតិប្បដ្ឋាន-វិបស្សនា សូម្បីលះសកាយទិដ្ឋិមួយរយ ភាគរយឱ្យជាសមុច្ឆេទមិនទាន់បាន ក៏យើងកាត់បន្ថយ ដោយការពិចារណា និងដោយ **តទង្គប្បហាន** រឿយៗជា ឧបនិស្ស័យទៅ ទើបយើងឃើញអ្វីៗដែលកើតឡើងវាមាន ហេតុរបស់វា ។ វាមិនមែននៅលើសត្វបុគ្គលតួខ្លួនយើង ជាអ្នកធ្វើឱ្យកើតទេ ហើយយើងឃើញថា ប្រសិនបើអ្វីៗវា នៅលើខ្លួនយើងធ្វើឱ្យកើតនោះ វាអត់ចាស់ វាអត់ឈឺ

វាអត់ស្លាប់ វាអត់មានរាគៈ ទោសៈ មោហៈទេ វាអត់មាន សេចក្តីទុក្ខវេទនា វាអត់មានការព្រាត់ប្រាសក្នុងលោកទេ បើអ្វីៗវានៅលើម្នាក់ៗអ្នកធ្វើបាននោះ ខំធ្វើតែរបស់ជាទី ពេញចិត្តទៅ ធ្វើតែរបស់ជាទីប្រាថ្នាទៅ ម៉េចក៏វាមាន អនិដ្ឋារម្មណ៍ដែរ? របស់ដែលជាទីមិនពេញចិត្ត ដូចជា ទុក្ខវេទនានេះ តើអ្នកណាម្នាក់ចង់បាន? គឺអត់ទេ សូម្បី តែម្នាក់ក៏អត់ដែរ ប៉ុន្តែវាអាចកើតឡើងបានដោយសារវា មានហេតុ ដូច្នេះអ្វីៗវាអាស្រ័យនៅលើហេតុ សូម្បីយើង រកទទួលទានមានបានអីក៏ដោយ ក៏វាសុទ្ធតែមានហេតុជា ឧបការមក ប៉ុន្តែមនុស្សយើងវង្វេងទៅជាភ្លេចដល់បុណ្យ ដែលនាំឱ្យមានឱ្យបាននោះ ក៏វានាំឱ្យទៅជាប្រទូស្តនឹង បុណ្យអីចឹងទៅ វាទៅជាមើលងាយបុណ្យ វាទៅជាប្រមាថ សព្វគ្រប់ទៅ ទាំងដែលខ្លួនឯងកំពុងរស់នៅដោយសារ បុណ្យ មានបានដោយសារបុណ្យ ជួបជុំដោយសារបុណ្យ វាទៅជាមើលងាយបុណ្យដោយប្រការផ្សេងៗ ព្រោះអ្វី? ព្រោះសេចក្តីវង្វេង នេះគឺជាទោសសកាយទិដ្ឋិ ។ សូម

មេត្តាចាំផងចុះ ចំពោះសកាយទិដ្ឋិនេះ គឺជាទោសខ្លាំងណាស់ ។

# ភាសិតរបស់ព្រះសារីបុត្ត

**ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ**
**អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ**

ភិក្ខុត្រូវឈប់បរិភោគបាយបួនឬប្រាំពំនូត (មុននឹងឆ្អែត) ហើយឆាន់ទឹក ការប្រព្រឹត្តល្មមប្រមាណត្រឹមតែដើម្បីនៅជាសុខ នៃភិក្ខុដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន ។

យើងស្តាប់ភាសិតរបស់ព្រះសារីបុត្តទៅ គឺភិក្ខុឈប់ឆាន់បាយបួនប្រាំពំនូតមុនពេលឆ្អែត ។ យើងដឹងប្រមាណថាបួនប្រាំម៉ាត់ទៀតនឹងឆ្អែត អ៊ីចឹងក៏ឈប់ទៅ បរិភោគទឹកទៅឆ្អែតតែម្តង ។

ចំពោះភិក្ខុដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាននោះ តើភិក្ខុហ្នឹងមានការប្រព្រឹត្តបដិបត្តិដូចម្តេច? គឺមិន

ល្មោភនៅក្នុងអាហារទេ បើល្មោភអាហារគេហៅថាជ្រូកស្រុក តើអ៊ីចឹងមែនទេ? តាមព្រះធម៌បានលើកយកជ្រូកស្រុកជាឧទាហរណ៍ ទោះជាគេមិនដាក់ទ្រុងក៏មិនខ្វីទោងណា អញដេកស្រួល អញស៊ីស្រាប់ អញគ្រាន់តែស្រែកអ៊ូកៗអញបានស៊ីទាំងស្អូកៗ នេះជាការលើកឧទាហរណ៍បញ្ជាក់អំពីការល្មោភក្នុងកាមគុណ ឬក៏ចំណីអាហារជាដើម តែចំពោះសត្វទទាឬសត្វលលកដែលគេដាក់ក្នុងទ្រុង ទោះជាទ្រុងមាសក៏ដោយ ក៏តែងតែយកចំពុះរុកតាមប្រឡោះទ្រុងដើម្បីរកប្រឡោះប្រហោងនឹងហើរចេញ ទោះជាទ្រុងមាសក៏ដោយក៏មិនត្រេកអរពេញចិត្តដែរ ទាំងនេះសម្រាប់ភិក្ខុដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វាន គឺមិនល្មោភក្នុងអាហារទេ បរិភោគគ្រាន់តែដើម្បីឱ្យប្រព្រឹត្តឥរិយាបថបួនទៅបាន **អលំ ផាសុវិហារាយ** ដើម្បីនៅជាសុខ ហើយក៏ **ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ** នៅបួនឬប្រាំម៉ាត់ទៀតក៏ឈប់ទៅ ឆាន់ទឹកទៅបានហើយ នេះគឺជាភាសិតរបស់ព្រះសារីបុត្ត ។

ចំពោះការសិក្សានៅក្នុងបិណ្ឌបាតប្បច្ច័យនេះ មានការប្រព្រឹត្តទៅដើម្បី **បច្ចយសន្និស្សិតសីល** របស់បព្វជិត គឺសីលហ្នឹងសម្រេចដោយបញ្ញា ពិចារណាធ្វើឱ្យមានការបរិសុទ្ធនាំមកនូវសេចក្តីសង្វេគផងដែរ ។ នៅក្នុងគម្ពីរវិសុទ្ធិមគ្គមានសម្តែងបញ្ជាក់អំពីសាមណេរជាក្មួយរបស់ព្រះសង្ឃ **វខិត្តិត** ដែលមានលោកអ៊ំហ្នឹងឯងជាព្រះឧបជ្ឈាយ៍ ។

នៅពេលដែលសាមណេរជាក្មួយកំពុងតែឆាន់លោកអ៊ំផងជាព្រះឧបជ្ឈាយ៍ផងក៏បានប្រទាននូវឱវាទថា សូមឱ្យលោកកុំដុតអណ្តាតខ្លួនឯងព្រោះការមិនសង្រួម ។ ឱវាទតែប៉ុណ្ណឹងឯងដែលធ្វើឱ្យសាមណេរមានឧបនិស្ស័យ មានសេចក្តីសង្វេគកើតឡើង រលឹកឃើញពាក្យរបស់លោកអ៊ំថា **កុំឱ្យដុតអណ្តាខ្លួនឯងព្រោះការមិនសង្រួម** ក៏មានការចម្រើនវិបស្សនានៅពេលដែលកំពុងឆាន់ ក៏អស់អាសវក្កិលេសទៅដោយតាំងនៅក្នុងភាវៈជាសាមណេរ ជាព្រះអរហន្តមួយអង្គទៅ ដោយមានធម៌ជាទីតាំងនៃសេចក្តីសង្វេគ ព្រោះជាធម្មតាតណ្ហាដែលវាមានការប្រព្រឹត្តទៅ នៅក្នុងរសជាតិ

អាហារក្តី ឬក៏ប្រព្រឹត្តទៅនៅក្នុងផោដ្ឋព្វៈក្តីវាជាភ្លើង ដែលហៅថា **រសតណ្ហា** ក្នុងការបរិភោគអាហារគឺប្រព្រឹត្តទៅដោយតណ្ហា ហើយផោដ្ឋព្វៈដែលវាមានការប៉ះខ្ទប់នឹងកាយនោះ នេះក៏ញ៉ាំងតណ្ហាឱ្យកើតឡើងដោយការមិនសង្រួម មិនបិទនូវទ្វារហៅថា **ផោដ្ឋព្វៈតណ្ហា** ក៏គួរឱ្យយើងបានពិចារណាឃើញដល់តណ្ហា ដែលប្រព្រឹត្តទៅតាមទ្វារទាំង៦ មាន **រូបតណ្ហា** ប្រាថ្នាក្នុងរូបារម្មណ៍ **សទ្ទតណ្ហា** ប្រាថ្នានៅក្នុងសំឡេង **គន្ធតណ្ហា** ប្រាថ្នានៅក្នុងក្លិន ទាំងអស់នេះសុទ្ធតែជាភ្លើង ហើយ **រសតណ្ហា ផោដ្ឋព្វៈតណ្ហា ធម្មតណ្ហា** ភ្លើងហ្នឹងវាមានការដុតភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងដុតចិត្តឱ្យមានសេចក្តីក្រៀមក្រោះ ឆេះរលេះរលួយដោយអំណាចភ្លើងតណ្ហានឹងឯង ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្តែងនៅក្នុងព្រះគាថាធម្មបទថា **នត្ថិ រាគៈ សមោអគ្គិ** ភ្លើងស្មើដោយរាគៈមិនមាន ភ្លើងអ្វីក៏ដោយក្នុងលោកនេះ ពីព្រោះភ្លើងនេះឯងវាញ៉ាំងសេចក្តីក្តៅក្រហាយក្នុងចិត្តសន្តាន ហើយនាំមកនូវ

សេចក្តីទុក្ខជាផលដោយប្រការផ្សេងៗ ម្យ៉ាងទៀតជាពិ-សេសគឺវាអាចដុតកុសលធម៌ឱ្យមានការសាបសូន្យទៅបាន។ កុសលធម៌ដែលនឹងត្រូវចម្រើននោះក៏ត្រូវវិចរិល ក៏ត្រូវបាត់បង់ឆេះខ្ទេចខ្ទីអស់នូវបញ្ញាដែលនឹងត្រូវចម្រើនឡើង ដើម្បីការត្រាស់ដឹងនូវសច្ចធម៌ ប្រៀបបីដូចជាសាស្ត្រាវុធដែលបានកាត់នូវក្បាល គឺបញ្ញាមិនឱ្យមានការងើបរួចអំពីវដ្ត-សង្សារ ក៏ដូចជាងើបមិនរួចអំពីអបាយភូមិអ៊ីចឹងដែរ ។ ភ្លើងហ្នឹងវាមានកម្តៅខ្លាំងក្លា ដែលមានការប្រព្រឹត្តទៅនៅក្នុងជីវិតធម្មតាៗ គ្រាន់តែការឃើញរូប ឮសំឡេងជាដើម ឬថាប្រព្រឹត្តទៅធម្មតាៗនៅពេលដែលប្រើប្រាស់ នូវសំពត់ខោអាវ ឬក៏ចង្ហាន់បិណ្ឌបាតអាហារបរិភោគ វាមានរាគៈតណ្ហាប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ មិនមែនប្រព្រឹត្តទៅក្នុងពេលដទៃណានោះទេ គឺមានជាប្រក្រតីសព្វថ្ងៃហ្នឹងឯងជាធម្មតាជាធម្មជាតិដែលយើងជ្រាបស្រាប់ហើយ កិលេសទាំងអស់ហ្នឹង កាលណាបើវាមិនទាន់បានលះដោយអរិយ-មគ្គគឺវាមិនបាត់បង់ទៅណាទេ គឺនៅតែក្នុងសន្តានចិត្តហ្នឹង

ឯង បើយើងមានការប្រឹងប្រែងប្រព្រឹត្តនូវកុសលខ្លាំងក្លាយ៉ាងណាៗទៅដែលជាលោកិយកុសល ក៏វាក្រាបសំងំតែប៉ុណ្ណឹងឯង វាមិនបាត់បង់ទេ វាក្រាបវាសំងំអ៊ីចឹងទៅ នៅក្នុងសន្តានជារហូតទោះជាយូរអង្វែងយ៉ាងណាក៏ដោយ ដូចជារឿង **កាមឆន្ទៈ ព្យាបាទ** ជាដើម នៅក្នុងព្រហ្មលោកមានអាយុរាប់រយកប្ប សូម្បីអត់កម្រើក អត់កើតឡើងនៅក្នុងជវនប្រព្រឹត្តទៅជា កាមឆន្ទៈ ព្យាបាទ ។ នៅក្នុងសន្តានចិត្តនៃព្រហ្មបុគ្គលគឺអត់មានកាមឆន្ទៈ ព្យាបាទទេ ទោះជានៅរាប់រយកប្ប រាប់រយផែនដីយ៉ាងណាក៏វាអត់កើតឡើងដែរ ប៉ុន្តែនឹងថាឱ្យវាដាច់ទៅ ព្រោះវាខានកើតក្នុងសន្តានហ្នឹងយូរហើយក៏នៅតែអត់ដាច់ មានឱកាសចុតិអំពីព្រហ្មលោកមកជាមនុស្ស ឬជាទេវតាក៏វាកើតឡើង វាមានការប្រព្រឹត្តទៅក្នុងសន្តានចិត្តទៀតអ៊ីចឹងទៅ ចំពោះកាមឆន្ទៈព្យាបាទហ្នឹងនោះ ។ នេះជាការសម្តែងឱ្យឃើញថាលោកិយកុសលសូម្បីរូបសមាបត្តិ អរូបសមាបត្តិក៏មិនមានអំណាចកាត់នូវកិលេសក្នុងសន្តានបានទេ ដូច្នេះហើយបានជា

យើងប្រឹងប្រែងអប់រំចម្រើននូវអរិយមគ្គប្រកបដោយអង្គ៨ប្រការ ពីព្រោះយើងសង្វេគចំពោះវដ្តសង្សារ ។

យើងឃើញអ្នកណាអ្នកណី ដែលប្រព្រឹត្តធ្វើនូវអំពើមិនគួរគប្បី តើយើងគិតថាអ្នកហ្នឹងធ្វើឬ? ដូចជាទៅលួចទៅប្លន់ទៅសម្លាប់អ្នកស្រុកទៅ កាប់ចិញ្ច្រាំទៅ បើយើងខ្វះការពិចារណាគ្រាន់តែឮដំណឹងមកហ្នឹង ក៏បណ្តោយចិត្តឱ្យប្រព្រឹត្តទៅដោយអកុសលផ្សេងៗ ។ យើងស្អប់យើងមិនគាប់ចិត្តទេចំពោះមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ បៀតបៀនអ្នកដទៃ អ្នកស្រុកអ្នកភូមិដោយបាណាតិបាតក្តី ដោយអទិន្នាទានក្តី ដោយកាមេសុមិច្ឆាចារក្តី ទាំងអស់ហ្នឹងយើងមិនចូលចិត្តទេ ប៉ុន្តែយើងពិចារណាបន្តិចទៅមើល តើអ្នកដែលប្រព្រឹត្តអំពើទាំងអស់នេះដោយសារអ្វី? យើងគ្រាន់តែដឹងថាអ្នកហ្នឹងជាអ្នកធ្វើ ប៉ុន្តែយើងកុំភ្លេចថាគឺដោយអំណាចកិលេស បើសិនជាអត់មានកិលេសទេ តើនឹងទៅប្រព្រឹត្តបាណាតិបាត អទិន្នាទានធ្វើអ្វី? តើអ៊ីចឹងមែនទេ? តើដោយសារកិលេសមែនទេ? ហើយកិលេសនេះ គឺជា

កិលេសរបស់បុថុជ្ជន ព្រះអរិយសូម្បីនៅមានកិលេសខ្លះៗ ដូចជាព្រះសោតាបន្នបុគ្គល គឺបានលះនូវបញ្ចវេរាដាច់អស់ហើយ គឺដាច់ដោយសោតាបត្តិមគ្គ ប៉ុន្តែកិលេសរបស់បុថុជ្ជនអាចប្រព្រឹត្តទៅបាននៅក្នុងបញ្ចវេរា មានបាណាតិបាត អទិន្នាទានជាដើម ទាំងនេះដោយសារកិលេសវានាំឱ្យប្រព្រឹត្តធ្វើនូវអំពើហ្នឹងឯង ប៉ុន្តែឥឡូវព្រះគុណម្ចាស់ញាតិញោមបងប្អូនស្រីប្រុសពុទ្ធបរិស័ទទាំងអស់ ពិចារណាខ្លួនឯងវិញមើល តើកិលេសប្រភេទទាំងអស់ហ្នឹងបានលះដាច់ហើយឬនៅ? លះដាច់ដោយសោតាបត្តិមគ្គហើយឬនៅ? ពិតមែនតែក្នុងពេលហ្នឹងយើងមិនទៅសម្លាប់គេ យើងមិនទៅលួចគេមែន ដោយសារយើងមានសីល យើងមានសទ្ធារក្សាសីលទៅ យើងមិនបៀតបៀនអ្នកដទៃក៏ពិតមែន ពិតមែនតែពេលដែលមានសីលដោយសារយើងបានស្ដាប់ព្រះធម៌ យើងបានពិចារណាសេចក្ដីនៃព្រះធម៌ក៏ប៉ុន្តែដរាបណាដែលសោតាបត្តិមគ្គមិនទាន់កើតទេ កុំទុកចិត្តថាអាត្មាអញឈប់ធ្វើបាណាតិបាត ឈប់ប្រព្រឹត្តអទិន្នា-

ទានជាដើម មិនថាជាតិនេះឬជាតិណាៗទេវាអាចប្រព្រឹត្ត ទៅបាន អ៊ីចឹងហើយទើបគួរឱ្យមានសេចក្តីសង្វេគចំពោះ កិលេសដែលឆេះនូវភពទាំង៣នេះ ឆេះឱ្យទ្រលោម តើ ដោយសារអំណាចអ្វី? ដោយអំណាចលោកទាំង៣នេះឯង វាជាអារម្មណ៍នៃរាគៈ ទោសៈ មោហៈ ហើយលោកទាំង៣ នេះឯងដែលត្រូវភ្លើងឆេះដោយអំណាចថាសត្វលោកដែល មានសន្តានចិត្តប្រព្រឹត្តទៅនៅក្នុងអវិជ្ជាដែលមិនទាន់ត្រាស់ ដឹងនូវសច្ចធម៌ ត្រូវភ្លើងហ្នឹងឯងរួបរិតដុតរោល ហើយឱ្យ ប្រព្រឹត្តធ្វើនូវអំពើល្ងង់ខ្លៅទាំងឡាយទាំងពួង ។ ដូច្នេះការ ដែលយើងពិចារណាអ៊ីចឹង យើងឃើញអ្នកដទៃដែល ប្រព្រឹត្តធ្វើនូវអំពើខុស អំពើឆ្កាំឆ្កងផ្សេងៗនោះ យើងក៏ សង្វេគដោយយើងឃើញថា រឿងនេះគឺជារឿងរបស់កិលេស វាជាទោសរបស់កិលេស ។ ចំពោះកិលេសនេះវាខ្លាំង ណាស់ក្នុងមនុស្សដែលប្រព្រឹត្តធ្វើនូវអំពើខុសឆ្កាំឆ្កង មុន ដំបូងវាមិនសូវហ៊ានខ្លាំងទេ ធ្វើម្តងពីរដងទៅដោយការ កាប់សម្លាប់ ដោយការលួចប្លន់ បីដងបួនដងទៅវាចេះតែ

មានឧបនិស្សយប្បច្ច័យឱ្យធ្វើណាធ្វើណីខ្លាំងក្លា ។ ស្តាប់ឮទៅគឺឃើញថាមិនមែនជាអំពើរបស់មនុស្សទេ វាជាអំពើរបស់សត្វតិរច្ឆានសុទ្ធៗអ៊ីចឹងទៅ វាអត់មានមនុស្សធម៌ វាអត់មានមេត្តាករុណាអីទេក្នុងការសម្លាប់ ក្នុងការលួចប្លន់ ក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយផ្សេងៗ ប៉ុន្តែរឿងនេះយើងត្រូវឱ្យដឹងថាសុទ្ធតែអំណាចរបស់កិលេស គឺជារឿងកិលេសទាំងអស់ វាគ្មានមនុស្សឯណាទៀតទេ មនុស្សហ្នឹងគ្រាន់តែបញ្ញត្តិសន្មត់ទេ គឺកិលេសទេដែលជាបច្ច័យនាំឱ្យប្រព្រឹត្តនូវអកុសលកម្មទាំងអស់ រហូតដល់ទៅហ៊ានសម្លាប់មាតាបិតាជាអ្នកឱ្យជីវិត ជាអ្នកឱ្យកំណើតរបស់ខ្លួនទៀត ហើយយើងគិតមើលតើជារឿងអ្វី? គឺជារឿងរបស់កិលេស **(ចំពោះកិលេសនេះមាននៅក្នុងពួកកិលេស១០ ដែលខ្ញុំបាទបានរៀបរៀងជាសៀវភៅមួយឈ្មោះថា សិក្សាសតិប្បដ្ឋាន និងអកុសលធម៌៩កង បានធ្វើរួចរាល់ហើយ នៅតែបោះពុម្ពទេ)** ដូច្នេះសួរថាយើងគួរខ្លាចឬមិនគួរខ្លាចចំពោះកិលេសហ្នឹង? គួរខ្លាចណាស់ ដែលវាសំងំនៅក្នុងចិត្តរបស់យើងហ្នឹងឯង

វានេះជាពួកខ្មោចវាបំបែកគ្នានៅគ្រប់មនុស្សសត្វទាំងអស់ មិនមានច្រទ្បំ មិនមានវង្វេង មិនមានចន្លោះប្រហោង បុគ្គលណាមួយថាមិនបានអាស្រ័យនៅក្នុងបុគ្គលនោះគឺអត់ទេ វានៅគ្រប់មនុស្សម្នាទាំងអស់ ដរាបណាដែលលោកុត្តរកុសលមិនទាន់កើតទេ គឺអត់មានអ្វីបណ្តេញវាបានឡើយ យ៉ាងច្រើនដោយកុសលថ្នាក់ទាន ថ្នាក់សីល ថ្នាក់សមថ គ្រាន់តែធ្វើឱ្យវាក្រាបសំងំតែប៉ុណ្ណឹងឯង ហើយបើសេចក្តីប្រមាទវានៅមាន សត្វលោកហ្នឹងពេលណាប្រមាទវាក៏ងើបឡើងវិញ ប្រមាទទីមួយជាបច្ច័យនាំឱ្យមានការប្រមាទីពីរទីបីជាបន្តបន្ទាប់ ។ ចំពោះការដែលយើងបានពិចារណាយ៉ាងនេះ ក៏នាំឱ្យមានសេចក្តីព្យាយាមប្រឹងប្រែងប្រព្រឹត្តធ្វើនូវអំពើល្អ មិនថាអស់សង្ឃឹមក្នុងសេចក្តីល្អដែលកុសលជាលោកិយនោះទេ ប៉ុន្តែបានសេចក្តីថាមិនជំអក់នៅក្នុងកុសលនោះៗ ។ ពាក្យថាជំអក់នៅហ្នឹងគឺដោយសេចក្តីប្រកាន់ថាកុសលហ្នឹងជាតួខ្លួន កុសលហ្នឹងជារបស់ខ្លួន ហើយខ្លួនជាអ្នកធ្វើឱ្យកើតឡើង ដូច្នេះត្រូវមានការអប់រំ

ចម្រើនសតិប្បដ្ឋាន-វិបស្សនាឱ្យឃើញថា សភាវៈសង្ខារណាៗដែលកើតឡើងនោះព្រោះអាស្រ័យបច្ច័យ ។ យើងត្រូវអប់រំរឿយៗបញ្ញាហ្នឹងចម្រើនឡើងឱ្យឃើញការប្រព្រឹត្តទៅនៃសភាវធម៌នោះឯងមានការកើតឡើងព្រោះអាស្រ័យបច្ច័យហើយនឹងសាបសូន្យទៅ រួចទៅក៏កើតសភាវៈដទៃផ្សេងៗ អត់មានអ្វីជាសត្វបុគ្គលជាតួខ្លួនយើងទេ ។ អប់រំសតិប្បដ្ឋានរឿយៗដើម្បីអ្វី? ដើម្បីកម្ចាត់បង់នូវកិលេសក្នុងសន្តានដែលវាដេកសំងំឱ្យវាស្លាប់តែម្តង ឬឱ្យវាដាច់ជាសមុច្ឆេទតែម្តង ។

## ការពិចារណាសេនាសនប្បច្ច័យ

មានដែនកំណត់ក្នុងការប្រើប្រាស់៥ចំណុចគឺៈ

**១-សីតស្ស បដិឃាតាយ** ការពារនូវធាតុត្រជាក់ ។

**២-ឧណ្ហស្ស បដិឃាតាយ** ការពារនូវកម្តៅ ។

**៣-ឧតុសមកសវាតាតបសីរឹសប្ប សម្ផស្សានំ បដិឃាតាយ** ដើម្បីការពារនូវសម្ផស្សទាំងឡាយ គឺសម្ផស្សរបោមមូសខ្យល់កម្ដៅថ្ងៃ និងពួកសត្វលូនវារ មានពស់ជាដើម ។

**៤-ឧតុបរិស្សយវិនោទនំ** កម្ចាត់បង់នូវអន្តរាយគឺរដូវ បានដល់រដូវដែលមានជាប្រក្រតីទោះក្ដៅក្ដីត្រជាក់ក្ដីជាដើម ។

ត្រង់សេចក្ដីនេះក៏យើងឃើញថា ទី១ទី២ក៏ជាតួរដូវដែរ ក៏ប៉ុន្តែចំពោះ **សីត និង ឧណ្ហ** នេះទៅតាមឱកាសពេលវេលា រីឯចំពោះពាក្យរដូវនេះគឺថាជាប្រក្រតីរាល់ថ្ងៃទោះជារដូវហ្នឹងមានសភាពយ៉ាងណាក៏ដោយ ដែលវានាំឱ្យមានអន្តរាយ ហើយម្យ៉ាងទៀតចំពោះ **បរិស្សយ** នេះលោកចែកទៅ២យ៉ាងដោយឡែកផ្សេងអំពីឧតុហ្នឹងទៅទៀត នៅក្នុង **វិនោទនំ** គឺការកម្ចាត់បង់ក្នុងទីនេះ អាចមានន័យម្យ៉ាងទៀតគឺកម្ចាត់បង់នូវ **ឧតុ** ហើយនឹង **បរិស្សយ** នេះតាមសេចក្ដីពន្យល់ក្នុងព្រះធម៌ ។ **បរិស្សយ** មានការចែក ទៅជា២គឺ **បរិស្សយ** ប្រែថាអន្តរាយប្រាកដ និងអន្តរាយ មិនប្រាកដឬកំបាំង ។

អន្តរាយដែលប្រាកដគឺអន្តរាយកើត អំពីសត្វទាំងឡាយ មានសត្វសាហាវដូចជាសត្វសីហឬសត្វ ខ្លាជាដើម ហៅថា **បាកដបរិស្សយ** ឯចំណែក **បដិច្ឆន្នបរិស្សយ** គឺអន្តរាយខាងក្នុងដែលកើតមានព្រោះរាគៈទោសៈ មោហៈ ជាកិលេស ដូចនេះចំពោះសេនាសនៈក៏ប្រើប្រាស់ដើម្បីការ ពារអន្តរាយទាំងពីរ ។

ចំពោះអន្តរាយប្រាកដនោះយើងមិនសូវឆ្ងល់ទេព្រោះ វាការពារនូវពួកសត្វទាំងឡាយហ្នឹងបានហើយ ប៉ុន្តែចំពោះ អន្តរាយខាងក្នុងតើយ៉ាងម៉េច? ក៏ដើម្បីបិទបាំងនូវការ ឃើញរូបភាពទាំងឡាយផងដែរ ដែលឃើញហើយនាំឱ្យ កើតនូវកិលេសក្នុងសន្តានចិត្ត ឬក៏សំឡេងក្លិនជាដើមដែល បានឮហើយធុំហើយវានាំឱ្យកើតកិលេស ។ សេនាសនៈ គ្រឿងបិទបាំងហ្នឹងក៏វាអាចរារាំងបានផងដែរ កុំឱ្យមានការ ប្រព្រឹត្តទៅដើម្បីបានឃើញឮធុំក្លិនជាដើមនូវរបស់ទាំងអស់ នោះ ជាការការពារនូវអន្តរាយខាងក្នុង នេះជាការជួយបិទ

បាំងនូវទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ហ្នឹងផងដែរ នេះចំពោះពាក្យថា **បរិស្សយ** រីឯ **ឧតុ** សំដៅ យកជាប្រក្រតីរាល់ថ្ងៃមិនថារដូវប្រាំងរដូវវស្សា ឬក៏ខែមន្ត រដូវអីទេ គឺថាជាប់ជានិច្ចជាប្រក្រតី មានសេនាសនៈ កុដិ សាលាផ្ទះសម្បែងទីកន្លែងហ្នឹងឯងជាគ្រឿងរក្សាការពារនូវអន្តរាយគឺឧតុ ឬអន្តរាយទាំងពីរ ។

**៥-បដិសល្លានារាមត្ថំ** ជាប្រយោជន៍ក្នុងការត្រេកអរដើម្បីពួនសំងំ អភិរម្យក្នុងកម្មដ្ឋាន ។

ត្រេកអរក្នុងទីនេះ មិនមែនត្រេកអរដោយអំណាចរាគៈ ដោយអំណាចលោភៈទេ គឺត្រេកអរនៅក្នុងវិវេកធម៌ ត្រេកអរនៅក្នុងការពួនសំងំអភិរម្យក្នុងកម្មដ្ឋាន។ ការត្រេកអរនេះគ្រាន់តែប៉ុណ្ណឹងឯង មិនដើម្បីសង្ហារ បង្អួតគេឯងអីហ្នឹងយ៉ាងណាថាអញហ្នឹងឯងមានកុដិល្អ មានតូបស្អាតធ្វើអស់មួយម៉ឺនដុល្លារ ដើម្បីហ៊ឺហាបង្អួតគេទេ គឺគ្រាន់តែដើម្បីប្រយោជន៍ការពារនូវត្រជាក់ការពារនូវក្តៅ ការពារ

សម្មស្សរបោមមូសខ្យល់ កម្តៅថ្ងៃ សត្វពស់តូចពស់ធំខ្ទួយក្អែបជាដើម ហើយក៏ដើម្បីការពារនូវអន្តរាយផ្សេងៗដែលកើតអំពីរដូវឧតុ ជាពិសេសគឺថា **បដិសល្លានារាមត្ថំ** ដើម្បីអភិរម្យសំងំនៅក្នុងកម្មដ្ឋាន ដែលជាប្រយោជន៍ដល់ការពួនសំងំ ត្រេកអរក្នុងការពួនសំងំតែប៉ុណ្ណោះ ។

## ការពិចារណាគិលានភេសជ្ជប្បច្ច័យ

មានដែនកំណត់នូវការប្រើប្រាស់ថ្នាំកែរោគត្រឹមតែម៉្យាងគត់គឺ **ឧប្បន្នានំ វេយ្យាពាធិកានំ វេទនំ បដិឃាតាយ អព្យាបជ្ឈបរមតាយ** ដើម្បីកម្ចាត់បង់នូវទុក្ខវេទនាអាស្រ័យនឹងជំងឺរោគាផ្សេងៗដែលបានកើតឡើងហើយ មានការអស់នូវសេចក្តីលំបាកជាក្រៃលែង អធិប្បាយថាត្រឹមការជាសះស្បើយនូវរោគនោះឯង ។

**អព្យាបជ្ឈ** គឺការអស់ទុក្ខ **បរម** គឺក្រៃលែង ដូច្នេះ **អព្យាបជ្ឈបរម** គឺវាក្រៃលែងត្រឹមការមិនមានទុក្ខ ។

**វេយ្យាពាធិកានំ** សំដៅយកជំងឺរោគាផ្សេងៗដែលកើតមកពីធាតុកម្រើក ។ ធាតុកម្រើកហៅថា **ព្យាពាធ** ។

ចំពោះជំងឺរោគាផ្សេងៗដែលកើតពីធាតុកម្រើកហ្នឹងហៅថា **វេយ្យាព្យាធិក** ដូច្នេះការដែលប្រើប្រាស់នូវគិលានភេសជ្ជៈនេះដើម្បីកម្ចាត់បង់នូវទុក្ខវេទនា ។

ចំពោះទុក្ខវេទនានេះវាជាអកុសលវិបាក (គឺជាផលរបស់អកុសលកម្មឯណានិមួយ) ដែល **វេទនំ** គឺសំដៅយកទុក្ខវេទនាជាអកុសលវិបាក ប៉ុន្តែអកុសលវិបាកហ្នឹងឯងអាស្រ័យនឹងជំងឺរោគាផ្សេងៗ ដែលកើតមានព្រោះធាតុកម្រើក ព្រោះជំងឺវាមានច្រើនណាស់ ។ ជំងឺខ្លះកើតអំពីបាបកម្មឯណានិមួយអ៊ីចឹងទៅ ដែលកម្មនៅតែមានឱកាសជាបច្ច័យឱ្យឈឺនោះគឺមើលមិនជាទេ ប៉ុន្តែវាមានជំងឺខ្លះកើតមានព្រោះធាតុកម្រើក មិនកើតអំពីកម្មទេ ប៉ុន្តែទុក្ខវេទនាជាអកុសលវិបាកកើតអំពីកម្ម តែចំណែករោគនោះមិនកើតអំពីកម្មទេគឺកើតអំពីធាតុកម្រើក ដូចនេះអាចដើម្បីប្រើប្រាស់នូវថ្នាំផ្សេងៗសម្រួលធាតុហ្នឹងទៅ ជំងឺរោគដែល

កើតពីធាតុកម្រើកហ្នឹងវាអាចជាសះស្បើយទៅបាន ហើយប្រយោជន៍នៃការប្រើប្រាស់ថ្នាំហ្នឹងគឺត្រឹមតែប៉ុណ្ណឹងឯង ។ **អព្យាបជ្ឈបរមតាយ** គឺត្រឹមការដែលមិនមាននូវសេចក្តីទុក្ខយ៉ាងក្រៃលែង បានសេចក្តីថាត្រឹមតែការជាសះស្បើយរោគតែប៉ុណ្ណឹងទេ ។

នៅក្នុងការដែលយើងសិក្សាអំពីធម៌ទាំងអស់នេះ ក៏អាចជាគ្រឿងសង្វេគចំពោះសង្ខារធម៌ទាំងអស់ ដែលវាអត់មានយើងជាម្ចាស់នោះ គឺសត្វលោកអត់មានអ្វីជារបស់ខ្លួនទេ ហើយក៏មិនជាឥស្សរៈជាធំអីលើជីវិតខ្លួនឯងឡើយ កើតមកហើយវាមានជរា ព្យាធិ មរណហ្នឹងឯងជាម្ចាស់ គ្របសង្កត់ដល់នូវការវិនាសទៅវិញគ្រប់សង្ខារធម៌សូម្បីមិនមានវិញ្ញាណគ្រប់គ្រងក៏ដោយ ដើមឈើ ព្រៃភ្នំ,... កើតមកហើយរួចទៅក៏ស្លាប់ទៅវិញទៅ ។

នៅក្នុងសេចក្តីនេះ យើងគួរតែពិចារណាឱ្យបានរឿយៗ សូម្បីក្នុងបឋមវ័យក៏ដោយ វ័យក្មេងវ័យកណ្តាលហ្នឹងក៏ដែរ ត្រូវពិចារណាអំពីអាយុសង្ខារឱ្យបានរឿយៗ

ដើម្បីឱ្យឃើញថាដែលកើតមកហើយ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណនេះតែងតែមានការប្រែប្រួលជាធម្មតា អត់មាននៅក្នុងអំណាចនៃសត្វបុគ្គលណាទេ កន្លែងនេះសំខាន់ណាស់ ដើម្បីកុំឱ្យវាវង្វេងនៅពេលដែលជិតស្លាប់ ព្រោះកាលណាបើយើងមិនបានពិចារណាទេ ដល់ពេលវាមានវិបត្តិកើតឡើងវិបរិតប្រែប្រួលនូវរូបកាយនេះ វានាំឱ្យតក់ស្លុតថា ឃី!អញម៉េចក៏ទៅជាអ៊ីចឹង? អញស្លាប់ទេដឹង? អញវិនាសចាកទ្រព្យសម្បត្តិ ចាកបងប្អូនកូនចៅ អញខានឃើញលោកនេះតទៅទៀតទេដឹង? វាភ័យតក់ស្លុតណាស់ ដោយអំណាចនៃការភ័យតក់ស្លុតនេះនាំឱ្យវង្វេងបាន មិនអាចដើម្បីនឹងមានចិត្តស្ងប់រំងាប់បានទេ តើមកអំពីអ្វី? មកអំពីមិនបានពិចារណាឱ្យបានរឿយៗទេ គឺរវល់តែខ្លួនអញអ្វីៗជារបស់អញ ហើយក៏សប្បាយនឹងគ្រឿងបោកបញ្ឆោតក្នុងលោកនេះ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាគ្រឿងបោកបញ្ឆោត ដែលសត្វលោកយើងអាប់ឥតប្រាជ្ញានោះក៏ចេះតែសប្បាយរីករាយទៅ ហើយក៏ជាប់ក្នុងអន្ទាក់ផងដែរ

ម៉្លោះហើយមិនបានពិចារណាពីសង្ខារធម៌ប្រែប្រួលទេ ដល់អីចឹងទៅកុំចាំបាច់និយាយថា ឈឺបម្រុងស្លាប់អីពីក្មេង តែចាស់ហើយហ្នឹងក៏មិនព្រមស្លាប់ដែរ ៥០,៦០,៧០,៨០,៩០, ១០០ឆ្នាំហើយហ្នឹងក៏ដោយ ដល់ពេលកម្លាំងថមថយចុះទៅមានសភាពញាប់ញ័រក្នុងរូបកាយហ្នឹងឯងខុសប្រក្រតីធម្មតាក៏ភ័យតក់ស្លុត គឺភ័យតក់ស្លុតនឹងស្លាប់ហ្នឹងឯង ។ មិនដឹងជាគិតថាចង់រស់ឱ្យនៅដល់២០០ ឬ៣០០ឆ្នាំយ៉ាងម៉េចនឹងកើត បើអាយុខេយ្យវាត្រឹមតែប៉ុណ្ណឹង តើមកអំពីអ្វី? មកពីមិនធ្លាប់បានពិចារណា ដល់ទៅវាធ្វើឱ្យភ័យអីចឹងក៏នាំឱ្យវង្វេងគឺការដែលមិនមានស្មារតី ដល់ទៅមានការវង្វេងហើយវាជារឿងមួយដែលអន្ទះអន្ទែងនៅពេលជិតស្លាប់ផងបរលោកនោះគួរឱ្យស្រៀវស្លុតទៀតផង ដូច្នេះយើងត្រូវតែបំពេញបុណ្យកុសលឱ្យបានច្រើនៗដើម្បីជាទីពឹង ហើយនៅលើខ្លួនយើងម្នាក់ឯង ដែលជួយខ្លួនឯងឱ្យបានបុណ្យច្រើនៗនោះ គឺត្រូវបានសន្សំក្នុងសន្តាន ។

នៅពេលឈឺ ឧទាហរណ៍ថា ដូចជាញោតិញោម អង្គុយយូរទៅឈឺក្បាលជង្គង់ ឈឺចង្កេះ ឬក៏លើកដៃទៅឈឺ ការដែលឈឺហ្នឹងគឺជាទុក្ខវេទនាអាស្រ័យត្រង់កន្លែងនោះកើតឡើង ដូច្នេះគួរយើងឃើញថាទុក្ខវេទនាអាស្រ័យកន្លែងនោះកើតឡើងពិតប្រាកដ ឬក៏យើងនៅត្រង់កន្លែងហ្នឹង? នៅពេលឈឺក្បាលជង្គង់ តើមានខ្លួនយើងឈឺក្បាលជង្គង់ហ្នឹងទ ឬក៏មានតែទុក្ខវេទនា? គឺទុក្ខវេទនា អ៊ីចឹងយើងក៏ឃើញទុក្ខវេទនាមិនមែនជាខ្លួនយើង ដែលកើតឡើងអាស្រ័យកាយប្បសាទ កាយវត្ថុហ្នឹងជាបច្ច័យហើយ កើតឡើងកន្លែងហ្នឹងឯង ដោយសារវាមានផោដ្ឋព្វៈប៉ះខ្ទប់

ទោះជាទុក្ខវេទនាត្រង់កន្លែងណាក៏ដោយ បើមានសតិរលឹករឿយៗទៅក្នុងរូបកាយនេះ ទុក្ខវេទនាកើតឡើងក៏ឃើញច្បាស់ថា ទុក្ខវេទនាហ្នឹងមិនមែនជាខ្លួនយើងទេ វាអាស្រ័យនឹងកាយប្បសាទ ។ យើងនិយាយដោយសន្ទត់ទៅថា ត្រង់ដៃក៏ដោយ ត្រង់ជើងក៏ដោយ ត្រង់កន្លែង

ណា១ក្នុងរូបកាយនេះក៏ដោយ គឺមិនមែនជាខ្លួនយើងទេ ត្រង់កន្លែងនោះ១ គឺទុក្ខវេទនាតែប៉ុណ្ណោះ ទាំងនេះវាមានធាតុប្រាកដឡើង វាអាចទៅជាវេទនានុបស្សនាសតិប្បដ្ឋាន ដែលព្រះអង្គទ្រង់សម្តែងក្នុងសតិប្បដ្ឋាន៤ គឺមានវេទនាហ្នឹងឯង ។ សញ្ញាវាមិនប្រាកដទេ តាមពិតមានវេទនាកើតឡើងត្រង់ណាវាមានសញ្ញា សង្ខារ វិញ្ញាណត្រង់នោះ ប៉ុន្តែសភាវៈដែលប្រាកដច្បាស់ គឺវេទនា និងវិញ្ញាណ គឺចិត្តដែលបានដឹងនូវអារម្មណ៍នោះក្នុងខណៈនៃទុក្ខវេទនា ដូចនេះទើបព្រះអង្គទ្រង់ត្រាស់សម្តែងនូវ វេទនានុបស្សនា-សតិប្បដ្ឋាន និងចិត្តានុបស្សនាសតិប្បដ្ឋាន ពីព្រោះសភាវៈហ្នឹងវាប្រាកដច្បាស់ ហើយសតិរលឹកបានឃើញថា វាមិនមែនជាតួខ្លួនយើង យ៉ាងនេះជួយសម្រួលចិត្តកុំឱ្យវាមានភាពភ័យតក់ស្លុតអន្ទះសា ពីព្រោះជាការចម្រើនប្រាជ្ញា-ស្មារតី ។ កាលណាបើមិនមែនជាខ្លួនយើងហើយត្រង់ទុក្ខវេទនាហ្នឹង វាក៏ធ្វើឱ្យចិត្តស្ងប់រំងាប់ហើយ ។ វាអត់មានខ្លួនយើងអ្នកឈឺ វាអត់មានខ្លួនយើងអ្នកលំបាក ហើយក៏វា

អត់មានខ្លួនយើងអ្នកស្លាប់ផងដែរ ព្រោះការស្លាប់នេះវា គ្រាន់តែជាធាតុបែកធ្លាយតែប៉ុណ្ណឹងទេ ខ្យល់ដង្ហើមចេញ ចូលហ្នឹងវាឈប់ចេញចូលទៅ

វាមានបាត់យើងឯណាអត់ទេ គឺវាអត់មានបាត់យើងទេ វាគ្រាន់តែខ្យល់ហ្នឹងវាឈប់ចេញ វាឈប់ចូលតើ! ហើយតើខ្យល់ចេញចូលហ្នឹងជាខ្លួនយើង

ដែរសព្វថ្ងៃហ្នឹង? ដកដង្ហើមចេញចូលហ្នឹង ចេញបាត់ទៅ ចូលមក១ តើជាខ្លួនយើងទេ? អត់ទេ ហើយដល់ពេល ស្លាប់វាមានយើងឯណាស្លាប់ វាគ្រាន់តែខ្យល់ចេញចូល ហ្នឹងវាឈប់ចេញចូលតើ! ហើយយើងចេះតែភ័យអញ ស្លាប់ៗ វាអត់តែមានខ្លួនឯងស្លាប់ផង គ្រាន់តែអស់ខ្យល់ សោះក៏ចេះតែភ័យថាខ្លួនឯងស្លាប់ ។ ទាំងអស់នេះវាទាល់ តែយើងដឹងអ៊ីចឹង ទើបអាចសម្រួលចិត្តឱ្យស្ងប់រំងាប់បាន ហើយដល់តែយើងមិនបានអប់រំសតិ-បញ្ញាទេ គឺដឹងតែពី រឿងថាអញស្លាប់ៗ ហើយដល់តែថាអញស្លាប់គឺភ័យហើយ ចំពោះរឿងភ័យនេះវាមិនមែនជារឿងល្អទេ វានាំឱ្យចិត្ត

សៅហ្មង វានាំឱ្យវង្វេងសព្វគ្រប់ទាំងអស់ ។ អ្នកដែលមានអធ្យាស្រ័យកាចពីដើមនោះ ក៏រិទ្ធតែកាចនៅពេលជិតស្លាប់ អ្នកដែលមានអធ្យាស្រ័យអីយ៉ាងណា១ វាធ្វើឱ្យវង្វេងនៅពេលជិតស្លាប់ហ្នឹងឯង ទៅតាមអំណាចនៃកិលេសដែលខ្លួនធ្លាប់មានមក អត់ធ្លាប់បានអប់រំនូវកុសលធម៌ឯណាដើម្បីនឹងលះ ដើម្បីនឹងគ្របសង្កត់នូវកិលេសនោះ១ ដូច្នេះហើយបានត្រូវអាស្រ័យប្រាជ្ញាស្មារតី គឺសតិសម្បជញ្ញៈនេះដើម្បីបានជាអធិបតីក្នុងដំណើរផ្លូវរបស់យើង ឆ្ពោះទៅកាន់ព្រះនិព្វាន ។

នៅក្នុងកំណើតជាមនុស្សនេះ យើងពិចារណាមើលតាំងតែពីនៅក្នុងផ្ទៃនៃមាតា គឺត្រូវបានទទួលនូវភារៈគ្រប់គ្រងបញ្ចក្ខន្ធដែលជាសំបុកនៃរោគ ។ ខ្លះកើតមកមានជំងឺរោគាជាប្រចាំ រហូតខ្លះទៀតពេញវ័យកំលោះក្រមុំហើយក៏មានរោគប្រចាំកាយ នេះគឺជាភារៈដែលមនុស្សយើងត្រូវទទួលនូវបញ្ចក្ខន្ធហ្នឹងឯង ហើយគ្រប់គ្នាត្រូវធ្វើការងារដើម្បីបាននូវអាហារបរិភោគ ដើម្បីបាននូវបច្ច័យ៤ បញ្ចក្ខន្ធ

នេះចងមនុស្សយើងឱ្យជាប់នឹងការងារ អាជីពចិញ្ចឹមជីវិត តាំងតែពីបានចូលធ្វើការ បន្ទាប់ពីមាតាបិតាចិញ្ចឹមបីបាច់ ថែរក្សាទំនុកបម្រុងឱ្យរៀនសូត្រហើយ ទើបចេញធ្វើការ ងារឬប្រកបមុខរបរជំនួញផ្សេងៗដើម្បីចិញ្ចឹមជីវិតរហូតមក គឺរវល់ណាស់ ក៏ដោយសារតែបញ្ចក្ខន្ធនេះឯងដែលធ្វើឱ្យ យើងរវល់ ។ ដែលថាយើងហ្នឹងគឺសន្មត់ក្រសែរបស់ខន្ធ មួយសង្សាររវដ្តមក មិនដឹងទីបំផុតពីខាងដើមត្រឹមណាមក ទេរហូតមកដល់សព្វថ្ងៃនេះ ក៏សន្មត់ថាយើង ហើយតើអ្វី ដែលចងឱ្យយើងរវល់នឹងអាជីពការងារ ទាំងនៅក្នុងស្រុក ខ្មែររហូតដល់ស្រុកផ្សេងៗទៀតទូទាំងពិភពលោកនេះ? គឺ ជាបញ្ចក្ខន្ធដែលជាជីវិតហ្នឹងឯង ។ នេះគឺជាចំណងមួយ ដែលយើងត្រូវឃើញ ហើយណាមួយកិលេសចងយើងឱ្យ ជាប់នឹងទីកន្លែង ជាប់នឹងអ្វីៗដែលយើងស្រឡាញ់ពេញចិត្ត ហើយណាមួយទៀត គឺចំណងកម្មចងឱ្យយើងជាប់នឹងភព ៣១ជាន់ សូម្បីទៅជាទេវតា ទៅជាព្រះឥន្ទ្រ ទៅជា ព្រះព្រហ្ម ទោះជារូបព្រហ្មក្តីអរូបព្រហ្មក្តីក៏ដោយ ពេលអស់

បុណ្យក៏មកជាសភាពបែបនេះវិញ នេះគឺជាចំណងនៅក្នុង វដ្តសង្សារ ។

ចំពោះបញ្ចក្ខន្ធនេះ ញាតិញោមបងប្អូនប្រុសស្រីទាំងអស់ មានព្រះករុណាគុណម្ចាស់ជាអធិបតីបានពិចារណាទៅក៏គង់ជ្រាប គឺភារៈប្រភពនៃបញ្ហាគឺវាជាឧបាទានក្ខន្ធ៥នេះឯង ដែលធ្វើឱ្យយើងប្រឹងប្រែងស្វែងរកបច្ច័យ៤ ហៅថា **ទិដ្ឋធម្មិកដ្ឋប្រយោជន៍** ប្រយោជន៍ក្នុងបច្ចុប្បន្នគឺបច្ច័យ៤ហ្នឹងឯងដែលដោយសារតែមានបញ្ចក្ខន្ធ ។ កន្លែងហ្នឹងសមគួរយើងពិចារណាមើលឱ្យឃើញថា ដោយសារតែការចិញ្ចឹមជីវិតនេះនាំឱ្យយើងលំបាកលំបិនសព្វគ្រប់ ។ ពេលឈឺត្រូវរកថ្នាំ ត្រូវរកពេទ្យសព្វគ្រប់ថែមទៀត ហើយសូម្បីតែ **សម្បរាយិកដ្ឋ** ប្រយោជន៍នៅក្នុងលោកខាងមុខ ដែលយើងត្រូវគេចពីអបាយភូមិ ត្រូវរកសុគតិភពហ្នឹងយ៉ាងណាៗក៏ដោយសារតែមានបញ្ចក្ខន្ធ ។ ដែលយើងត្រូវរកសុគតិភពក្នុងដំណើរជីវិតឱ្យយើងបានសុខនោះ ក៏ដោយសារតែមានជីវិតមានបញ្ចក្ខន្ធហ្នឹងឯង អ៊ីចឹងបានជានៅក្នុងព្រះពុទ្ធ-

សាសនានេះ ពេលយើងស្ដាប់យើងសិក្សាដល់ទីបំផុតទៅ យើងនឹងបានឃើញនូវប្រយោជន៍មួយទៀត ដែលហៅថា **បរមត្ថ** គឺប្រយោជន៍ដ៏ក្រៃលែង ប្រយោជន៍ហ្នឹងគឺផុតអំពីបញ្ចក្ខន្ធ ។ កាលណាបើផុតអំពីបញ្ចក្ខន្ធហើយ ចំពោះទុក្ខកង្វល់នៅក្នុងចិត្តក៏ត្រូវស្ងប់រំងាប់ ។

នៅក្នុងព្រះពុទ្ធសាសនាមាន **បរមត្ថប្រយោជន៍** គឺជាប្រយោជន៍ដ៏ក្រៃលែងហ្នឹងគឺការរួចផុតពីខន្ធ៥នេះឯង ។ កាលណាបើយើងសិក្សាពីបញ្ចក្ខន្ធ ឱ្យឃើញច្បាស់សភាពពិតនៃបញ្ចក្ខន្ធអ៊ីចឹងទៅ ការរលត់តណ្ហានឹងសម្រេចបានដល់ពុទ្ធបរិស័ទយើង ។ យើងប្រគល់បច្ច័យ៤ឱ្យបញ្ចក្ខន្ធឬក៏អ្វីៗសម្បត្តិក្នុងភពនេះសម្រាប់បញ្ចក្ខន្ធតែប៉ុណ្ណោះ ។ កាលណាបើយើងបានកំណត់ដឹងនូវបញ្ចក្ខន្ធដោយភាពមិនទៀង ជាទុក្ខ ជាអនត្តាច្បាស់លាស់ហើយនោះ យើងក៏ត្រូវរលត់ឧបាទាន និងរលត់តណ្ហា ។ ការរលត់នូវតណ្ហានេះឯងដែលជាទីមិនមាននូវកង្វល់ មិនរវល់នឹងសម្បត្តិក្នុងភពកន្លែងនេះដែលជាទីពឹងសម្រាប់ពុទ្ធបរិស័ទយើង ដែលជា

ទីពឹងដ៏ក្រៃលែង ព្រោះបើមិនអ៊ីចឹងទេ មនុស្សយើងស្វែងរកសេចក្ដីសុខទាក់ទងនឹងរបស់ខាងក្រៅទាក់ទងនឹងបច្ច័យ ៤ ទាក់ទងនឹងលាភ ទាក់ទងនឹងយស ហើយយើងបានសុខដោយសាររបស់ទាំងអស់ហ្នឹងឯង ។ ចំពោះរបស់ទាំងអស់នោះវានៅក្នុងការប្រែប្រួល ទាំងយើងជាអ្នកបាននូវរបស់ហ្នឹងក៏ប្រែប្រួល ចាស់ទៅ ឈឺទៅ ក៏ស្លាប់ទៅ ម៉្លោះហើយយើងមិនអាចបានសុខនឹងរបស់ទាំងអស់ឱ្យស្ថិតស្ថេរទៀងទាត់បានទេ វាគ្រាន់តែមួយគ្រាមួយរយៈតែប៉ុណ្ណោះ។ ចំពោះអ្វីៗខាងក្រៅ ទោះជាទ្រព្យសម្បត្តិក៏ដោយ ភរិយាស្វាមីកូនប្រុសស្រីក៏ដោយ គ្រាន់តែជារបស់មួយគ្រាតែប៉ុណ្ណោះ វាស្ថិតនៅក្នុងភាពចាស់ជរាគ្រាំគ្រា មានជំងឺមានអាពាធ ហើយស្ថិតនៅក្នុងភាពមិនទៀង របស់ទាំងអស់ហ្នឹងមិនអាចជាទីពឹងឱ្យយើងបានសេចក្ដីសុខពិតប្រាកដទេ ដូច្នេះនៅក្នុងព្រះពុទ្ធសាសនានេះ មានព្រះធម៌ឱ្យយើងអប់រំបញ្ញា គ្រប់គ្រងចិត្តដោយបញ្ញា ស្វែងរកសេចក្ដីសុខក្នុងចិត្ត ។ បច្ច័យ៤គ្រាន់តែជាទីអាស្រ័យ តែត្រូវស្វែងរក

សេចក្ដីស្ងប់ក្នុងចិត្ត នេះទើបស្ថិតស្ថេរនៅក្នុងចិត្តរហូតដល់ផុតពីការប្រកាន់បញ្ចក្ខន្ធ ។ ស្ងប់នូវសេចក្ដីកង្វល់ក្នុងបច្ច័យ៤ ស្ងប់នូវសេចក្ដីកង្វល់ក្នុងសម្បត្តិក្នុងភព កាលណាបើរលត់តណ្ហា ទោះជាមិនរលត់មួយរយភាគរយក៏ដោយឱ្យតែយើងដើរនៅក្នុងផ្លូវក្នុងការរំលត់តណ្ហានេះ គឺចេះតែបានស្ងប់ឡើងៗក្នុងចិត្តរបស់យើង ។ ដែលយើងចាំបាច់ត្រូវការបច្ច័យ៤ មាសប្រាក់ទ្រព្យសម្បត្តិនេះ យើងនឹកឃើញថាយកមកឱ្យយើង ចិញ្ចឹមយើង ទាំងហ្នឹងដោយសារយើងប្រកាន់បញ្ចក្ខន្ធថាជាយើង ហើយយើងអរនឹងបច្ច័យ៤ យើងអរនឹងទ្រព្យសម្បត្តិទៅ ហើយយើងអរថាយើងបានសប្បាយទៅ នេះមកពីយើងមិនទាន់បានកំណត់ដឹងនូវបញ្ចក្ខន្ធនេះទេ ដល់តែយើងកំណត់ដឹងនូវបញ្ចក្ខន្ធទៅបានយើងឃើញថា បើកុំតែបញ្ចក្ខន្ធកើតឡើង ការរវល់ការកង្វល់មិនមានតែម្ដង ។ បើកុំតែមានបញ្ចក្ខន្ធកើតឡើង តើមានទុក្ខមានកង្វល់មានរវល់ហ្នឹងមកពីណា? ដល់ទៅបញ្ចក្ខន្ធកើតមកយើងត្រូវការរកអាហារបរិភោគ ដល់

បានមកយើងអរយើងសប្បាយ ដល់ទៅអរនឹងសំលៀក បំពាក់ ទ្រព្យសម្បត្តិ ផ្ទះសម្បែងទីកន្លែងអរៗៗទៅជាភ្លេច គឺភ្លេចថាមេរវល់មេកង្វល់គឺបញ្ចក្ខន្ធ ដល់អ៊ីចឹងទៅយើង រវល់តែអរសប្បាយ យើងអត់បានកំណត់ដឹងនូវបញ្ចក្ខន្ធ ដើម្បីចេញចាកពីបញ្ចក្ខន្ធទេ ។ យើងរក្សានូវបញ្ចក្ខន្ធហ្នឹង ឯងដោយឧបាទាន ដើម្បីចង់បាននូវការសប្បាយពីបច្ច័យ៤ ពីលាភពីយសក្នុងលោកនេះ ប៉ុន្តែការផ្តើមមុនដំបូងដោយ បញ្ចក្ខន្ធជាមេរវល់ជាមេកង្វល់ សម្រាប់ឱ្យយើងត្រូវការ បច្ច័យ៤ សម្រាប់ឱ្យយើងស្វែងរកសម្បត្តិក្នុងភព គឺដោយ សារតែបញ្ចក្ខន្ធហ្នឹងឯង ។ ដូចជាជំងឺអ៊ីចឹង ដោយសារ ជំងឺហ្នឹងវាកើតមកទើបយើងត្រូវការថ្នាំ ត្រូវការលោកគ្រូ ពេទ្យ ត្រូវការមន្ទីរពេទ្យដែលសំខាន់សម្រាប់អ្នកឈឺណាស់ ប៉ុន្តែយើងពិចារណាមើលទៅយើងជ្រាបថា ប្រសិនបើមិន មានរោគទេ មិនមានជំងឺទេ តើថ្នាំហ្នឹងសំខាន់សម្រាប់ យើងទេ? អត់ទេ លោកគ្រូពេទ្យមានចាំបាច់អីសម្រាប់ យើងបើយើងអត់ឈឺផង មន្ទីរពេទ្យយើងមានគិតថា យី!

នៅផ្ទះដូចជាអផ្សុកណាស់ ទៅរកទទួលទានដំណេកនៅពេទ្យបានពីរបីយប់ យើងមិនដែលគិតទៅទទួលដំណេកនៅមន្ទីរពេទ្យឯណា ព្រោះយើងវាអត់ឈឺ ដែលសំខាន់ចាំបាច់ដោយសារតែយើងឈឺទេតើ ទើបពេទ្យហ្នឹងសំខាន់សម្រាប់អ្នកឈឺ ទើបថ្នាំហ្នឹងសំខាន់ជំនាញរបស់លោកគ្រូ

ពេទ្យសំខាន់ណាស់សម្រាប់មើលអ្នកជំងឺ នេះដោយសារតែយើងមានជំងឺទេ យ៉ាងណាមិញបញ្ចក្ខន្ធនេះជារោគទើបយើងចាំបាច់ត្រូវការបច្ច័យ៤ ដូច្នេះសូមឱ្យយើងសម្លឹងមើលត្រង់ដែលរួចពីបញ្ចក្ខន្ធផង កុំឱ្យយើងសម្លឹងមើលទៅតែក្នុងបច្ច័យ៤ជាទីត្រេកអរពេញចិត្តតែម្យ៉ាងនោះ ។ យើងសម្លឹងមើលត្រង់ដែលថាមិនមានរោគ ការជារោគ គឺនៅត្រង់ការមិនមានបញ្ចក្ខន្ធ ។ ការរួចផុតអំពីបញ្ចក្ខន្ធនេះគឺសំខាន់ណាស់ ការស្ងប់រំងាប់ ការមិនកង្វល់ ការមិនរវល់ការមិនមានតណ្ហាទៅនៅក្នុងបច្ច័យ៤ នេះទើបជាទីបំផុតនៃទុក្ខ ។ ការផុតពីបញ្ចក្ខន្ធ គឺការផុតនេះសំខាន់ណាស់

កាលណាបើយើងមើលឃើញរូបហ្នឹងច្បាស់ ជាមហាភូតរូប ជាឧបាទាយរូប ដូចជាដីទឹកភ្លើងខ្យល់នេះ ព្រះសម្មាសម្ពុទ្ធ សម្ដែងក្នុងបិដកលេខ៣៥ ក្នុងសំយុត្តនិកាយ សឡាយ-តនវគ្គ អសិវិសូបមសូត្រ ព្រះអង្គសម្ដែងថា ដីទឹកភ្លើង ខ្យល់ជាអសិរ្ពិស ហើយព្រះរាជាគឺកម្ម ។ កម្មហ្នឹងបានឱ្យ អសិរ្ពិស ដែលមានពិសដ៏ពន្លឹកហ្នឹងមកយើងជាអ្នកទោស នេះចិញ្ចឹមអសិរ្ពិសហ្នឹងឯង ហើយដល់ពេលវាខឹងគឺវាខាំ ។ ពស់ដីពស់ទឹកពស់ភ្លើងពស់ខ្យល់យើងពិនិត្យមើល យើង ចិញ្ចឹមពស់៤ដាក់ទ្រុង ហើយយើងមានគិតថាយើងហ្នឹង ចិញ្ចឹមខ្លួនយើងឯណា នេះដែលយើងចាប់ពស់៤យកមក ចិញ្ចឹម យើងមានគិតថាចិញ្ចឹមយើងឯណា គឺចិញ្ចឹមពស់ ទេតើ ឱ្យបាយឱ្យទឹកឱ្យចំណីរាល់ថ្ងៃ យើងមានគិតថា ចិញ្ចឹមយើងឯណា យ៉ាងណាមិញដីទឹកភ្លើងខ្យល់ គឺជា អសិរ្ពិសដែលនាំឱ្យឈឺ នាំឱ្យលំបាកដោយសារអសិរ្ពិស ហ្នឹងឯង សូមយើងធ្វើទុកក្នុងចិត្តអីចឹងរឿយៗទៅនឹងបាន ដឹងថាយើងកំពុងចិញ្ចឹមអសិរ្ពិស ។ ដីទឹកភ្លើងខ្យល់ដែល

ឈើគ្រប់បែបគ្រប់យ៉ាងដោយសារអសរិទ្ធិសវាខាំ ពស់ដីវាខាំ យ៉ាងម៉េច? ពស់ទឹកវាខាំយ៉ាងម៉េច? ពស់ភ្លើងវាធ្វើឱ្យក្តៅយ៉ាងម៉េច? ពស់ខ្យល់វាធ្វើឱ្យចាក់ឱ្យចុកឱ្យសៀតយ៉ាងម៉េច? បើអត់ដីទឹកភ្លើងខ្យល់ទេ មនុស្សយើងចេះឈឺមកពីណា? នេះដែលសមគួរយើងធ្វើទុកក្នុងចិត្តអ៊ីចឹងទៅចិត្តហ្នឹងក៏វាគ្រោកដែរ វាគ្រោកអំពីការប្រកាន់ខ្លួនឯងនេះ ហើយវេទនា សញ្ញា សង្ខារ វិញ្ញាណជានាមធម៌ដែលដឹងនូវអារម្មណ៍នេះទៀតដែលយើងត្រូវសិក្សា ។ ព្រះករុណាគុណម្ចាស់ញាតិញោមបងប្អូនស្រីប្រុសត្រូវសិក្សាឱ្យយល់ថាតើអ្វីដែលជាអារម្មណ៍? អារម្មណ៍គឺអ្វីដែលចិត្តដឹង ។ អ្វីដែលចិត្តដឹងហ្នឹងឯងដែលហៅថាអារម្មណ៍ វាជារបស់ខាងក្រៅ ។ ដែលហៅថាអារម្មណ៍គឺជារបស់ខាងក្រៅ រីឯចិត្តជារបស់ខាងក្នុង សូមពុទ្ធបរិស័ទព្រះមេត្តា និងមេត្តាចាំកន្លែងហ្នឹងឱ្យបានច្បាស់ផងដែរ ។ វិញ្ញាណដឹងនូវអ្វីណាគឺអ្វីនោះហៅថាអារម្មណ៍មាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាអារម្មណ៍ ។

ចំពោះអារម្មណ៍នេះគឺជារបស់វិញ្ញាណមិន
មែនជារបស់ព្រះករុណាគុណម្ចាស់ញាតិញោមទេ ថែមទាំង
វាមានចេតសិកគឺវេទនា សញ្ញា សង្ខារ ប្រកបជាមួយនឹង
វិញ្ញាណផង ។ អារម្មណ៍ក្នុងលោកដែលយើងដឹងថា នេះ
ផ្ទះ នេះរថយន្ត នេះទ្រព្យសម្បត្តិ នេះភរិយាស្វាមីកូនប្រុស
ស្រីអីទាំងអស់ហ្នឹងគឺជាអារម្មណ៍របស់វិញ្ញាណទេ ញាតិ
ញោមត្រូវយល់ថាហ្នឹងជាអារម្មណ៍របស់វិញ្ញាណ កាលណា
បើយល់ថាអ្វីៗទាំងអស់ដែលវិញ្ញាណបានដឹងនោះ គឺគ្រាន់
តែជាអារម្មណ៍ ហើយជារបស់ខាងក្រៅពីវិញ្ញាណទៀត ។
ពាក្យថាខាងក្រៅនេះសំខាន់ណាស់ យើងត្រូវយល់ថា
វិញ្ញាណមិនអាចយកអារម្មណ៍ហ្នឹងបានទេ គ្រាន់តែមានកិច្ច
ដឹងអារម្មណ៍តែប៉ុណ្ណោះ ។ អ្វីៗទាំងអស់ដែលវិញ្ញាណបាន
ដឹងនោះ វិញ្ញាណមិនអាចយកអារម្មណ៍ហ្នឹងបានទេ ទោះ
ជាអារម្មណ៍ហ្នឹងនៅជិតក៏ដោយ នៅឆ្ងាយពីស្រុកខ្មែរក៏
ដោយគឺជាអារម្មណ៍របស់វិញ្ញាណ ហើយឱ្យតែជាអារម្មណ៍
គឺវិញ្ញាណមិនអាចយកបានទេ ហើយត្រូវយល់ម្យ៉ាងទៀត

ថាវិញ្ញាណក៏អត់ចាំបាច់អាស្រ័យអារម្មណ៍ហ្នឹងយកអារម្មណ៍ហ្នឹងឬត្រូវការអារម្មណ៍ហ្នឹងដែរ ព្រោះវិញ្ញាណជាធម្មតាកើតឡើងហើយរលត់ទៅ អត់មានត្រូវការយកអារម្មណ៍ហ្នឹងមកធ្វើអ្វីទេ ។ វិញ្ញាណដែលដឹងអារម្មណ៍ណាហើយវិញ្ញាណហ្នឹងក៏រលត់ទៅ ដូច្នេះវាអត់ចាំបាច់ត្រូវការអ្វីៗទេ ព្រោះជារបស់ខាងក្រៅ សូមមេត្តាសិក្សាឱ្យយល់យ៉ាងនេះទើបបានជាប្រយោជន៍ នេះហើយគឺជា **ធម្ម** ។ **ធម្ម** ជាភាសាបាលី ឯ **ធម៌** ជាភាសាសំស្ក្រឹត ។ **ធម្ម** នេះឯងគឺជា **ធម្មជាតិ** ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់ដឹងក្តី មិនត្រាស់ដឹងក្តី **ធម្ម** គឺ **ធម្មជាតិ** ហ្នឹងឯង ។ កាលណាបើយើងដឹង **ធម្ម** គឺ **ធម្មជាតិ** យ៉ាងនេះឯងដែលឈ្មោះថា យើងដឹងធម៌ ។ ចំពោះការដឹងធម៌នេះគឺជាការដឹងធម្មជាតិហ្នឹងឯង ។ ពាក្យថាព្រះអង្គសម្តែងធម៌ៗហ្នឹងគឺព្រះអង្គសម្តែងពីធម្មជាតិ ធម្មជាតិដែលព្រះអង្គត្រាស់ដឹងហើយ ព្រះអង្គបានយកមកសម្តែងប្រាប់ហៅថាសម្តែងធម៌ ។ កាលណាបើពុទ្ធបរិស័ទយើងបានស្តាប់ទៅ ធ្វើទុកក្នុងចិត្តយល់ទៅលើធម្មជាតិតាម

តែព្រះអង្គសម្ដែង ហ្នឹងឯងឈ្មោះថាដឹងធម៌ **បដិច្ចសមុប្បាទធម៌ អរិយសច្ចធម៌** នេះគឺធម៌ ។ កាលណាបើដឹងហើយវាត្រូវស្ងប់នូវឧបាទាន ស្ងប់នូវទុក្ខ ស្ងប់នូវកង្វល់ នេះឯងដែលជាទីពឹង ដែលសេចក្ដីស្ងប់នេះជាខាងក្នុង ។ ដូចជាខ្ញុំព្រះករុណាខ្ញុំបាទបានប្រគេនគុណម្ចាស់ ជំរាបជូនញាតិញោមអ៊ីចឹងគឺមានជំរៅណាស់ ប៉ុន្តែមិនហួសវិស័យនៃពុទ្ធបរិស័ទយើងទេ ។

ឥឡូវញាតិញោមកំពុងតែដឹងថា កំពុងតែស្ដាប់ធម៌សន្មត់ថាយើងកំពុងដឹង ប៉ុន្តែតាមពិតតើអ្វីជាធាតុដឹង? គឺវិញ្ញាណធាតុ បើអត់មានវិញ្ញាណទេនោះវាហាក់ដូចជាសាកសពអ៊ីចឹង ដូចជាអង្កត់អុសដែលមិនដឹងអីអ៊ីចឹង ប៉ុន្តែឥឡូវដែលយើងនៅរស់នេះ រូបនៅតែមិនដឹងអ៊ីចឹង ព្រោះរូបជាធាតុមិនដឹង ដូចជាសាកសពដែលស្លាប់ទៅអត់ដឹងកូនឃំ អត់ដឹងលោកសូត្រធម៌ យ៉ាងណាមិញរូបដែលកំពុងនៅរស់នេះ រូបហ្នឹងអត់ដឹងដូចគ្នា សាកសពអត់ដឹងយ៉ាងណារូបនេះក៏អត់ដឹងដូចគ្នា ។ អង្កត់អុស មែកឈើនៅ

ក្នុងព្រៃ អត់ចេះភ័យ អត់ចេះខ្លាច អត់ដឹងក្ដៅត្រជាក់ អត់ដឹងទឹកលិចឬភ្លើងឆេះ អត់ដឹង... យ៉ាងណាមិញឱ្យតែជារូបគឺជាធាតុមិនដឹង ។ ទាំងអស់នេះដែលយើងត្រូវយល់ទៅលើរូបធម៌គឺនៅត្រង់មិនដឹងហ្នឹងឯង ។ ឥឡូវយើងនៅរស់ក៏មិនដឹងដូចតែគ្នា ប៉ុន្តែតើអ្វីដែលដឹង? គឺហៅថានាមធម៌ ដែលយើងត្រូវយល់ថាអ្វីជារូបធម៌? អ្វីជានាមធម៌? នាមធម៌ជាធាតុដឹង ហើយនាមធម៌ហ្នឹងវាមិនមែនជាសត្វជាបុគ្គលស្ថិតនៅដឹងរហូតមួយជីវិតមកនោះទេ វាដឹងរួចហើយវារលត់ទៅៗ វាដូរគ្នារហូត តើនាមធម៌ហ្នឹងដឹងអ្វី? ដឹងអារម្មណ៍ ។ អ្វីដែលដឹងនេះឯងហៅថាអារម្មណ៍ដែលនាំឱ្យការដឹងហ្នឹងកើតឡើង ដូច្នេះអារម្មណ៍វាជាបច្ច័យនាំឱ្យការដឹងហ្នឹងកើតឡើង ដឹងរួចហើយក៏វាបាត់ទៅៗ ដូច្នេះក្រសែនៃការដឹងហ្នឹងវាតគ្នាមួយថ្ងៃៗច្រើនណាស់ ដូចជាព្រឹកមិញអ៊ីចឹង តើដឹងអ្វីខ្លះ? ការដែលដឹងពីព្រឹកមិញវាអត់មានមកនៅដល់ឥឡូវនេះទេ ឥឡូវនេះវាដឹងអារម្មណ៍ផ្សេងៗក្នុងពេលនេះ គឺវាអ៊ីចឹងឯង តើយល់ខ្លះដែរទេ?

ដូចជាយើងកំពុងស្តាប់ព្រះធម៌នេះ រួចទៅក៏ឈប់ហើយស្លូត្រយំកិច្ចទៅ ត្រូវទទួលទានក៏ទទួលទានទៅ ត្រូវទៅផ្ទះក៏អញ្ជើញទៅ ប៉ុន្តែរូបធម៌និងនាមធម៌ដែលកំពុងស្តាប់នេះវាបាត់អស់ទៅហើយ ។ ដល់ពេលញាតិញោមអញ្ជើញតាមរថយន្តទៅវិញ ហើយនឹកថារូបធម៌នាមធម៌ដែលកំពុងស្តាប់ព្រះធម៌នេះ តើមានបានទៅជិះឡានជាមួយទេ? ថាអត់ទេ វារលត់ទៅ វាបាត់ទៅ នេះឯងហៅថា **អសម្មោហសម្បជញ្ញៈ** ។ **អសម្មោហ** ប្រែថាមិនវង្វេង **សម្បជញ្ញៈ** គឺសេចក្តីដឹងខ្លួន មិនវង្វេងគឺឃើញរូបធម៌ និងនាមធម៌គ្រប់ពេលវេលាដែលត្រូវរលត់ទៅ វាអត់ស្ថិតស្ថេរទៀងទាត់នៅទេ ដែលឈ្មោះថាឃើញធម៌គឺត្រូវរៀនអ៊ីចឹងនេះជាព្រះកម្មដ្ឋាន ព្រះករុណាគុណម្ចាស់ញាតិញោមគឺត្រូវពិនិត្យមើលតាមហ្នឹងឯង ។

ដូច្នេះវិញ្ញាណដែលដឹងនូវអារម្មណ៍គឺដឹងថាអារម្មណ៍ជារបស់ខាងក្រៅ

កាលណាបើញាតិញោមយល់ច្បាស់ទៅ២

វាលះនូវតណ្ហាអត់ត្រូវការអ្វីទេ ព្រោះគ្រាន់តែជាអារម្មណ៍របស់វិញ្ញាណតែប៉ុណ្ណោះ ពីព្រោះអ្វី? ពីព្រោះអារម្មណ៍វាគ្រាន់តែជារបស់ខាងក្រៅ ។ វិញ្ញាណមានដឹងអារម្មណ៍ណាហើយយកអារម្មណ៍នោះបានឯណា ដឹង រូប សំឡេង ក្លិន រស ផោដ្ឋព្វៈហ្នឹងឯងហៅថាអារម្មណ៍ ហើយវិញ្ញាណក៏ដឹងអារម្មណ៍ហ្នឹងឯង ។

វិញ្ញាណដឹងហើយក៏រលត់ទៅៗ

អត់មានត្រូវការយកអារម្មណ៍ហ្នឹងមកធ្វើអ្វីទេ កាលណាបើកំណត់ដឹងយ៉ាងនេះទើបវារលត់តណ្ហា ។ ជាមួយគ្នានឹងការដឹងអារម្មណ៍ហ្នឹងវាមានវេទនាសោយអារម្មណ៍ផងដែរ តួដែលសោយអារម្មណ៍គឺវេទនា ។ កាលណាបើយើងអត់ដឹងកន្លែងហ្នឹងទេ យើងក៏ត្រូវការយកអារម្មណ៍នោះ ព្រោះវេទនាវាសោយអារម្មណ៍ណាជាទីពេញចិត្ត **វេទនា បច្ចយា តណ្ហា** តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ នេះនៅក្នុងបដិច្ចសមុប្បាទធម៌ ។ តើតណ្ហាយ៉ាងម៉េច? គឺវាទៅរកអារម្មណ៍នោះ យ៉ាងម៉េចបានវាទៅរក? ថាវេទនាវាសោយ

វាសោយទៅវាឆ្ងាញ់ វាសោយទៅវាសុខ វាសោយទៅវាស្រួល អ៊ីចឹងវាជាបច្ច័យឱ្យកើតតណ្ហាត្រូវការអារម្មណ៍ហ្នឹងឯង ហើយដល់ត្រូវការទៅតើវាយ៉ាងម៉េច? គឺនាំឱ្យកើតកម្ម គឺអំពើដែលកើតឡើងជាមនោសញ្ចេតនាសកម្មភាពដើម្បីឱ្យបាននូវអ្វីដែលតណ្ហាត្រូវការហៅថា **អភិសង្ខារ** ។ តណ្ហា ឧបាទានកើតភព ហើយភពហ្នឹងគឺកម្មភព គឺវាកើតឡើងអ៊ីចឹង ដោយសារតែការសោយអារម្មណ៍ណាហើយមិនមានការកំណត់ដឹង ។ តាមពិតការសោយហ្នឹងវាអត់មែនយើងជាអ្នកសោយអារម្មណ៍ទេ វេទនាសោយរួចក៏រលត់ទៅៗ ការធ្វើទុកក្នុងចិត្តយ៉ាងនេះទើបឈ្មោះថា **យោនិសោមនសិការ** ធ្វើទុកក្នុងចិត្តថា ឱ!ការសោយអារម្មណ៍ហ្នឹងមិនមែនយើងឯណាគឺវេទនាទេតើ បើអ៊ីចឹងមានចាំបាច់ទៅស្វែងរកអារម្មណ៍ធ្វើអ្វី បើវេទនាវាអត់មានត្រូវការអារម្មណ៍ហ្នឹងផងហ្នឹង វេទនាវារលត់ទៅ ដូច្នេះកន្លែងហ្នឹងឯងដែលរាំងស្ទះមិនឱ្យវេទនាជាបច្ច័យនៃតណ្ហា ស្ងប់រំងាប់នៃតណ្ហាបាន អ៊ីចឹងហើយបានជាព្រះខីណាស្រព

លោកអត់មានអភិសង្ខារគឺកម្ម ដល់តែវាអត់មានកម្មវាក៏អត់មានបដិសន្ធិក៏បរិនិព្វានទៅ ហ្នឹងដោយការអប់រំបញ្ញាយ៉ាងនេះឯង ហើយនេះក៏ជាគោលធម៌សំខាន់ក្នុងព្រះពុទ្ធសាសនា ។ ញាតិញោមស្រីប្រុសទាំងអស់បដិបត្តិធម៌មានសីលល្អ មានសមាធិល្អ មានបញ្ញាល្អ ប៉ុន្តែត្រូវចាំគោលធម៌ក្នុងជីវិតនេះ បើមិនឃើញបដិច្ចសមុប្បាទធម៌គឺធម៌ដែលកើតឡើងពីបច្ច័យត១គ្នាទេ គឺមិនអាចស្ងប់រំងាប់ចិត្តបានទេ មិនអាចរលត់តណ្ហាបានទេ ព្រោះតណ្ហាហ្នឹងវាត្រូវការអារម្មណ៍ ម៉េចបានជាទៅស្វែងរកអារម្មណ៍តណ្ហាហ្នឹង? ថាមកពីប្រកាន់ថាយើងអ្នកសោយនូវអារម្មណ៍ វេទនាកើតឡើងថាយើងអ្នកសោយ ។ បើសោយអារម្មណ៍ណាជាទីប្រាថ្នាគឺស្វែងរកអារម្មណ៍ហ្នឹងទៅ កាមតណ្ហា ភវតណ្ហាអ៊ីចឹងទៅ ហើយបើមិនពេញចិត្តនឹងអារម្មណ៍ណាក៏កើតទៅជាវិភវតណ្ហា ប្រាថ្នាគេច ប្រាថ្នាចៀសពីអារម្មណ៍ហ្នឹងទៅ តណ្ហាវាកើតពីវេទនាអ៊ីចឹងឯង ។ នេះជាសេចក្តីអធិប្បាយក្នុងគោលសំខាន់ក្នុងព្រះពុទ្ធសាសនា ។

យើងសិក្សាព្រះពុទ្ធសាសនា ក៏ព្រោះព្រះធម៌នេះអាចដើម្បីបញ្ចប់កង្វល់ក្នុងជីវិតយើងបាន គឺព្រះធម៌ធានាអ៊ីចឹង គ្រាន់តែយើងមានសម្មាទិដ្ឋិយល់ថា ព្រះធម៌ហ្នឹងគឺជានេយ្យានិកធម៌អាចនាំយើងចូលឱ្យដល់នូវការស្ងប់ពីកង្វល់បាន នេះគឺជាសម្មាទិដ្ឋិមួយសំខាន់ណាស់ ព្រោះជីវិតរបស់យើងនេះគឺជានាមរូបដែលជារូបធម៌ជានាមធម៌ ដែលបានសម្ដែងហើយថារូបជាធាតុមិនដឹង អត់ភ័យអត់ខ្លាចអត់តក់ស្លុត អត់ត្រូវការប្រាថ្នាអ្វីទាំងអស់ តើសាកសពនេះត្រូវការអ្វីទេ? អត់ត្រូវការទេ នេះហៅថារូបធម៌ យើងក៏មានមួយចំណែកដែរ ដែលសភាពមិនភ័យមិនខ្លាចមិនត្រូវការហ្នឹង យើងមានមួយចំណែកទៅហើយ ចំពោះរូបវាមិនចេះភ័យខ្លាចមិនចេះតក់ស្លុតអីទេព្រោះវាអត់ដឹង ដីទឹកភ្លើងខ្យល់មិនត្រូវការអ្វីទេ មិនប្រាថ្នាអ្វីទេ យើងក៏មានមួយចំណែកដែរ ហើយនៅមួយចំណែកទៀតគឺនាមធម៌ ។ ចំពោះនាមធម៌នេះ ទាល់តែយើងពិនិត្យមើលទៅទើបយើងដឹងថាយើងធ្វើការងារផ្សេងៗ ឥឡូវមកស្ដាប់ព្រះធម៌ ការដែល

ដឹងហ្នឹងគឺជានាមធម៌ ដល់ទៅពិនិត្យមើលមែនទែនទៅ នាមធម៌ហ្នឹងក៏អត់ត្រូវការអ្វីដែរ ព្រោះវាអត់មានតួខ្លួនឯង ត្រូវការទេចំពោះនាមធម៌ហ្នឹងនោះ អាស្រ័យរូបក៏កើតឡើង អ៊ីចឹងទៅ មើលដោយបញ្ញាទើបដឹងថារូបធម៌ និងនាមធម៌ តាមពិតអត់មានត្រូវការអ្វីទាំងអស់ ។ តួរូបធម៌ក្តីតួនាមធម៌ក្តីអត់មានត្រូវការអ្វីទេ ហើយក្នុងព្រះគុណម្ចាស់ក៏មាន ខ្ញុំព្រះករុណាខ្ញុំបាទក៏មាន ញាតិញោមបងប្អូនស្រីប្រុសអ៊ីស្រី អ៊ីប្រុសក៏មាននាមរូបហ្នឹងដែរ ហើយចុះបើតួនាមរូបមិនត្រូវការអ្វីទេ យ៉ាងម៉េចបានជាមិនត្រូវការ? កន្លែងហ្នឹងឯង ដែលពិបាកយល់ ខ្ញុំគ្រាន់តែឧទាហរណ៍ដូចពន្លឺនេះអ៊ីចឹង វាអាស្រ័យទាន ឬអាស្រ័យអគ្គិសនីទើបវាមានពន្លឺ ។ ពន្លឺនេះក៏អត់ត្រូវការអ្វីដែរ ចង់ភ្លឺក៏ភ្លឺទៅ ចង់ងងឹតក៏ងងឹតទៅ ឬដូចជាម្លប់ឈើអ៊ីចឹង វាអត់មានខ្លួនឯងទេ វាអាស្រ័យមែក អាស្រ័យស្លឹកទៅ វាក៏មានស្រមោលក៏មានម្លប់អ៊ីចឹងទៅ ។ អ្វីៗទាំងអស់វាអត់មានខ្លួនឯងទេ ដូចពន្លឺនេះអ៊ីចឹង ពន្លឺថ្ងៃ មានព្រះអាទិត្យក៏ភ្លឺទៅ បើអត់មានព្រះអាទិត្យក៏ងងឹតទៅ

វាមានខ្លួនឯងឯណា ហើយបើមានខ្លួនឯងវិញនោះពន្លឺហ្នឹង វានៅតែភ្លឺហើយ ប៉ុន្តែអ្វីៗទាំងអស់ក្នុងលោកអាស្រ័យហេតុ ឬអាស្រ័យបច្ច័យទើបកើតឡើង ។ អ្វីដែលអាស្រ័យហេតុ អាស្រ័យបច្ច័យកើតឡើងគឺវាអត់មានខ្លួនឯងទេ គឺជាផល របស់ហេតុ ។ នេះគឺជាទ្រឹស្តី តែទ្រឹស្តីនេះសំខាន់ណាស់ ដើម្បីឱ្យយើងចូលទៅដល់សច្ចធម៌ ពីព្រោះទ្រឹស្តីនេះគឺជា ការសម្តែងទៅលើសេចក្តីពិតនៃធម្មជាតិដែលព្រះអង្គត្រាស់ ដឹង អត់មានអ្វីមួយដែលវាកើតឯងៗទេ គឺទាល់តែផ្សំផ្គុំ ទើបកើតឡើង ។ អ្វីដែលកើតឡើងពីការផ្សំផ្គុំវាអត់មាន ខ្លួនឯងទេ អ្វីហ្នឹងឯងដែលយើងត្រូវមើលឱ្យឃើញ ហើយ រលត់តណ្ហាតែម្តង ព្រោះអ្វីនោះវាអត់ត្រូវការអីដោយខ្លួន ឯងទេ ហើយយើងហ្នឹងតែម្តងគ្រប់គ្នាគឺមានអាហ្នឹងឯង គឺ មាននាមរូបហ្នឹងឯង ប៉ុន្តែមកពីយើងអត់បានដឹង ដល់អ៊ីចឹង ទៅយើងចូលដល់ធម្មជាតិអត់បានទេ ព្រោះយើងចូលវាអត់ ដល់ ម៉្លោះហើយវាត្រូវការ តណ្ហាហ្នឹងវាមានអវិជ្ជាដែល

មិនដឹង វាក៏នាំឱ្យយើងត្រូវការប្រាថ្នានូវអារម្មណ៍ខាងក្រៅដោយសព្វគ្រប់ទាំងអស់អ៊ីចឹងទៅ វាទៅជាវដ្តសង្សារ តែដល់ទៅយើងបានព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនេះ យើងត្រូវចូលឱ្យដល់ខ្លួនឯងគឺចូលតាមរយៈបញ្ញា ចូលឱ្យដល់ខ្លួនឯងទៅបានដឹងថាខ្លួនយើងគឺនាមរូប ហើយនាមរូបហ្នឹងអត់ត្រូវការអ្វីទេ ។ កាលណាបើចូលដល់នាមរូបត្រូវរលត់តណ្ហា ត្រូវរលត់កិលេស មិនរលត់ដល់ទៅព្រះអរហន្តព្រះអនាគា ព្រះសកទាអ៊ីក៏អាចដល់សោតា ឬក៏មិនដល់សោតាក៏ចូលក្នុងផ្លូវហ្នឹងស្ងប់ទៅៗ គឺថាពិសេសណាស់ ។ សម្បត្តិក្នុងលោកនេះអត់មានតម្លៃអ្វីជាងការចូលដល់ធម៌ទេ អត់មានតម្លៃដូច អត់មានតម្លៃស្មើទេ ។ យើងត្រូវការបច្ច័យ៤ដោយសារមានបញ្ចក្ខន្ធទេ ទើបយើងត្រូវការរបស់ទាំងអស់ហ្នឹងគឺវាមានតម្លៃដោយសារបញ្ចក្ខន្ធ បើយើងរួចពីបញ្ចក្ខន្ធហើយ តើយើងត្រូវការអ្វីទៀត? ត្រូវការបាយយកមកធ្វើអ្វីបើយើងរួចពីបញ្ចក្ខន្ធហើយ ត្រូវការសំលៀកបំពាក់ ត្រូវការថ្នាំធ្វើអ្វីបើយើងវាអត់ឈឺផង ហើយដែល

យើងរួចពីបញ្ចក្ខន្ធនេះ មិនមែនទាល់តែស្លាប់ទៅទេ ឬទៅឯណាបានឈ្មោះថារួចពីបញ្ចក្ខន្ធគឺអត់ទេ គឺនៅរស់នេះឯង គឺកំពុងតែស្តាប់ធម៌ហ្នឹងត្រូវរួច ក៏អាចរួចពីបញ្ចក្ខន្ធហ្នឹងបាន ដូចជាព្រះសោតាបន្នបុគ្គលលោកឃើញនិព្វាន លោករួចមួយថ្នាក់ហើយ រួចពីរថ្នាក់ដល់សកទាគាមី រួចបីថ្នាក់ដល់អនាគាមី រួចបួនថ្នាក់ដល់ព្រះអរហត្តជាព្រះអរហន្តហ្នឹងគឺរួចអស់ហើយ ។ រឿងរួចពីបញ្ចក្ខន្ធនេះគឺរួចអ៊ីចឹង គឺរួចទាំងដែលយើងនៅរស់នេះឯង តើរួចនៅត្រង់ណា? គឺរួច ត្រង់ដែលថាមិនប្រកាន់បញ្ចក្ខន្ធនេះឯង ដូច្នេះយើងដល់

កន្លែងមួយដែលយើងអត់ចាំបាច់ត្រូវការបច្ច័យ៤ទេ កន្លែងហ្នឹងគឺរលត់តណ្ហា ។ ក្នុងចិត្តរបស់យើងវាអត់ប្រព្រឹត្តទៅក្នុងបច្ច័យ៤ដោយតណ្ហាទេ ព្រោះរបស់ទាំងអស់ហ្នឹងវាសម្រាប់តែបញ្ចក្ខន្ធ ហើយបើយើងទៅដល់កន្លែងមួយដែលអត់មានបញ្ចក្ខន្ធហើយ តើយើងមានខ្វះអ្វីទៀត? គឺអត់ខ្វះអ្វីទៀតទេ ព្រោះយើងមិនត្រូវការសម្បត្តិក្នុងភព

ដោយសារមានកន្លែងមួយដែលអត់បញ្ចក្ខន្ធ ហើយកន្លែងហ្នឹងឯងដែលជាកន្លែងរលត់ឧបាទាន កន្លែងដែលរលត់នូវតណ្ហា ទាំងដែលជីវិតកំពុងរស់នៅនេះឯង នេះគឺជាទិសដៅមួយសំខាន់ណាស់ ដើម្បីអប់រំចិត្តសន្តានចូលឱ្យដល់ធម៌សម្រាប់ពុទ្ធបរិស័ទយើងគ្រប់ព្រះអង្គគ្រប់គ្នា ។

សូមអនុមោទនាព្រះធម៌!...

សម្តែងដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**